**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

# ប្រភេទនៃទោសព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភាឆ្នាំ២០២២


**ស្រាវជ្រាវដោយ**

**និស្សិតឈ្មោះ៖ អ៊ុន ដេត**

**ស៊ាន កក្កដា**

សាស្ត្រាចារ្យណែនាំ

**ជុំ អ៊ឹម**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **អ៊ុន ដេត** និង **ស៊ាន កក្កដា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាលាកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

ខ្ញុំសូមធ្វើការគោរពនិងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះមាតាបិតា ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងបានផ្តល់នូវដំបូន្មានប្រៀនប្រដៅល្អជាច្រើន ដោយមិនឲ្យរូបកូនប្រព្រឹត្តនូវទុច្ចរិត គឺឲ្យសាងតែអំពើល្អ លះបង់នូវអំពើអបាយមុខ ខិតខំព្យាយាមរៀនសូត្រ ជាពិសេសនោះអ្នកមានគុណទាំងពីរតែងតែលើកទឹកចិត្តដល់រូបកូនគ្រប់ពេលវេលា ដោយពុំមានការត្អូញត្អែទេ ទោះបីហត់នឿយធ្វើការងារបែកញើសហូរឈាមក៏ដោយ គឺសុទ្ធសឹងតែធ្វើដើម្បីកូន។ ព្រោះថា ចង់ឲ្យកូនមានអនាគតល្អ ជាកូនល្អ សិស្សល្អ ពលរដ្ឋល្អនៅក្នុងសង្គមជាតិទាំងមូល។ ទាំងអស់នេះហើយ សុទ្ធតែជាកម្លាំងចិត្ត បានជំរុញរូបកូន ឲ្យមានការខិតខំប្រឹងប្រែងស្រាវជ្រាវ សរសេរសារណាបញ្ចប់ការសិក្សារហូតទទួលបានដោយជោគជ័យ។

ទទឹមគ្នានេះដែរយើងខ្ញុំទាំងពីររូបសូមថ្លែងអំណរអរគុណចំពោះលោកសាស្ត្រាចារ្យ **ជុំ អ៊ីម** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងសេចក្តីសុខផ្ទាល់ខ្លួនមកដល់រូបខ្ញុំ តាមរយៈការណែនាំនិងការពន្យល់បង្ហាត់បង្ហាញក្នុងការសរសេរសារណានេះដើម្បីទទួលបានជាសមត្ថផលល្អ ។

ជាចុងក្រោយនេះ ខ្ញុំបាទទាំងពីររូប សូមអំណរគុណ និងបួងសួងដល់បារមីនៃវត្ថុស័ក្តសិទ្ធក្នុងលោក សូមជួយបីបាច់ថែរក្សាដល់អ្នកមានគុណ និងលោកគ្រូសាស្ត្រាចារ្យ ឲ្យជួបតែសេចក្តីសុខ មានសុខភាព និងប្រាសចាករោគទាំងពួងគ្រប់ពេលវេលា កុំបីអាក់ខានឡើយ។

# អារម្ភកថា

នៅក្នុងឆ្នាំទី៤ ដែលជាឆ្នាំចុងក្រោយនៃថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាលកវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយការខិតខំសិក្សារៀនសូត្រ និងផ្តល់ដំបូន្មានល្អៗពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យកន្លងមក ទើបក្រុមយើងខ្ញុំសម្រេចចិត្ត តាក់តែងសារណាបញ្ចប់ការសិក្សា ដោយបានជ្រើសរើសយកប្រធានបទ ប្រភេទនៃទោសព្រហ្មទណ្ឌ ដើម្បីធ្វើការបកស្រាយ និងពន្យល់ទៅលើប្រធានបទមួយនេះ។

សព្វថ្ងៃនេះ ប្រភេទនៃទោសព្រហ្មទណ្ឌ មានការជាប់ទាក់ទងទៅនិងបុគ្គលអ្នកប្រព្រឹត្ត ទៅតាមស្ថាននិងអំពើរបស់ខ្លួន ដែលរស់នៅសង្គមបច្ចុប្បន្ន។ ហេតុនេះហើយ ទើបក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវប្រមូលផ្តុំ និងចងក្រងនូវខ្លឹមសារ បូករួមទាំងបានការណែនាំពីសាស្ត្រាដឹកនាំ ក្នុងគោលបំណងចូលរួមជាចំណេះដឹង និងអភិវឌ្ឍន៍ ចំណេះដឹងទៅលើ ប្រភេទនៃទោសព្រហ្មទណ្ឌ ឲ្យបានដឹងស៊ីជម្រៅ ងាយស្រួលដល់ការអនុវត្ត នូវពេលមានបទល្មើសអ្វីមួយបានកើតមានឡើង ជាពិសេសនោះ គឺបានផ្តល់គំនិតដល់និស្សិតជំនាន់ក្រោយដែលសិក្សាអំពីផ្នែកច្បាប់ រួមទាំងជាប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងមូល មានបំណងចង់ឈ្វេងយល់អំពី **ប្រភេទនៃទោសព្រហ្មទណ្ឌ** របស់ព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ក្រុមយើងខ្ញុំសង្ឃឹមថា ការខិតខំប្រឹងប្រែង ស្រាវជ្រាវធ្វើសារណាមួយនេះ និងជួយជាគំនិតយោបល់ដល់សិស្សប្អូនៗជំនាន់ក្រោយបន្តទៅទៀត។ ម៉្យាងទៀត ក៏សូមអភ័យទោស ចំពោះកំហុសខុសឆ្គងដោយអចេតនា ដែលមាននៅក្នុងអត្ថបទ រួមទាំងខ្លឹមសារ ក្រុមយើងខ្ញុំរងចាំទទួលការផ្តល់យោបល់ និងការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកលោកស្រីសាស្ត្រាចារ្យ និស្សិត និងអ្នកស្រាវជ្រាវទាំងអស់ ដោយសោមនស្សរីករាយ ដើម្បីឲ្យស្នាដៃមួយនេះ កាន់តែមានលក្ខណៈល្អប្រសើរថែមទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ១

## ជំពូកទី១

## ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គល

**១.១ .មូលទោស** ............................................................ ៣

១.១.១. ប្រភេទនៃមូលទោស ............................................................ ៣

១.១.១.១. ទោសដាក់ពន្ធនាគារ ............................................................ ៣

១.១.១.២. ទោសពិន័យជាប្រាក់ ............................................................ ៤

១.១.១.៣. របៀបសម្គាល់នៃបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុ ............................................................ ៥

ក. បទឧក្រិដ្ឋ ............................................................ ៥

ខ. បទមជ្ឈឹម ............................................................ ៥

គ. បទលហុ ............................................................ ៦

**១.២. ការប្រកាសមូលទោស** ............................................................ ៧

១.២.១. ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជានីតិជន ............................................................ ៧

១.២.២. ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជាអនីតិជន ............................................................ ៨

ក. ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ............................................................ ៩

ខ. ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ............................................................ ៩

**១.៣. ទោសបន្ថែម** ............................................................ ១០

១.៣.១. ប្រភេទនៃទោសបន្ថែមទាំង១៩ ចំណុចក្នុងក្រមព្រហ្មទណ្ឌ ............................................................ ១០

១.៣.២. ការប្រកាសទោសបន្ថែម ............................................................ ១៤

១.៣.៣. លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម ............................................................ ១៤

១.៣.៣.១.ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គលជានីតិជន ............................................................ ១៥

១.៣.៣.២.ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គលជាអនីតិជន ............................................................ ១៦

ក. ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ............................................................ ១៦

ខ. ចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់អាយុ១៨ឆ្នាំ ............................................................ ១៦

**១.៤. ទោសជំនួស** ............................................................ ១៧

១.៤.១. ប្រភេទនៃទោសជំនួស..........១៧
១.៤.១.១. ទោសការងារសហគមន៍..........១៧
ក. និយមន័យនៃការងារសហគមន៍..........១៧
ខ. របបគតិយុត្តិនៃការងារសហគមន៍..........១៧
គ. អ្នកមិនទទួលផលប្រយោជន៍នៃការងារសហគមន៍..........១៨
ឃ. គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ..........១៨
១.៤.១.២. ទោសស្តីបន្ទោស..........១៨
ក. អត្ថន័យនៃទោសស្តីបន្ទោស..........១៨
ខ. របបគតិយុត្តនៃការស្តីបន្ទោស..........១៩
១.៤.២. ការប្រកាសទោសជំនួស..........១៩
១.៤.២.១. ការប្រកាសទោសការងារសហគមន៍..........១៩
ក. លក្ខខណ្ឌនៃការប្រកាសទោសការងារសហគម៍..........១៩
ខ. ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជានីតិជន..........២០
គ. ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជាអនីតិជន..........២០
១. អនីតិជនដែលមានអាយុក្រោម ១៦ឆ្នាំ..........២០
២. អនីតិជនដែលមានអាយុយ៉ាងតិច ១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ..........២០
១.៤.២.២. ការប្រកាសទោសស្តីបន្ទោស..........២១
ក. លក្ខខណ្ឌនៃការប្រកាសទោសស្តីបន្ទោស..........២១
ខ. ការប្រកាសទោសស្តីបន្ទោសចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ..........២១

## ជំពូកទី២

## ទោសដែលត្រូវអនុវត្តសម្រាប់នីតិបុគ្គល

**២.១. មូលទោសក្នុងប្រភេទជាទោសពិន័យ**..........២៥
**២.២. ទោសបន្ថែមទាំង១៤ចំណុចកំណត់ដោយក្រមព្រហ្មទណ្ឌ**..........២៦
**២.៣. ការប្រកាសទោសព្រហ្មទណ្ឌ ចំពោះទោសនីមួយៗទៅលើនិតិបុគ្គល**..........៣០
២.៣.១. នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិបុគ្គលដែលជារដ្ឋ..........៣១
២.៣.២. នីតិបុគ្គលដែលជានីតិឯកជន ឬ នីតិបុគ្គលដែលមិនមែនជារដ្ឋ..........៣២
២.៣.៣. ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស..........៣៣

២.៣.៤. ទោសបន្ថែមទាំង១៤ចំណុច ....................................................................... ៣៣

## ជំពូកទី៣

## ស្ថានសម្រាលទោស និងស្ថានទម្ងន់ទោស

**៣.១. ស្ថានទម្ងន់ទោស** ....................................................................... ៣៧
**៣.១.១. ស្ថានទម្ងន់ទោសទូទៅ ឬ ចរិតគ្រោះថ្នាក់នៃអំពើរបស់ជនល្មើស** ............... ៣៨
៣.១.១.១. ក្រុមមានការចាត់តាំង ....................................................................... ៣៨
៣.១.១.២. ការគិតទុកជាមុន ....................................................................... ៣៨
៣.១.១.៣. ការកាប់គាស់ទម្លុះទម្លាយ ....................................................................... ៣៩
៣.១.១.៤. ការផ្លោះរបងចូល ....................................................................... ៣៩
៣.១.១.៥. ការប្រើប្រាស់អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ ....................... ៣៩
៣.១.១.៦. ការពួនស្ទាក់ ....................................................................... ៣៩
**៣.១.២. ការមិនរាងចាល** ....................................................................... ៣៩
៣.១.២.១. អានុភាពនៃការមិនរាងចាល ....................................................................... ៤០
៣.១.២.២. លក្ខខណ្ឌនៃការមិនរាងចាល ....................................................................... ៤០
**៣.២. ស្ថានសម្រាលទោស** ....................................................................... ៤៤
៣.២.១. មូលដ្ឋានគ្រឹះស្ថានសម្រាលទោស ....................................................................... ៤៤
៣.២.១.១. និយមន័យនៃស្ថានសម្រាលទោស ....................................................................... ៤៤
៣.២.១.២. ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស ....................... ៤៥
៣.២.២. ខ្នាតនៃស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលជានីតិជន និងអនីតិជន ....................... ៤៦
៣.២.២.១. ខ្នាតនៃស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលជានីតិជន ....................... ៤៦
៣.២.២.២. ខ្នាតនៃស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលជាអនីតិជន ....................... ៤៩
**សេចក្តីសន្និដ្ឋាន** ....................................................................... ៥១
**អនុសាសន៍** ....................................................................... ៥៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាការពិតណាស់ នៅពេលដែលប្រទេសជាតិមានលក្ខណៈជឿនលឿនរីកចម្រើន ជាបន្តបន្ទាប់នោះ មនុស្សគឺត្រូវការរបស់របរប្រើប្រាស់គ្រប់យ៉ាង ដើម្បីបំពេញសេចក្តីត្រូវរបស់ខ្លួន រស់នៅក្នុងសង្គមមានភាពងាយស្រួល និងសេចក្តីសុខ។ តែថា បើទោះជាមនុស្សយើងមាននូវសេចក្តីសុខស្រួលក៏ដោយ តែបើភាពសុខស្រួលនោះមានលក្ខណៈខុសច្បាប់ ឬបង្កភាពចលាចលដល់អ្នកដទៃនោះ ពិតណាស់ថា ការរស់នៅក្នុងសង្គមមួយ មិនអាចគេចផុតពីការទំនាក់ទំនងបានឡើយ។ ដូចនេះហើយ បានជានៅក្នុងប្រទេសមួយតម្រូវឲ្យមានច្បាប់ការពារនៅពេលដែលមានបទល្មើសអ្វីមួយកើតឡើង។

តាំងពីដើមមកអ្នកដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌបាន គឺមានតែរូបវន្តបុគ្គលប៉ុណ្ណោះ មានន័យថា ជាបុគ្គលមាន សាច់ ឈាម គឺសំដៅដល់មនុស្សគ្រប់រូបម្នាក់ៗហ្នឹង ដែលជាប្រធាននៃបទល្មើស។ ប៉ុន្តែការវិវត្តន៍ និងការយល់ឃើញក្នុងសម័យបច្ចុប្បន្ន យើងឃើញថាក្រៅពី រូបវន្តបុគ្គល គឺមានបុគ្គលមួយរូបទៀត ដែលបុគ្គលម្នាក់នេះ បានកំណត់ដោយច្បាប់ មានឈ្មោះថា នីតិបុគ្គល ។ ដូច្នេះហើយ នីតិបុគ្គលនៅក្នុងសម័យទំនើបនាពេលបច្ចុប្បន្ន ឬនីតិបុគ្គលនៅក្នុងប្រទេសស៊ីវិល័យនេះ គេបានចាត់ទុកថា គឺជាតួងអង្គដ៍សំខាន់ គឺជាប្រធាននៃបទល្មើសដ៍មានសក្កានុពល ឬយើងហៅទៀតថា ជនល្មើសដ៍មានសក្កានុពលនៅក្នុងសង្គមសម័យទំនើប ហើយជាពិសេសនៅក្នុងសង្គមបច្ចុប្បន្ន។ គេយល់ឃើញថា បុគ្គលដែលបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស មានទាំងរូបវន្តបុគ្គល និងនីតិបុគ្គលផង។ ដូចនេះក្រមព្រហ្មទណ្ឌ ដើម្បីតាមឲ្យទាន់សភាពការណ៍ ក្រមព្រហ្មទណ្ឌបានកំណត់បែងចែកអំពីអ្នកទទួលខុសត្រូវនោះ មានទាំងរូបវន្តបុគ្គល មានទាំងនីតិបុគ្គល។ ដូច្នេះហើយ ដើម្បីឲ្យយល់ដឹងច្បាស់ថា តើទោសព្រហ្មទណ្ឌមានអ្វីខ្លះ ? តើទោសព្រហ្មទណ្ឌនេះត្រូវយកអនុវត្តចំពោះ រូបវន្តបុគ្គល ឬមួយក៏ ចំពោះនីតិបុគ្គល ដោយរបៀបណា ? ហើយមានយន្តការ និងរបបគតិយុត្តមួយដាច់ដោយឡែក បើចំពោះនីតិបុគ្គលក៏មានរបបគតិយុត្តមួយដាច់ដោយឡែកដែរនោះ។

សារណានេះបានរៀបរៀង ដោយធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលនូវព័ត៌មានទាំងឡាយដែលក្នុងនោះរួមមានដូចជា ឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណាមួយនេះ ដើម្បីឲ្យមានភាពត្រឹមត្រូវនិងច្បាស់លាស់។ ការដកស្រង់ចេញមកពីប្រភពល្អៗ ក៏ដូចជាការបកស្រាយរបស់នីតិករ អ្នកដែលមានបទពិសោធន៍នៅក្នុងវិស័យច្បាប់ និងអ្នកជំនាញផ្នែកច្បាប់។ ដើម្បីជាការឆ្លើយតបទៅនិងប្រធានបទខាងលើ គឺក្រុមរបស់ខ្ញុំសូមធ្វើការបែងចែកចេញជា៣ជំពូកធំៗ រួមមាន៖

ជំពូកទី១៖ ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គល

ជំពូកទី២៖ ទោសអនុវត្តសម្រាប់នីតិបុគ្គល

ជំពូកទី៣៖ ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស

# ជំពូកទី១
# ទោសដែលត្រូវអនុវត្ត
# ចំពោះរូបវន្តបុគ្គល

# ជំពូកទី១

# ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គល

រូបវន្តបុគ្គល គឺមានន័យថា ជាបុគ្គលដែលមានសាច់ មានឈាម និងមានជីវិតដែលអាចរស់នៅបាន ជាមនុស្សពិតៗតាមបែបធម្មជាតិ ហើយរូបវន្តបុគ្គលនេះ គឺផ្ទុយទៅនិងនីតិបុគ្គល។[1] សម្រាប់ប្រភេទទោសដែលត្រូវយកមកអនុវត្តទៅលើរូបវន្តបុគ្គលនោះរួមមាន មូលទោស ទោសបន្ថែម និងទោសជំនួស។

## ១.១ មូលទោស

មូលទោស គឺទោសដាក់ពន្ធនាគារ និងទោសពិន័យ។[2] មូលទោស គឺជាទោសមូលដ្ឋាន ដែលអាចយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោស ចំពោះទៅលើជនដែលជាប់ចោទ និងជនដែលបានធ្វើការប្រព្រឹត្តនូវបទល្មើស។ ន័យម្យ៉ាងទៀត មូលទោសគឺជាទោសទាំងឡាយណាដែលច្បាប់បានប្បញ្ញត្តិ ជាលក្ខណៈសារវន្ត ចំពោះបទល្មើសនីមួយៗ។ ហើយមូលទោសនេះ មានការប្រែប្រួលទៅតាមប្រភេទនៃជនល្មើស ជារូបវន្តបុគ្គល ឬនីតិបុគ្គល។[3] ដោយឡែក ចំពោះមូលទោស ក៏មានការកំណត់នៅក្នុងក្រមព្រហ្មទណ្ឌដែលបានចែងថា៖ មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ការពិន័យជាប្រាក់ត្រូវគិតជាប្រាក់រៀល។ ម្យ៉ាងវិញទៀត មូលទោស ជាទោសសំខាន់ចម្បងជាងគេដែលតុលាការ អាចធ្វើការប្រកាសទោសតែឯង ដើម្បីផ្តន្ទាទោសចំពោះបទល្មើសណាមួយ។

### ១.១.១ ប្រភេទនៃមូលទោស

ជាទូទៅមូលទោស គឺត្រូវបានបែងចែកជាពីរប្រភេទធំៗក្នុងនោះរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ប៉ុន្តែសម្រាប់ទោសពិន័យជាប្រាក់ គឺគិតជាប្រាក់រៀល ដោយផ្អែកតាមក្រមព្រហ្មទណ្ឌបានបញ្ញត្តិទុក។

#### ១.១.១.១ ទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ គឺជាទោសដាក់គុក ឬជាទោសដែលបំបាត់សេរីភាពរបស់បុគ្គល ដែលបានប្រព្រឹត្តនូវបទល្មើស និងត្រូវបានផ្តន្ទាទោសដោយដាក់ទោសពន្ធនាគារ គឺមានន័យថា ទោសដាក់ពន្ធនាគារ ជនណាម្នាក់ក្រោយពេលដែលសាលក្រមបានសម្រេចដាក់ពន្ធនាគាររួចហើយ គឺត្រូវយកជននោះ ទៅដាក់គុក ពីព្រោះថាការអនុវត្តទោសគឺត្រូវធ្វើនៅពន្ធនាគារ។ នៅក្នុងក្រមព្រហ្មទណ្ឌថ្មីបានកំណត់អំពីរបៀបនៃការគណនាចំពោះការដាក់ពន្ធនាគារ ឬទោសគុកនេះផងដែរ។ ក្រមព្រហ្មទណ្ឌបានកំណត់ថា៖ ប្រសិនបើជាទោសដាក់ពន្ធនាគារកំណត់ដោយរយៈពេល ០១ថ្ងៃ ហេតុដូច្នេះច្បាប់បានកំណត់ថា ០១ថ្ងៃនេះ គឺមានរយៈពេល២៤ម៉ោង។ បើជន

[1] សន្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០០១ លេខរៀងទី១៩៩។

[2] មាត្រា៤៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

[3] រៀបរៀងដោយ លោក លីន សិលា និយាយអំពីនិយមន័យនៃមូលទោស។

ណាម្នាក់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ០១ខែ របៀបនៃការគណនា ០១ខែ ត្រូវគិត ៣០ ថ្ងៃ។ បើសិនជាជនម្នាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារក្នុងរយៈពេល០១ឆ្នាំ របៀបក្នុងការគណនា ត្រូវគិត ១២ ខែ។[4]

ទន្ទឹមនឹងនេះផងដែរ ចំពោះក្រមព្រហ្មទណ្ឌក៏បានកំណត់អំពីលក្ខខណ្ឌនៃការបញ្ចប់ទោស ដោយហេតុថា ជាគោលការណ៍ នៅពេលដែលតុលាការបានដាក់ពន្ធនាគារទៅលើជនណាម្នាក់ហើយ ជននោះ គឺត្រូវតែទទួលរងនូវទោសក្នុងពន្ធនាគារឲ្យបានគ្រប់ចំនួន គឺមានន័យថា បើជននោះត្រូវដាក់គុកមានចំនួន ០៣ ឆ្នាំ ដូច្នេះ ជននោះត្រូវតែទទួលរងទោសឲ្យបានគ្រប់ចំនួនឆ្នាំយ៉ាងពេញលេញ ដោយគិតទៅតាមរបៀបគណនា ដូចបានរៀបរាប់ត្រូវចំណុចពីខាងដើមមកហើយ។ ចំពោះករណីពិសេសមួយទៀតនោះ ដោយផ្អែកទៅតាមក្រមព្រហ្មទណ្ឌបានធ្វើការកំណត់នៃការបញ្ចប់ទោសថា ជាគោលការណ៍ទណ្ឌិត ដែលទោសរបស់ខ្លួនត្រូវបានបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀត ដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឲ្យមានសេរីភាពនៅមុនថ្ងៃឈប់សម្រាកនោះ។[5] នៅត្រង់ចំណុចនេះ គឺមានន័យថា រាល់ទណ្ឌិតដែលបានបញ្ចប់ទោសទៅតាមការកំណត់ ដោយការបញ្ចប់ទោសនោះ ស្រាប់តែចំថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬមួយចំថ្ងៃឈប់សម្រាកជាផ្លូវការណ៍ ដូច្នេះទណ្ឌិតនោះ ត្រូវបានដោះលែងនៅថ្ងៃសុក្រនោះតែម្តង។

### ១.១.១.២ ទោសពិន័យជាប្រាក់

នៅក្នុងមូលទោសនេះផងដែរ មានទោសមួយទៀត ដែលគេឲ្យឈ្មោះថា គឺជាទោសពិន័យ សម្រាប់អនុវត្តទៅលើរូបវន្តបុគ្គល។ ដោយយោងទៅតាមក្រមព្រហ្មទណ្ឌដែលបានចែងថា៖ ការពិន័យត្រូវគិតជាប្រាក់រៀល។ ដែលតម្រូវឲ្យទណ្ឌិតបង់ចំនួនប្រាក់ទៅតាមការកំណត់របស់ច្បាប់។[6] យោងទៅតាមក្រមព្រហ្មទណ្ឌគឺបានធ្វើការបញ្ជាក់ថា៖ ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលជាថវិការរដ្ឋ។[7] ហើយចំពោះទឹកប្រាក់នេះ ត្រូវកំណត់ជាប្រាក់រៀល ប្រាក់រៀលដែលជាផលនៃការពិន័យត្រូវទុកជាប្រាក់ចំណូលសម្រាប់ថវិការជាតិ ដោយត្រូវយកទៅរក្សាទុកនៅក្នុងរតនាគារជាតិ។របៀបនៃការប្រមូលប្រាក់ពិន័យនោះក៏មានការចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ៖ ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារជាតិនៅក្រោមឱវាទរបស់អយ្យការ។[8] ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីដែលបានប្រមូលបាននេះត្រូវបង់ចូលថវិការដ្ឋ។

[4] មាត្រា៤៩នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ២០០៩។
[5] មាត្រា៥០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ២០០៩។
[6] មាត្រា៥២នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[7] មាត្រា៥២នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[8] មាត្រា៤៩៨នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

នីតិវិធីក្នុងការទាញយកនូវប្រាក់ពិន័យនេះ គឺក្រោយពេលដែលសេចក្ដីសម្រេច ចូលជាស្ថាពររួចហើយ។ បន្ទាប់មក នឹងជូនដំណឹងអំពីសេចក្ដីសម្រេចស្ថាពរនេះទៅឲ្យរតនាគារជាតិ រតនាគារជាតិនឹងចេញលិខិតមួយ ដើម្បីឲ្យជននោះទៅបង់ប្រាក់ដោយស្ម័គ្រចិត្ត ហើយការអនុវត្តក្នុងការបង់ប្រាក់ពិន័យនេះ គឺត្រូវស្ថិតនៅក្រោមការឃ្លាំមើល ឬក្រោមឱវាទរបស់អង្គការអយ្យការ។

ប្រសិនបើថា ជននោះពុំបានធ្វើការបង់ប្រាក់ទៅតាមពិន័យ ឬគេចវេសពីការបង់ប្រាក់ពិន័យនោះ ដូច្នេះ ព្រះរាជអាជ្ញានឹងចេញដីកាមួយកំណត់ឲ្យជននោះទៅបង់ប្រាក់ពិន័យនោះសាជាថ្មីម្ដងទៀត ក៏ប៉ុន្តែ បើករណី ជននោះនៅតែរឹងទទឹងមិនខ្វល់ខ្វាយ ឬមួយមិនអនុវត្ត ព្រះរាជ្ញាអាចប្រើនីតិវិធីបង្ខំបាន ដើម្បីទារយកប្រាក់ពិន័យ។

### ១.១.១.៣ របៀបសម្គាល់នៃបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុ

យោងទៅតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩មាត្រា៤៦ ដល់មាត្រា៤៨ បានចែងអំពីចំណាត់ថ្នាក់នៃបទល្មើស បានបែងចែងជា ៣ប្រភេទ គឺបទឧក្រិដ្ឋ បទមជ្ឈឹម និងបទលហុ។ ដែលប្រភេទថ្នាក់នៃបទល្មើសនេះ មានលក្ខណៈសម្គាល់ខុសគ្នា ដោយវាប្រែប្រួលទៅតាមបទល្មើសរបស់បុគ្គលអ្នកប្រព្រឹត្ត។ បន្ទាប់ទៅនេះ យើងនឹងសិក្សាពីភាពខុសគ្នា រវាងបទល្មើសបទឧក្រិដ្ឋ បទមជ្ឈឹម និងបទលហុ ថាតើ បទឧក្រិដ្ឋ បទមជ្ឈឹម និងបទលហុ មានការកំណត់សម្គាល់ដូចម្ដេច?

#### ក. បទឧក្រិដ្ឋ

បទឧក្រិដ្ឋ គឺជាបទល្មើសដែលមានទណ្ឌកម្មធ្ងន់ធ្ងរបំផុត។ បទល្មើសនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី៥(ប្រាំ)ឆ្នាំ និងក្រោម ឬស្មើនឹង៣០(សាមសិប)ឆ្នាំ ឬដាក់ពន្ធនាគារអស់មួយជីវិត។[9] បើតាមការកំណត់និយមន័យរបស់បទឧក្រិដ្ឋ ដោយយោងទៅតាមមាត្រា៤៦នៃក្រមព្រហ្មទណ្ឌបានចែងថាៈ បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិប្បរមានៃទោសដាក់ពន្ធនាគារគឺត្រូវៈ

- ជាទោសដាក់ពន្ធនាគារអស់មួយជីវិត។
- ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី៥(ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង៣០(សាមសិប)ឆ្នាំ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[10]

#### ខ. បទមជ្ឈឹម

បទមជ្ឈឹម គឺជាបទល្មើសដែលមានទណ្ឌកម្មជាមធ្យមនៃទោស ដែលត្រូវដាក់ពន្ធនាគារមានរយៈពេលលើសពី៦(ប្រាំមួយ)ថ្ងៃ ដល់៥(ប្រាំ)ឆ្នាំ។

[9] សន្ធានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌនៃទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ១៨៣។
[10] មាត្រា៤៦នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

បើតាមការកំណត់និយមន័យរបស់បទល្មើសមជ្ឈិមក្នុងក្រមព្រហ្មទណ្ឌបានចែងថា៖ បទល្មើសមជ្ឈិម នៅក្នុងករណី ដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ គឺមានរយៈពេលលើសពី៦(ប្រាំមួយ)ថ្ងៃ និងក្រោម ឬស្មើនឹង៥(ប្រាំ)ឆ្នាំ ហើយទោសដាក់ពន្ធនាគារនេះ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[11]

### គ. បទលហុ

បទលហុ គឺជាបទល្មើសដែលមានទណ្ឌកម្មស្រាលជាងគេ។ បទល្មើសលហុនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើនឹង៦(ប្រាំមួយ)ថ្ងៃ ឬពិន័យជាប្រាក់ប៉ុណ្ណោះ។ បើតាមការកំណត់និយមន័យរបស់បទលហុ ដោយយោងទៅតាមមាត្រា៤៨នៃក្រមព្រហ្មទណ្ឌបានចែងថា៖ បទល្មើសលហុ នៅក្នុងករណី៖

អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ គឺត្រូវមានរយៈពេលក្រោម ឬស្មើនឹង៦(ប្រាំមួយ)ថ្ងៃ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។[12]

ដូចនេះ បទល្មើសមួយចាត់ទុកថាជាបទលហុ លុះត្រាតែកម្រិតអតិបរមានៃទោសដាក់ពន្ធនាគារ មានរយៈពេលស្មើ ឬតិចជាង(ប្រាំមួយ)ថ្ងៃ ឬជាបទល្មើសដែលគ្មានទោសដាក់ពន្ធនាគារទេ គឺមានតែទោសពិន័យជាប្រាក់ប៉ុណ្ណោះ ។

បើយោងទៅតាមក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩ បានចែងអំពីប្រភេទនៃបទល្មើសលហុ ដែលមានចំនួន ១០បទល្មើសក្នុងនោះរួមមាន៖

មាត្រា ២២៨ គឺជាបទហិង្សាស្រាល

មាត្រា ២៩៧ ជាបទស្រវឹងជាក់ស្តែង

មាត្រា ២៩៨ ជាបទហៅអ្នកដទៃនៅទីសាធារណៈ

មាត្រា ៣០៥ ជាបទបរិហាកេរ្តិ៍ជាសាធារណៈ

មាត្រា ៣០៧ ជាបទជេរប្រមាថជាសាធារណៈ

មាត្រា៤១៨ ជាបទធ្វើឱ្យមានការខូចខាតស្រាល

មាត្រា ៤២០ ជាបទធ្វើឱ្យមានការខូចខាត បណ្ណ ប្រកាស ឬសេចក្តីជូនដំណឹងជាផ្លូវការ

មាត្រា ៥០២ ជាបទប្រមាថ

មាត្រា៥១៦ ជាបទប្រមាថចំពោះព្រះសង្ឃដូនជី និងតាជី

---

[11] មាត្រា៤៧នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[12] មាត្រា៤៨នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

មាត្រា៦៥១ ជាបទដាក់ឲ្យធ្វើចារចរណ៍ជាថ្មីនូវរូបិយវត្ថុ និងរូបិយបណ្ណក្លែង ។

### ១.២ ការប្រកាសមូលទោស

ជាគោលការណ៍ ការប្រកាសមូលទោស គឺត្រូវបានធ្វើឡើងនៅចំពោះ រូបវន្តបុគ្គល ដែលជានីតិជន និង អនីតិជន សុទ្ធតែទទួលបាននូវការប្រកាសមូលទោសដូចៗគ្នាទាំងអស់។ តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ ចំពោះជនរងគ្រោះ។

នៅក្នុងក្រមព្រហ្មទណ្ឌបានចែងអំពីគោលការណ៍នីត្យានុកូលភាពនៃទោសថា៖ មានតែទោសដែលមានចែងក្នុងបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចយកទៅប្រកាសបាន។[13] ដូច្នេះហើយការប្រកាសទោសត្រូវបានធ្វើឡើងតាមករណីនីមួយៗដូចជា៖

- ចំពោះបទល្មើសដែលមានទោសដាក់ពន្ធនាគារ តុលាការអាចប្រកាស តែទោសដាក់ពន្ធនាគារតែប៉ុណ្ណោះ មិនអាចបន្ថែមទោសពិន័យជាប្រាក់បាននោះទេ។

- ចំពោះបទល្មើសដែលមានទោសពិន័យជាប្រាក់ តុលាការអាចប្រកាស តែទោសពិន័យជាប្រាក់ប៉ុណ្ណោះ មិនអាចបន្ថែមទោសដាក់ពន្ធនាគារបានទេ។

- ចំពោះបទល្មើសដែលមានទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផង តុលាការអាចប្រកាស ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬទោសដាក់ពន្ធនាគារតែមួយមុខតែប៉ុណ្ណោះ ឬទោសពិន័យជាប្រាក់ តែមួយមុខតែប៉ុណ្ណោះ ដោយយោងទៅតាមក្រមព្រហ្មទណ្ឌបានកំណត់។[14]

#### ១.២.១ ការប្រកាសមូលទោសនៅលើរូបវន្តបុគ្គលជានីតិជន

ការប្រកាសទោសសម្រាប់រូបវន្តបុគ្គលដែលជានីតិជន មានចែងយ៉ាងច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌ នៅក្នុងមូលទោស មានប្រភេទទោសចំនួន២ធំៗ គឺទោសដាក់ពន្ធនាគារ ឬទោសដាក់គុក និងទោសដែលពិន័យជាប្រាក់។[15] ដោយឡែកសម្រាប់បទប្បញ្ញត្តិថ្មីនៃក្រមព្រហ្មទណ្ឌ ករណីខ្លះច្បាប់បានធ្វើការចែងកំណត់នៃការផ្តន្ទាទោសនូវបទល្មើសមួយ ដោយដាក់ពន្ធនាគារពីចំនួនប៉ុណ្ណោះទៅចំនួនត្រឹមប៉ុណ្ណោះ ហើយនឹងពិន័យជាប្រាក់ចាប់ពីចំនួនត្រឹមប៉ុណ្ណោះទៅដល់ចំនួនប៉ុណ្ណោះ។ ពុំមែនតែក្រមព្រហ្មទណ្ឌទេ នៅមានបទប្បញ្ញត្តិដទៃផ្សេងទៀតដែលបានចែងដូចគ្នា គឺភាគច្រើនមានការចែងអំពីទោសដាក់ពន្ធនាគាររួចហើយ ក៏បានចែងអំពីទោសពិន័យជាប្រាក់ថែមទៀតផង។ ប៉ុន្តែរាប់ចាប់តាំងអំពីក្រមព្រហ្មទណ្ឌនេះបានចូលធរមានមក និងយកមកអនុវត្តបានហើយ

---

[13] មាត្រា៣នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[14] មាត្រា៩៧នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[15] មាត្រា៩៧នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

នោះ ជាពិសេសគឺបទប្បញ្ញត្តិនៃគន្លីទី១ បានចែងអំពីគោលការណ៍ទូទៅមួយ ដែលគ្របដណ្តប់ទៅលើគ្រប់បទល្មើសព្រហ្មទណ្ឌ គ្រប់ទោសព្រហ្មទណ្ឌទាំងអស់ទាក់ទងជាមួយនឹងមូលទោសនេះ។ លើសពីនេះទៅទៀតនោះ គឺក្រមព្រហ្មទណ្ឌបានធ្វើការចែងអំពីរបបនៃការប្រកាសទោស ថាតើចៅក្រមអាចប្រកាសមូលទោសដោយរបៀបដូចម្តេចទៅ? បើយោងទៅតាមក្រមព្រហ្មទណ្ឌបានចែង ស្តីពីរបបនៃការប្រកាសមូលទោសនោះ គឺបានចែងកំណត់ថា ប្រសិនបើបទល្មើសមួយមានចែងផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង។

ដូច្នេះ ចៅក្រមគាត់មានសិទ្ធិអំណាចធ្វើការជ្រើសរើសក្នុងការកំណត់អំពីទោសមានដូចតទៅនេះ៖

**ចំណុចទី១៖** ចៅក្រមអាចប្រកាសទោសទាំងពីរចូលជាមួយគ្នាបាន គឺមានន័យថា ទាំងទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផង។

**ចំណុចទី២៖** ចៅក្រមអាចប្រកាសត្រឹមតែទោសដាក់គុកទេ បានសេចក្តីថា ចៅក្រមអត់ប្រកាសនូវទោសពិន័យជាប្រាក់ទេ។

**ចំណុចទី៣៖** ជម្រើសមួយទៀតនោះ គឺចៅក្រមអាចប្រកាសត្រឹមតែទោសពិន័យជាប្រាក់ ស្មើនឹងមិនប្រកាសនូវទោសជាប់គុកក៏បានដែរ។

ហើយនូវត្រង់ពាក្យថាឈ្នាប់ "និង" ពាក្យថា "និង" ចំណុចទីនេះ គឺមានចែងនៅគ្រប់បទប្បញ្ញត្តិនៃមាត្រាជាបន្តបន្ទាប់ ក្នុងក្រមព្រហ្មទណ្ឌ ក៏ដូចជាអត្ថបទច្បាប់ដទៃផ្សេងទៀត គឺថាលែងចងជាកាតព្វកិច្ចចំពោះចៅក្រមទៀតហើយ បានសេចក្តីថា ចៅក្រមមានសិទ្ធិអំណាចនៅក្នុងការជ្រើសរើសទៅតាមគោលការណ៍ឯកត្តកម្មនៃទោសនេះថា តើគួរប្រកាសទោសរបៀបយ៉ាងដូចម្តេចទៅ? ចៅក្រមអាចយកទោសទាំងពីរទៅបញ្ចូលគ្នាតែម្តងដើម្បីផ្តន្ទាទោសក្នុងពេលតែមួយ ឬមួយក៏សម្រេចជ្រើសរើសយកត្រឹមតែទោសគុក ឬក៏ទោសពិន័យជាប្រាក់យកមកអនុវត្ត។

យោងទៅតាមក្រមព្រហ្មទណ្ឌ ដែលចែងអំពីគោលការណ៍ឯកត្តកម្មនៃទោស ប៉ុន្តែគោលការណ៍នេះអាចអនុវត្តទៅបាននៅក្នុងលក្ខខណ្ឌ ដែលពុំមានបទប្បញ្ញត្តិពិសេស ដែលចែងផ្ទុយជាមួយបដិប្បញ្ញត្តិទៅនឹងគោលការណ៍នេះ គឺមានន័យថា មានអត្ថបទផ្សេងទៀតដែលចែងជាបដិប្បញ្ញត្តិថា កាលណាច្បាប់បានចែងផ្តន្ទាទោសដាក់គុកផង និងពិន័យជាប្រាក់ផងនោះ ចៅក្រមត្រូវតែប្រកាសទោសទាំងពីរព្រមគ្នាតែម្តង។ ដូចនេះ គឺអាចមានបទប្បញ្ញត្តិពិសេសចែងអំពីស្ថានភាពនេះ ច្បាស់លាស់មែន ដូច្នេះហើយ ចៅក្រមត្រូវតែអនុវត្តទៅតាមបទប្បញ្ញត្តិពិសេសនោះ។[16] ប៉ុន្តែបើពុំដូច្នោះទេ ចៅក្រមត្រូវអនុវត្តនូវរបបរួមដូចមានចែងក្នុងមាត្រា៩៧នេះគឺសុទ្ធទាក់ទងនឹងការប្រកាសមូលទោស។

### ១.២.២ ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជាអនីតិជន

[16] មាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុទៅតាមច្បាប់កំណត់ ឬមួយជនដែលមានអាយុក្រោម១៨ឆ្នាំ។ ម្យ៉ាងទៀត អនីតិជនគឺជាជនដែលច្បាប់មិនទាន់ឲ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ឬជាជនដែលច្បាប់កំណត់ឲ្យទទួលខុសត្រូវនូវលើអំពើរបស់ខ្លួនដោយមានកម្រិត។ ចំពោះអនីតិជនដែលច្បាប់តម្រូវឲ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន តាមរយៈការប្រកាសទោសដោយកំណត់កម្រិតអាយុតាមរបៀបពីរយ៉ាងៈ

**ក.ចំពោះអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ**

ជាទូទៅអនីតិជន ដែលមានអាយុក្រោម១៤ឆ្នាំ ច្បាប់មិនតម្រូវឲ្យទទួលខុសត្រូវពីបទព្រហ្មទណ្ឌនោះទេ គឺមានន័យថា តុលាការមិនអាចសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុក្រោម១៤បានឡើយ សូម្បីតែការចោទប្រកាន់ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ក៏មិនអាចចោទប្រកាន់ទៅលើអនីតិជន ដែលមានអាយុក្រោម១៤ឆ្នាំបានដែរ ជាទូទៅចៅក្រមមិនអាចចោទប្រកាន់បានទេ។ ក៏ប៉ុន្តែ អាចមានករណីពិសេសខ្លះ ដែលចៅក្រមអាចចោទបាន គឺករណីពិសេស ដែលអនីតិជនក្រោមអាយុ១៤ឆ្នាំបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ។

**ខ. ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ**

ចំពោះអនីតិជនដែលមានអាយុចាប់ពីឆ្នាំ១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ គឺច្បាប់បានទុកលទ្ធភាពឲ្យចៅក្រមធ្វើការពិនិត្យទៅលើជម្រើសដែលមាន២ចំណុចជាវិធានការៈ

**ចំណុចទី១ៈ** ចៅក្រមមិនប្រកាសអំពីទោសព្រហ្មទណ្ឌទេ គឺបានសេចក្តីថា ចៅក្រមមិនប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ទេ ប៉ុន្តែចៅក្រមអាចប្រើប្រាស់វិធានដាក់ឲ្យស្ថិតនៅក្រោមសកម្មភាពតាមដានវិធានការអប់រំ វិធានការការពារ ឬវិធានការឧបត្ថម្ភជាដើមមកជំនួសវិញ។

**ចំណុចទី២ៈ** ប្រសិនបើចៅក្រមបានពិនិត្យមើលឃើញយ៉ាងច្បាស់លាស់អំពីកាលៈទេសៈនៃបទល្មើសហើយនិងបុគ្គលិកលក្ខណៈរបស់ជនល្មើសដែលជាអនីតិជននោះ តម្រូវច្បាប់បើកសិទ្ធិឲ្យតុលាការ អាចប្រកាសអំពីទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជននោះបានផងដែរ ចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ។ ប៉ុន្តែប្រសិនបើតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌចំពោះអនីតិជន ដោយយោងតាម កាលៈទេសៈ បុគ្គលិកលក្ខណៈរបស់ជននោះ គឺតុលាការត្រូវតែអនុវត្តនូវមូលទោសដែលមានចែងនៅក្នុងបទប្បញ្ញត្តិទៅតាមក្រមព្រហ្មទណ្ឌ ព្រោះបានចែងអំពីមូលទោសមួយសម្រាប់តែអនីតិជននោះប៉ុណ្ណោះ។[17]

**ឧទាហរណ៍** អនីតិជនដែលមានអាយុ១៦ឆ្នាំ គាត់បានធ្វើការប្រព្រឹត្តបទល្មើសមួយ ដែលវាមានលក្ខណៈសាហាវព្រៃផ្សៃណាស់ បានរំលោភសេពសន្ថវៈនិងសម្លាប់នារីនោះចោលទៀតផង។ ដូច្នេះ បទល្មើសមួយនេះ វាគឺកាចសាហាវជាពន់ពេក ទើបតម្រូវឲ្យតុលាការមិនអាចប្រើវិធានការតាមដាន អប់រំ ការពារ និងការឧបត្ថម្ភនោះទេ ជម្រើសដ៏ត្រឹមត្រូវ គឺតុលាការត្រូវតែដាក់ទោសព្រហ្មទណ្ឌតែម្តង។

[17] មាត្រា១៦០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

តែទោះបីយ៉ាងណាក៏ដោយ ទោសដែលត្រូវដាក់សម្រាប់អនីតិជន យោងទៅតាមក្រមព្រហ្មទណ្ឌថ្មីឆ្នាំ ២០០៩ ត្រូវដាក់ចំពោះអតិបរិមានៃដាក់ពន្ធនាគារគឺត្រូវបានសម្រាលពាក់កណ្ដាល។ តែបើអតិបរិមានៃទោសដាក់ពន្ធនាគារ ជាអតិបរិមានៃទោសដាក់ពន្ធនាគារអស់មួយជីវិត គឺសម្រាលដោយត្រូវបន្ថយមកត្រឹមតែ២០ឆ្នាំតែប៉ុណ្ណោះសម្រាប់អតិបរិមា។ ចំណែកឯ អប្បបរមានៃទោសដាក់ពន្ធនាគារវិញ ក៏ត្រូវតែសម្រាលពាក់កណ្ដាលដូចទោសទណ្ឌផ្សេងទៀតផងដែរ។ ហើយចំពោះ ទោសពិន័យជាប្រាក់វិញក៏ដូចគ្នាទៅនឹងទោសដាក់ពន្ធនាគារដែរ គឺអប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់នោះ ក៏ត្រូវបន្ថយពាក់កណ្ដាលមកផងដែរ។

## ១.៣ ទោសបន្ថែម

ទោសបន្ថែម គឺជាអនុទោស ឬជាទោសបន្ទាប់បន្សំ។[18] ហើយអនុទោស ឬ ទោសបន្ថែម គឺជាទោសដែលតុលាការប្រកាសបន្ថែមទៅលើមូលទោស។

ទោសបន្ថែម គឺសំដៅដល់ប្រភេទទោសមួយ ដែលបន្ថែមទៅលើមូលទោស បានសេចក្ដីថា ពេលដែលចៅក្រមគាត់ប្រកាសអំពីមូលទោស ហើយករណីលក្ខខណ្ឌច្បាប់ចែងកំណត់ថា អនុញ្ញាតឲ្យមានការផ្ដន្ទាទោសបន្ថែមទៀតនោះ ចៅក្រមអាចសម្រេចទោសបន្ថែមនេះ ដើម្បីបន្ថែមទៅលើមូលទោសនោះទៀតបាន។

### ១.៣.១ ប្រភេទនៃទោសបន្ថែម ១៩ ចំណុចក្នុងក្រមព្រហ្មទណ្ឌ

១. ការដកសិទ្ធិខ្លះៗជាពលរដ្ឋ

អំពីសិទ្ធិ ពលរដ្ឋដែលអាចដកបានថាៈសិទ្ធិពលរដ្ឋដែលអាចដកបានដូចមានចែងក្នុងចំណុច១ នៃមាត្រា៥៣(ប្រភេទនៃទោសបន្ថែម)នៃក្រមនេះរួមមាន:[19]

- សិទ្ធិបោះឆ្នោត។
- សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត។
- សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ
- សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្ដាល ជាអាណត្តិគាហករបស់តុលាការ។
- សិទ្ធិទទួលបាន និងពាក់គ្រឿងឥស្សរិយយសទាំងអស់។
- សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ។

ទោសនេះអាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំ យ៉ាងច្រើន។

២. ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ

[18] សន្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី៥០។
[19] មាត្រា៥៥នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

សំដៅដល់ការហាមឃាត់ ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះ បានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ។ ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ នៃក្រមព្រហ្មទណ្ឌបានចែងថា៖ ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ មិនអនុវត្តទៅលើការបំពេញអាណត្តិ ដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ឬការទទួលខុសត្រូវខាងសហជីពទេ។ ការហាមឃាត់នេះ មិនអាចអនុវត្តចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មានទេ។[20]

ទោសនេះអាចជាទោសស្ថាពរ ឬក៏ជាទោសបណ្តោះអាសន្ន សម្រាប់រយៈពេល៥(ប្រាំ )ឆ្នាំយ៉ាងច្រើន។ តុលាការត្រូវបញ្ជាក់មុខរបរដែលត្រូវហាមឃាត់។

៣. ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ តាមបញ្ញត្តិមាត្រា៥៧នៃក្រមព្រហ្មទណ្ឌបានចែងថា៖ ការហាមឃាត់ចំពោះការបើកបរយានយន្ត មិនត្រូវលើសពី៥(ប្រាំ)ឆ្នាំទេ។[21]

៤. ការព្យួរលិខិតបើកបរ

ទោសព្យួរលិខិតបើកបរ មិនត្រូវលើសពី៥(ប្រាំ)ឆ្នាំទេ។[22] ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនឲ្យទៅក្រឡាបញ្ជីតុលាការ លិខិតបើកបរត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

៥. ការហាមឃាត់ចំពោះការស្នាក់នៅ

ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិត ចំពោះការមានមុខនៅទីកន្លែងខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[23] ទោសនេះមិនអាចលើសពី១០(ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង៥ (ឆ្នាំ) ចំពោះបទមជ្ឈឹម។

តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់ និងកំណត់ចិរវេលានៃការហាមឃាត់។ ការហាមឃាត់ការស្នាក់នៅ រួមមានវិធានការតាមដាន។ ទណ្ឌិតត្រូវតែ:

- ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលដែលតុលាការបានចាត់តាំង។
- ចូលបង្ហាញខ្លួនឱ្យ បានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ។ តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន។

សេចក្តីសម្រេចរបស់តុលាការ ត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។

[20] មាត្រា៥៦នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។

[21] មាត្រា៥៧នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។

[22] មាត្រា៥៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[23] មាត្រា៥៩នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

៦. ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៃក្រមព្រហ្មទណ្ឌបានចែងថា៖ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាមិនត្រូវលើសពី៥ឆ្នាំ។[24]

ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ ដែលលិខិតឆ្លងដែននេះត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេក្នុងរយៈពេលដែលកំពុងទទួលទោសនោះ។

៧. ការហាមឃាត់ការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាអាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន ការហាមឃាត់នេះ នាំឲ្យមានការបណ្តេញទណ្ឌិតឲ្យចេញដោយច្បាប់នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ។[25]

៨. ការរឹបអូសឧបករណ៍ សម្ភារ ឬវត្ថុដែលប្រើប្រាស់

ការរឹបអូសឧបករណ៍ សម្ភារ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬឧប្បករណ៍ទុកសម្រាប់ប្រព្រឹត្តបទល្មើស តាមក្រមព្រហ្មទណ្ឌបានចែងថា៖ ការរឹបអូសអាចធ្វើទៅលើវត្ថុដូចតទៅ:[26]

- ឧបករណ៍ សម្ភារ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តិបទល្មើស។
- វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។
- ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។
- ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។
- ប៉ុន្តែការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិនជន។

៩. ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស

ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស កាលបើការរឹបអូសបានក្លាយទៅជាស្ថាពរ ទ្រព្យសម្បត្តិរឹបអូសក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ លើកលើតែមានបទប្បញ្ញត្តិដោយឡែកដែលចែងអំពីការប្រគល់ផ្សេងពីនេះ។[27]

រដ្ឋអាចលក់ ឬ បំផ្លាញទ្រព្យរឹបអូស តាមនីតិវិធីស្តីពីការលក់ទ្រព្យសម្បត្តិរដ្ឋ។

[24] មាត្រា៦០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[25] មាត្រា៦១នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[26] មាត្រា៦២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។

[27] មាត្រា៦៣នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។

១០. ការរឹបអូសផលទន់ ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។

១១. ការរឹបអូសឧបភោគភណ្ឌ សម្ភារ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

១២. ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

១៣. ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។[28] ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១៤. ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ

ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមក្រមព្រហ្មទណ្ឌបានចែងថា៖ ការបណ្តេញចេញពីលទ្ធកម្មសាធារណៈនាំឲ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយៈ

- រដ្ឋ។
- រដ្ឋបាលថ្នាក់ក្រោមជាតិ។
- គ្រឹះស្ថានសាធារណៈ។
- សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋ ឬ ដោយរដ្ឋបាលថ្នាក់ក្រោម។[29]

ទោសបណ្តេញចេញនេះអាចជាស្ថាពរ ឬ បណ្តោះអាសន្នសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

១៥.ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស

ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស តាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌបានចែងថា៖ ទោសបិទគ្រឹះស្ថាន នាំឲ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង។[30]

ទោសបិទគ្រឹះស្ថាននេះ អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល៥(ឆ្នាំ)ឆ្នាំយ៉ាងច្រើន។

១៦. ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន។ តាមបញ្ញត្តិមាត្រា៦៦នៃក្រមព្រហ្មទណ្ឌបានចែងថា៖ ការហាមឃាត់

---

[28] មាត្រា៦៤នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។

[29] មាត្រា៦៥នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។

[30] មាត្រា៦៦នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។

ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណៈជន ឬ ដែលប្រើប្រាស់ដោយសាធារណៈជន អាចជាស្ថាពរ ឬ បណ្ដោះអាសន្នសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំ យ៉ាងច្រើន។

១៧. ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស។ តាមបញ្ញត្តិមាត្រា៦៨នៃក្រមព្រហ្មទណ្ឌបានចែងថា៖ ទោសបិទផ្សាយសេចក្ដីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ។ ការបិទផ្សាយមិនអាចលើសពី២(ពីរ) ខែ ទេ។ ការបិទផ្សាយអាចធ្វើទាំងស្រុង ឬ តាមសម្រង់ ឬ តាមនិទ្ទេសធម្មតា ។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត។

១៨. ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន។ តាមបញ្ញត្តិមាត្រា៦៩នៃក្រមព្រហ្មទណ្ឌបានចែងថា៖ ទោសផ្សាយសេចក្ដីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសាព័ត៏មានសរសេរតាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ។

១៩. ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។ តាមបញ្ញត្តិមាត្រា៧០នៃក្រមព្រហ្មទណ្ឌបានចែងថា៖ ទោសផ្សាយជាសាធារណៈនូវសេចក្ដីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ។ ការផ្សាយនេះមិនអាចលើសពី៨(ប្រាំ)ថ្ងៃ ទេ។ ការផ្សាយអាចទាំងស្រុង តាមសម្រង់ ឬ តាមនិទ្ទេស សោហ៊ុយនៃការផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត។

**១.៣.២ ការប្រកាសទោសបន្ថែម**

ចំពោះរូបវន្តបុគ្គល ដែលជានីតិជន ឬអនីតិជន បន្ទាប់ពីបានទទួលការប្រកាសនូវមូលទោសរួចរាល់ហើយនោះ ពួកគេក៏ទទួលបាននូវការប្រកាសទោសបន្ថែមទៀតផងដែរ ប្រសិនបើច្បាប់បានចែងកំណត់ទុក។

**១.៣.៣ លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម**

ចំពោះទោសបន្ថែម វាជាសិទ្ធិរបស់ចៅក្រមក្នុងការប្រកាស ឬមិនប្រកាសទោសបន្ថែម ដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈឹម ឬបទលហុ ដែលត្រូវចោទប្រកាន់។ ទោសបន្ថែម គឺជាទោសដែលបន្ថែមលើទោសដែលមានការចោទប្រកាន់រួចហើយបានសម្រេច ។[31]

ទោសបន្ថែម នេះនឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់ លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈឹម ឬ បទលហុ ដែលត្រូវចោទប្រកាន់។

ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។

[31] មាត្រា៥៤នៃក្រមព្រហ្មទណ្ឌចុះ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។

ត្រង់ចំណុចខាងលើបានសេចក្តីថា ចំពោះទោសបន្ថែមចៅក្រមអាចយកទៅប្រកាសបាននោះ លុះត្រាតែជនល្មើសបានប្រព្រឹត្តនូវបទល្មើស ហើយបទល្មើសនោះមានការចែងកំណត់អំពីទោសបន្ថែម។ បើមិនដូច្នោះទេនោះ ចៅក្រមក៏មិនអាចធ្វើការប្រកាសនូវទោសបន្ថែមដើម្បីបន្ថែមទៅលើមូលទោសបានឡើយ។

ក៏ប៉ុន្តែប្រសិនបើច្បាប់បានចែងចងជាកាតព្វកិច្ច ថាត្រូវតែប្រកាសនោះ ពិតណាស់តុលាការមិនអាចមិនប្រកាសបាននោះទេ គឺត្រូវតែប្រកាសតែម្តង។

### ១.៣.៣.១ ការប្រកាសទោសបន្ថែមចំពោះរូបវ័ន្តបុគ្គលជានីតិជន

ការប្រកាសទោសបន្ថែមលើរូបវ័ន្តបុគ្គលជានីតិជន គឺមានចំនួន១៩ ចំណុច ដែលមានការចែងនូវក្នុងមាត្រា៥៣នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ ប៉ុន្តែមិនមែនគ្រប់ករណីទាំងអស់ទោសបន្ថែមទាំង១៩នោះ ចៅក្រមអាចជ្រើសរើសយកនូវទោសបន្ថែមមួយ ឬច្រើនលើសពីមួយក្នុងចំណោម១៩ ចំណុចនោះយកមកប្រកាសដើម្បីបន្ថែមទៅលើមូលទោសបាននោះទេ ព្រោះថាចៅក្រមដើម្បីអាចប្រកាសទោសបន្ថែមបានលុះត្រាតែទោសបន្ថែមនេះមានចែងយ៉ាងជាក់លាក់នៅក្នុងច្បាប់ នោះគឺបានន័យថា បានចែងយ៉ាងជាក់លាក់ចំពោះមាត្រាដែលផ្តន្ទាទោសចំពោះបទល្មើសហ្នឹងតែម្តង។ ប្រសិនបើមិនបានចែងយ៉ាងជាក់លាក់ទេ ចៅក្រមមិនអាចប្រកាសអំពីទោសបន្ថែមដើម្បីបន្ថែមទៅលើមូលទោសបានឡើយ។

ឧទាហរណ៍៖ ករណីមនុស្សឃាតដោយអចេតនា ច្បាប់ព្រហ្មទណ្ឌបានផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី២លានរៀល ទៅ៦លានរៀល។ ប៉ុន្តែដើម្បីចៅក្រមអាចប្រកាសអំពីទោសបន្ថែម ទៅមូលទោសបាននោះ លុះត្រាតែមានបទប្បញ្ញត្តិមួយទៀតចែងថា ចំពោះបទល្មើទាក់ទងជាមួយមនុស្សឃាតដោយអចេតនា ចៅក្រមអាចប្រកាសទោសបន្ថែមមួយឬ ច្រើនបាន។ ហើយទោសបន្ថែមនេះ មិនមានជាលក្ខណដាច់ខាត ឬតឹងតែង ត្រូវតែប្រកាសគ្រប់ទោសបន្ថែមនោះទេ គឺវាអាស្រ័យទៅលើតុលាការ ដោយផ្អែកនិងទម្ងន់នៃបទល្មើស កាលៈទេសៈនៃបទល្មើសតែប៉ុណ្ណោះ។ យោងទៅតាមមាត្រា២០៨នៃក្រមព្រហ្មទណ្ឌស្តីអំពីទោសបន្ថែមចំពោះបទមនុស្សឃាតដោយអចេតនា គឺមានចំនួន៧ចំណុចរួមមាន៖

១. ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន។

២. ការហាមឃាត់ចំពោះការបើកបរយានយន្តទោះបីជាប្រភេទណាក៏ដោយ សម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៣. ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៤. ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ សម្រាប់រយៈពេល៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៥. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល២ (ពីរ) ខែ យ៉ាងច្រើន។

៦. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

៧. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល៨(ប្រាំបី) ថ្ងៃ យ៉ាងច្រើន។

ដូច្នេះហើយ នូវពេលដែលច្បាប់បានកំណត់បញ្ញត្តិជាក់លាក់ ចៅក្រមអាចប្រកាសទោសបន្ថែម មួយ ឬច្រើន ដើម្បីយកទៅអនុវត្តលើមូលទោសបាន។

### ១.៣.៣.២ ការប្រកាសទោសបន្ថែមចំពោះរូបវ័ន្តបុគ្គលជាអនីតិជន

ក្រៅពីទោសបន្ថែម ដែលត្រូវប្រកាសទៅលើរូបវន្តបុគ្គលជានីតិជន មានចំនួន១៩ចំណុចនោះ ក្រមព្រហ្មទណ្ឌបានបញ្ញត្តិនៅក្នុងមាត្រា១៦១ បានចែងស្តីអំពីទោសបន្ថែម ដើម្បីយកទៅប្រកាសទៅលើរូបវន្តបុគ្គលដែលអនីតិជន។ ហើយចំពោះការប្រកាសទោសបន្ថែមទៅរូបវន្តបុគ្គលជាអនីតិជន គឺត្រូវបានបែងចែកជាពីរ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ និង អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ ១៨ ឆ្នាំ ។

#### ក. ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ

នៅក្នុងក្រមព្រហ្មទណ្ឌចំពោះអនីតិជន ដែលមានអាយុក្រោម ១៤ ឆ្នាំ ច្បាប់ ពុំបានចែងកំណត់អំពីទោសបន្ថែមទេ ព្រមទាំងមូលទោស គឺបានសេចក្តីថា ទាំងមូលទោស និងទោសបន្ថែម សម្រាប់យកទៅអនុវត្តលើអនីតិជនដែលមានអាយុក្រោម១៤ ឆ្នាំនោះ ព្រោះថា ទោសបន្ថែម គឺជាទោសបន្ថែមទៅលើមូលទោស ផ្ទុយទៅវិញ ប្រសិនបើគ្មានការប្រកាសមូលទោសទេ នោះស្មើនិង គ្មានការប្រកាសទោសបន្ថែមដូចគ្នាដែរ។ ដូច្នេះហើយ អនីតិជនប្រភេទនេះ ត្រូវបានរួចផុតពីការទទួលខុសត្រូវ។

#### ខ. ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់អាយុ១៨ឆ្នាំ

អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់អាយុ១៨ឆ្នាំ ជាទូទៅច្បាប់ពុំបានចែងកំណត់អំពីការទទួលខុសត្រូវឡើយនូវអំពើរបស់ខ្លួន តែទោះបីជាយ៉ាងណាក៏ដោយ តុលាការក៏មានសិទ្ធិ ឬប្រើវិធីសាស្ត្រក្នុងការប្រកាសទោសបន្ថែមសម្រាប់អនុវត្តដូចទៅនឹងបុគ្គលជានីតិជនផងដែរ។ ប៉ុន្តែសម្រាប់ទោសបន្ថែមចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំដល់១៨ឆ្នាំនោះ យោងតាមមាត្រា១៦១នៃក្រមព្រហ្មទណ្ឌ ទោសបន្ថែម គឺមាន (ចំនួន )ត្រឹមតែ៥ប៉ុណ្ណោះក្នុងនោះរួមមាន៖

១. ការរឹបអូសឧបករណ៍ សម្ភារ ឬវត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

២. ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣. ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលផលកើតចេញពីបទល្មើស។

៤. ការរឹបអូសឧបភោគភណ្ឌ សម្ភារ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។

៥. ការហាមឃាត់ចំពោះការកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវ គ្រប់ប្រភេទ។

## ១.៤ ទោសជំនួស

ទោសជំនួស គឺមានន័យថា ជាទោសដែលតុលាការអាចយកទៅប្រើប្រាស់ដើម្បីប្រកាស ជំនួសឱ្យនូវមូលទោស។ ន័យម្យ៉ាងទៀត ទោសជំនួស គឺជាទោសការងារសហគមន៍ ឬការស្តីបន្ទោសដែលត្រូវបានកំណត់ជាជំនួសទោសដាក់ពន្ធនាគារ។[32]

### ១.៤.១ ប្រភេទនៃទោសជំនួស

យោងតាមបទប្បញ្ញត្តិចាប់ពីមាត្រា៧២ ដល់មាត្រា៧៦នៃក្រមព្រហ្មទណ្ឌ ទោសជំនួសមានចំនួនពីរប្រភេទ ពោលគឺ ទោសការងារសហគមន៍ និងទោសការស្តីបន្ទោស។

#### ១.៤.១.១ ទោសការងារសហគមន៍

ទោសការងារសហគមន៍ជាទូទៅតុលាការតែងតែយកទៅអនុវត្តលើទណ្ឌិតក្នុងទិសដៅដើម្បីបម្រើផលប្រយោជន៍ដល់ឲ្យសមស្របទៅនិងបទល្មើសដែលខ្លួនបានប្រព្រឹត្ត ហើយជាការឆ្លើយតបទៅនិងសង្គម។

##### ក. និយមន័យនៃការងារសហគមន៍

ទោសការងារសហគមន៍ គឺជាទោសមួយប្រភេទ ដែលតម្រូវឲ្យតម្រូវទណ្ឌិតបំពេញការងារក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬ ដល់អង្គការមិនមែនរដ្ឋាភិបាល។[33]

ចំពោះការងារសហគមន៍ផងនេះដែរ គឺតុលាការអាចធ្វើការប្រកាសទោសការងារសហគមន៍បាន កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ ។

##### ខ. របបគតិយុត្តនៃការងារសហគមន៍

គតិយុត្ត គឺតាមគន្លងច្បាប់ ដែលទាក់ទងនឹងច្បាប់ ដែលត្រឹមត្រូវ។ ការងារសហគមន៍ អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ។ ការងារសហគមន៍ គឺត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ការងារជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ និងការងាររបស់ស្ត្រី។ តែភាគច្រើនគឺមិនសូវប្រើចំពោះការងារ

[32] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ

[33] មាត្រា៧២នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

កុមារនោះទេ ព្រោះកុមារ ឬអនីតិជនដែលមានអាយុពី ១៤(ដប់បួន) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ ច្រើនតែប្រើប្រាស់នូវយន្តការថ្មីស្ដីពី "ការស្ដីបន្ទោស" ទៅវិញទេ។[34]

**គ. អ្នកមិនទទួលផលប្រយោជន៍នៃការងារសហគមន៍**

ជាទូទៅការងារសហគមន៍ គឺមិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលបានទេ ព្រោះថានេះជាផលប្រយោជន៍របស់ឯកជនសុទ្ធសាធ គឺមិនមែនជាផលប្រយោជន៍របស់សាធារណៈទេ។

ដោយសារតែពេលខ្លះបុគ្គលឯកជនបានយកជនដែលធ្វើការងារនេះទៅបម្រើផលប្រយោជន៍ឲ្យខ្លួនឯងផ្ទាល់។ ដូច្នេះហើយ ទើបបានច្បាប់ហាមឃាត់កុំឲ្យមានករណីនេះកើតឡើងបន្តទៅទៀត។

**ឃ. គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ**

រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដល់អ្នកដទៃ ដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍។ រដ្ឋត្រូវតែធ្វើឧបាទេសកម្មដោយពេញច្បាប់ទៅក្នុងសិទ្ធិជនរងគ្រោះ។

ត្រង់ចំណុចនេះបានសេចក្ដីថា ជួនជាពេលខ្លះទណ្ឌិតដែលទទួលរងនូវការងារសហគមន៍នេះ គឺគ្មានថវិកាបង់ខ្លួនឯងទេ។ ផ្ទុយទៅវិញ បើរដ្ឋមិនចេញសំណងឲ្យនោះទេ ជនរងគ្រោះនឹងមិនទទួលបានការជួសជុលនូវព្យសនកម្ម ឬការខូចខាតឡើយ ជាហេតុនាំឲ្យមានភាពអយុត្តិធម៌ចំពោះជនរងគ្រោះដែលជាពលរដ្ឋរបស់ខ្លួនជាក់ជាមិនខានឡើយ។

ពាក្យថា ឧបាទេសកម្ម គឺជាឋានៈមួយដែលបុគ្គលម្នាក់ទទួលជំនួសនូវបុគ្គលណាមួយទៅតាមច្បាប់។ ដូច្នេះ រដ្ឋក្លាយទៅជាម្ចាស់បំណុលដើម្បីប្ដឹងទារសំណង ពីទណ្ឌិតនោះវិញ ក៏ប៉ុន្តែ បើជននោះគ្មានថវិកាបង់សងជូនរដ្ឋទាល់តែសោះ ហេតុនេះ ថវិកាដែលរដ្ឋចេញសងនោះ អត់ទទួលបានត្រឡប់មករដ្ឋវិញទេ ពីព្រោះទណ្ឌិតគ្មានថវិកាសងរដ្ឋឡើយ។

**១.៤.១.២ ទោសស្ដីបន្ទោស**

ទោសស្ដីបន្ទោស គឺជាយន្តការថ្មីដែលតុលាការ បានធ្វើការអនុវត្ត ទៅលើទណ្ឌិតទាំងឡាយណា ដែលបានប្រព្រឹត្តល្មើស ស្រាលៗ តាមរយៈការស្ដីបន្ទោស ការព្រមាន នូវកំហុសខុសឆ្គងដែលខ្លួនបានប្រព្រឹត្ត។

**ក. អត្ថន័យនៃទោសស្ដីបន្ទោស**

ចំពោះទោសស្ដីបន្ទោស គឺជាប្រភេទទោសមួយដែលក្នុងនោះ គឺជាទោសដែលប្រើប្រាស់សម្រាប់បទល្មើសស្រាល ហើយចៅក្រម គាត់មិនសម្រេចដាក់ពន្ធនាគារ ឬពិន័យជាប្រាក់អ្វីនោះទេ ប៉ុន្តែចៅក្រម គាត់អាចប្រកាសទោសនេះបាន ព្រោះទោសស្ដីបន្ទោស គឺព្រមាន ការប្រដៅអំពីទោស កំហុសខុសឆ្គងដែលទណ្ឌិតបានប្រព្រឹត្ត ហើយជាការព្រមានថា កុំឲ្យគាត់ប្រព្រឹត្តបទល្មើសតទៅទៀត។ ម៉្យាងវិញទៀត ទោសស្ដីបន្ទោស គឺភាគ

[34] មាត្រា៧៨នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ច្រើនប្រើចំពោះកុមារ ឬអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅដល់ក្រោម ១៨ ឆ្នាំ ។ តុលាការអាចប្រើប្រាស់នូវយន្តការថ្មីមួយនេះបាន បានសេចក្តីថា ប្រើការស្តីបន្ទោសទៅលើទណ្ឌិតតែម្តង គឺល្អប្រសើរណាស់ ។ ប៉ុន្តែចៅក្រមនឹងប្រាប់ថា ថ្ងៃក្រោយ គ្មានការអនុគ្រោះណាមួយទៀតទេ ប្រសិនបើនូវតែប្រព្រឹត្តអំពើបែបនេះទៅទៀត។[35]

**ខ. របបគតិយុត្តនៃការស្តីបន្ទោស**

យោងតាមបញ្ញត្តិនៃមាត្រា៧៦នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩បានចែងថា កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬ ស្មើនឹង ៣(បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌ ទាំងបីដូចតទៅនេះ៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់។
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**១.៤.២ ការប្រកាសទោសជំនួស**

យើងបានដឹងមកហើយថា ប្រភេទនៃទោសជំនួសគឺមានចំនួន២ប្រការ

**ប្រការ១ ទោសការងារសហគមន៍**

**ប្រការ២ ទោសស្តីបន្ទោស**

ចំពោះការប្រកាសទោសជំនួសនេះ គឺតម្រូវឲ្យប្រកាសទៅលើរូបវន្តបុគ្គលដែលជា នីតិជន និងរូបវន្តបុគ្គលដែលអនីតិជន ដែលសមស្របទៅនិងលក្ខខណ្ឌនៃក្រមព្រហ្មទណ្ឌ។

**១.៤.២.១ ការប្រកាសទោសការងារសហគមន៍**

សម្រាប់ទោសការងារសហគមន៍ ជាប្រភេទនៃទោស ដែលតម្រូវឲ្យទណ្ឌិតដែលបានប្រព្រឹត្តបទល្មើសនោះ គឺត្រូវតែបំពេញកាតព្វកិច្ច ជាប្រយោជន៍ដល់សាធារណៈ ដោយមិនគិតជាកម្រៃឡើយ ប៉ុន្តែដើម្បីឈានទៅដល់ការប្រកាសទោសនោះ ចាំបាច់ត្រូវតែទណ្ឌិតបានបំពេញនូវលក្ខខណ្ឌជាមុនសិន ដោយផ្អែកទៅតាមក្រមព្រហ្មទណ្ឌ។

**ក.លក្ខខណ្ឌនៃការប្រកាសទោសការងារសហគមន៍**

លក្ខខណ្ឌមួយចំនួនដែលតុលាការអាចធ្វើការប្រកាសទោសការងារសហគមន៍ទៅលើទណ្ឌិតបាននោះរួមមាន៖

[35] យោងតាមប្រសាសន៍ ឯកឧត្តម គើន រិទ្ធ

- កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរិមាតិចជាង ឬស្មើនឹង៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍។
- លុះត្រាតែជនជាប់ចោទ មានវត្តនៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ។

**ខ.ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជានីតិជន**

ចំពោះទោសការងារសហគមន៍ គឺជាប្រភេទមួយដែលតម្រូវឲ្យទណ្ឌិត បំពេញកាតព្វកិច្ច ជាប្រយោជន៍រួម ដោយមិនគិតជាកម្រៃទេ ក៏ប៉ុន្តែជាប្រយោជន៍ដល់សាធារណៈទូទៅនៅក្នុងសង្គម។ ហើយទោសនេះអាចអនុវត្តទៅបាន គឺអាស្រ័យទៅតាមលក្ខខណ្ឌដូចមានចែងនៅក្នុងបទប្បញ្ញត្តិចាប់ពីមាត្រា៧២ ដល់មាត្រា៧៤ ក៏ដូចជាមាត្រា៩៨ និងចាប់ពីមាត្រា១០១ ទៅដល់មាត្រា១០៣នៃក្រមព្រហ្មទណ្ឌផងដែរ។ ហើយមាត្រា៧២នៃក្រមព្រហ្មទណ្ឌ បានផ្តល់ជាលក្ខខណ្ឌរួមថា កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង និងស្មើ(៣)ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍បាន គឺបានសេចក្តីថា លក្ខខណ្ឌនេះ បើប្រើជាមួយនិងបទល្មើសធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសលើសពី ៣ឆ្នាំ គឺមិនអាចប្រើទោសការងារសហគមន៍បានឡើយ។ ផ្ទុយទៅវិញ បើសិនជាផ្តន្ទាទោសដាក់ពន្ធនាគារដែលអតិបរមានោះតិចជាង ឬស្មើនិង ៣ឆ្នាំ ទើបតុលាការអាចប្រកាសទោសការងារសហគមន៍នេះបាន។ ចំពោះលក្ខខណ្ឌច្បាប់នេះបានចែងថា ទោសការងារសហគមន៍នឹងប្រកាសទៅបានលុះត្រាតែតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយគាត់យល់ព្រមទទួលយកការងារសហគមន៍នេះ។ ដោយមិនមានការបង្ខិតបង្ខំទៅលើទណ្ឌិតឡើយ។

**គ.ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជាអនីតិជន**

ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជាអនីតិជន គឺសំដៅទៅលើតែអនីតិជនដែលមានអាយុយ៉ាងតិចជាង១៦ឆ្នាំ ដល់ក្រោមអាយុ១៨ឆ្នាំ តែប៉ុណ្ណោះទើបទទួលបាននូវការប្រកាសទោសការងារសហគមន៍។

ដោយឡែក អនីតិជនដែលមានអាយុក្រោម១៦ឆ្នាំវិញ គឺពុំបានទទួលការប្រកាសទោសការងារសហគមន៍នេះឡើយ។

**១.អនីតិជនដែលមានអាយុក្រោម ១៦ ឆ្នាំ**

អនីតិជនប្រភេទនេះ មិនត្រឹមតែមូលទោស និងទោសបន្ថែមទេ ដែលតុលាការមិនត្រូវបានប្រកាសចំពោះអនីតិជនដែលមានអាយុក្រោម ១៦ ឆ្នាំ ដោយហើចទៅសូម្បីតែ ទោសការងារសហគមន៍ ក៏ក្រមព្រហ្មទណ្ឌមិនបានបើកសិទ្ធិអំណាចឲ្យចៅក្រមធ្វើការជំនុំជម្រះធ្វើការប្រកាសទោស ទៅលើអនីតិជនដែលមានអាយុក្រោម១៦ ឆ្នាំបានដូចគ្នា។

**២.អនីតិជនដែលមានអាយុយ៉ាងតិច១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ**

តាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌនៃមាត្រា១៦២បានធ្វើការចែងថា៖ ទោសការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦(ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែថិរពេលវេលានៃការងារសហគមន៍មិនអាចលើពី ១០០(មួយរយ)ម៉ោង។

ត្រង់ចំណុចនេះបានសេចក្តីថា ថិរវេលានៃទោសការងារសហគមន៍ចំពោះអនីតិជនដែលមានអាយុចាប់ពី១៦ ឆ្នាំក្រោមដល់ ១៨ឆ្នាំ ច្បាប់កំណត់ត្រឹមពាក់កណ្តាលនៃថិរវេលារបស់នីតិជន ដូច្នេះហើយពាក់កណ្តាលនៃ ២០០ ម៉ោង ស្មើ១០០ ម៉ោង។

មួយវិញទៀត ត្រូវជ្រើសរើសការងារមួយដែលសមស្របសម្រាប់អនីតិជននោះ ពិសេសគឺស្ថានភាពរបស់អនីតិជនដែលទាក់ទងនឹងការបណ្តុះបណ្តាល និងស្ថានភាពដែលអនុញ្ញាតឲ្យកែសម្រួលអនីតិជនដោយកែប្រែ អប់រំ រៀនសូត្រ អនីតិជននោះ ឲ្យចូលមករស់នៅក្នុងសង្គមវិញបាន។

### ១.៤.២.២ ការប្រកាសទោសស្ថិតបន្ទោស

ទោសស្តីបន្ទោស គឺជាទោសដែលមានលក្ខណស្រាល សម្រាប់ដាក់ទៅលើទណ្ឌិត ដែលបានប្រព្រឹត្តបទល្មើសមិនធ្ងន់ធ្ងរ ដែលជំនួសឲ្យនូវមូលទោស ឬមកវិញត្រឹមតែស្តីបន្ទោសតែប៉ុណ្ណោះ។

#### ក. លក្ខខណ្ឌនៃការប្រកាសទោសស្តីបន្ទោស

ទោសស្តីបន្ទោស តុលាការអាចធ្វើការប្រកាសទៅបាននោះ លុះត្រាតែជនជាប់ចោទដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ៖[36]

**លក្ខខណ្ឌទី១៖** ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់

**លក្ខខណ្ឌទី២៖** ការខូចខាតត្រូវបានជួសជុលរួចហើយ និង

**លក្ខខណ្ឌទី៣៖** ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។

#### ខ. ការប្រកាសទោសស្តីបន្ទោសចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ

ទោសដែលអាចអនុវត្តចំពោះអនីតិជនមានចែងចាប់ពីមាត្រា១៦០ ទៅដល់មាត្រា១៦៦ ឃើញមានតែមូលទោស ទោសបន្ថែម និងទោសជំនួសក្នុងប្រភេទទោសការងារសហគមន៍តែប៉ុណ្ណោះ។[37] ដោយមើលមិនឃើញចែងអំពីទោសជំនួសក្នុងប្រភេទជាការស្តីបន្ទោស នៅក្នុងមាត្រាណាមួយទាល់តែសោះ សម្រាប់យកទៅអនុវត្តចំពោះអនីតិជន ដែលមានអាយុចាប់ពី១៤ ឆ្នាំឡើងដល់ក្រោម ១៨ ឆ្នាំ។ ទាំងនេះជាចម្ងល់ យើងអាចដោះ

[36] មាត្រា៧៦នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[37] យោងតាមប្រសាន៍ សាស្ត្រាចារ្យ កៅ សីហា។

ស្រាយបាន ដោយលើកមាត្រា៧៦នៃក្រមព្រហ្មទណ្ឌ ស្តីពី របបគតិយុត្តនៃការស្ដីបន្ទោស ដើម្បីយកមកធ្វើជាទឡ្ហីករណ៍ផ្នែកគតិយុត្ត ឬអំណះអំណាងតាមផ្លូវច្បាប់។ ដោយបានបញ្ជាក់ឲ្យយើងយល់បានថា ទាំងរូបវន្តបុគ្គលជានីតិជន ទាំងរូបវន្តបុគ្គលជាអនីតិជនមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ គឺចៅក្រមអាចយកមាត្រា៧៦នៃក្រមព្រហ្មទណ្ឌ មកប្រកាសបានដូចគ្នា ព្រោះមាត្រានេះជាបទប្បញ្ញត្តិទូទៅ នៃការស្ដីបន្ទោសដែលចែងនៅក្នុងក្រមព្រហ្មទណ្ឌ។ ប៉ុន្តែនៅទីនេះ គឺមិននិយាយអំពីអនីតិជនអាយុក្រោម១៤ ឆ្នាំទេ ព្រោះបើយកមាត្រា៣៩ កថាខណ្ឌទី២ មកពិនិត្យមើទៅឃើញថា អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌចំពោះគាត់បាន ប្រសិនបើកាលៈទេសៈបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។ ផ្ទុយទៅវិញ បើយើងបកស្រាយជាបដិលោមវិធី ឬវិធីបញ្ច្រាសន័យ នាំឲ្យយើងអាចនិយាយបានថា អនីតិជនអាយុក្រោម១៤ ឆ្នាំ មិនត្រូវទទួលរងនូវទោសព្រហ្មទណ្ឌទេ រួមទាំងទោសស្ដីបន្ទោស ឬទោសការងារសហគមន៍ ក្នុងឋានៈជាទោសជំនួស ទោសបន្ថែម និងមូលទោស គឺចៅក្រមមិនអាចប្រកាសទោសលើគាត់បានឡើយ ពីព្រោះបើគ្មានច្បាប់ចែងទេ អនីតិជនអាយុក្រោម១៤ ឆ្នាំ ក៏គ្មានទោសដែរ។

សរុបសេចក្តីមក ចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ គឺតុលាការអាចប្រកាសទោសចំពោះពួកគាត់បានដូចគ្នា ប្រសិនបើលក្ខខណ្ឌនៃរបបគតិយុត្តពាក់ព័ន្ធនឹងការស្ដីបន្ទោសត្រូវបានបំពេញតាមមាត្រា៧៦នៃក្រមព្រហ្មទណ្ឌ គឺលើកលែងតែ អនីតិជនអាយុក្រោម១៤ ឆ្នាំ ចេញតែប៉ុណ្ណោះ ទើបមិនប្រកាសទោសកើត។

# ជំពូកទី២
# ទោសអនុវត្តសម្រាប់
# នីតិបុគ្គល

# ជំពូកទី២

# ទោសដែលអនុវត្តសម្រាប់នីតិបុគ្គល

នីតិបុគ្គលគឺជាក្រុមមនុស្ស ឬ មូលនិធិដែលមានបុគ្គលភាពគតិយុត្តហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។[38] នីតិបុគ្គលសំដៅដល់អង្គការ ស្ថាប័នដែលបង្កើតឡើងដោយច្បាប់ ក្រុមហ៊ុន សមាគមន៍សហជីព ពាងចក្រជាដើម ដែលទទួលស្គាល់ដោយច្បាប់ហើយជាបណ្តុំនៃរូបវន្តបុគ្គល ។

នីតិបុគ្គលត្រូវបានបែងចែកជាពីរផ្សេងគ្នា និងមានទំនួសខុសត្រូវផ្សេងគ្នាដែលមាន នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលដែលជានីតិបុគ្គលឯកជន។

ហើយជាគោលការណ៍ទោសដែលអនុវត្តសម្រាប់នីតិបុគ្គលគឺមានលក្ខៈខុសគ្នាអំពីទោសដែលអនុវត្តសម្រាប់រូបវន្តបុគ្គល។

ទោសដែលអនុវត្តសម្រាប់នីតិបុគ្គលមាន មូលទោសក្នុងប្រភេទជាទោសពិន័យ និងទោសបន្ថែមទាំង ១៤ ចំណុចដែលមានប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងធ្វើឡើងតាមរយៈការប្រកាសទោសរបស់ចៅក្រមដែលជាអ្នកប្រកាស។[39]

## ២.១. មូលទោសក្នុងប្រភេទជាទោសពិន័យ

ដោយសារតែនីតិបុគ្គលមិនមែនជាមនុស្ស ដូច្នោះហើយចំពោះទណ្ឌកម្មដែលអនុវត្តចំពោះនីតិបុគ្គលក៏វាមានលក្ខណៈខុសគ្នាអំពីទោសដែលអនុវត្តសម្រាប់រូបវន្តបុគ្គលផងដែរ ។

ចំពោះមូលទោសដែលអនុវត្តសម្រាប់នីតិបុគ្គលនៅទីនេះ គឺមានតែទោសពិន័យជាប្រាក់ និងទោសបន្ថែមទាំង ១៤ ចំណុចតែប៉ុណ្ណោះ ពីព្រោះថានីតិបុគ្គលគឺជាគ្រឹះស្ថាន ស្ថាប័នសាធារណៈ ឬ ឯកជនណាមួយ ហេតុដូច្នេះហើយគេមិនអាចចាប់នីតិបុគ្គលដែលជាគ្រឹះស្ថាន ស្ថាប័ន ដាក់ពន្ធនាគារបាននោះទេ។

ចំពោះទោសដែលអនុវត្តសម្រាប់នីតិបុគ្គលគឺយើងឃើញថាមានប្បញ្ញត្តិនៅក្នុងមាត្រា ១៦៧ ដល់មាត្រា ១៨២ នៃក្រមព្រហ្មទណ្ឌ។ ហើយនៅក្នុងមាត្រា ១៦៧ រហូតដល់មាត្រា ១៨២នៃក្រមព្រហ្មទណ្ឌ នេះយើងឃើញថាទោសពិន័យក្នុងឋានៈជាមូលទោសនេះយើងប្រើប្រាស់ដូចគ្នាជាមួយនឹងទោសពិន័យសម្រាប់រូបវន្តបុគ្គល។

ហើយប្រសិនបើចំពោះការប្រកាសទោសទៅលើនីតិបុគ្គលគឺអនុវត្តដូចគ្នាទៅនិងរូបវន្តបុគ្គលចំពោះទោសពិន័យ ដោយកម្រិតនៃទោសពិន័យនៅទីនេះ គឺគិតទៅលើចន្លោះពីអប្បបរមា និង អតិប្បបរមានៃទោស

[38] មាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយកថាខ័ណ្ឌទី៣ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០១០។

[39] មាត្រា១៦៧នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០០៩។

ពិន័យ ។ មានន័យថាកាលណាតុលាការធ្វើការប្រកាសទោស គឺតុលាការអាចធ្វើការពិចារណាពីការពិន័យក្នុងចន្លោះកម្រិតទោសពីអប្បបរមា និងអតិប្បបរមាសមស្របណាមួយចំពោះបទល្មើសដែលមានបញ្ញត្តិ។

### ២.២. ទោសបន្ថែមទាំង១៤ចំណុចកំណត់ដោយក្រមព្រហ្មទណ្ឌ

ទោសបន្ថែម ដែលត្រូវអនុវត្តចំពោះនីតិបុគ្គលគឺមានប្បញ្ញត្តិនៅក្នុងនៃក្រមព្រហ្មទណ្ឌ ដែលទោសបន្ថែមនៅក្នុងមាត្រានោះ មាន១៤ ចំណុច។[40]

ទោសបន្ថែមទាំង ១៤ ចំណុចដែលអនុវត្តសម្រាប់នីតិបុគ្គលនៅទីនេះគឺមានលក្ខណៈខុសគ្នាមួយចំនួនរវាងទោសដែលអនុវត្តសម្រាប់រូបវន្តបុគ្គល ។ ហើយដើម្បីដឹងថាទោសដែលអនុត្តន៍ចំពោះនីតិបុគ្គលបែបណាខ្លះនោះ គឺយើងនិងធ្វើការបង្ហាញដូចខាងក្រោម ។

យោងតាមប្បញ្ញត្តិមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ទោសបន្ថែមដែលអនុវត្តសម្រាប់នីតិបុគ្គលមានដូចតទៅ ៖

១- ការរំលាយចោល ។

២- ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ។

៣- ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន ។

៤- ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ ។

៥- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦- ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរ បាន ក្រៅពីឧបរណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។

៧- ការហាមឃាត់ចំពោះការប្រើប្រាស់ប័ណ្ណទូទាត់ ។

៨- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស ។

៩- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សារធារណៈជន ឬ ដែលបានប្រើប្រាស់ដោយសារធារណៈជន ។

១០- ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តល្មើស ។

១១- ការឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២- ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

[40] មាត្រា១៦៨នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

១៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

➢ **ចំណុចទី១ ( ការរំលាយចោល )៖**

ដោយយោងទៅតាមប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ( ការរំលាយ និងការជម្រះបញ្ជីនីតិបុគ្គល )៖

សេចក្តីសម្រេចដែលបង្គាប់ឲ្យរំលាយនីតិបុគ្គល នាំឲ្យមានការបញ្ជូននីតិបុគ្គលទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។[41]

ការរំលាយនីតិបុគ្គលចោលគឺជាសេចក្តីសម្រេចប្រកាសមួយដែលមានលក្ខណៈធ្ងន់ធ្ងរ ពីព្រោះថាក្រៅអំពីទោសពិន័យជាប្រាក់ហើយតុលាការអាចប្រកាសទោសរំលាយក្រុមហ៊ុន សមាគន៍ ឬនីតិបុគ្គលណាមួយចោលដែលវាគឺជាប្រភេទនៃទោសមួយដែលមានលក្ខណៈធ្ងន់ធ្ងរសម្រាប់នីតិបុគ្គលដែលត្រូវទទួលរង។

➢ **ចំណុចទី២ ( ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ )៖**

ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ មិនអាចលើសពី៥ (ប្រាំ) ឆ្នាំទេ។ សេចក្តីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឲ្យមានការចាត់តាំងអាណ្តត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។ ជារៀងរាល់ ៦ ( ប្រាំមួយ ) ខែ យ៉ាងតិចអាណ្តត្តិគាហកតុលាការត្រូវធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្តឹងទៅតុលាការដែលបានប្រកាស ឲ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ ។

តុលាការសម្រេចក្នុងពេលសវនាការជាសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ អាណត្តិគាហកតុលាការ និងដាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ។[42]

➢ **ចំណុចទី៣ ( ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន )៖**

យោងតាមមាត្រា ១៧២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការហាមឃាត់ចំពោះការធ្វើសកម្មភាព ៖

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់ចិរវេលា ៥ ( ប្រាំ ) ឆ្នាំ យ៉ាងច្រើន ។

តុលាការបញ្ជាក់ពីសកម្មភាពដែលត្រូវហាមឃាត់។[43]

[41] មាត្រា១៧០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[42] មាត្រា១៧១នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[43] មាត្រា១៧២នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

➢ **ចំណុចទី៤.( ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ )៖**

ទោសបណ្ដេញចេញពីលទ្ធកម្មសាធារណៈ នាំឲ្យមានការហាមឃាត់ចំពោះការចូលរួម ដោយផ្ទាល់ ឬ ដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំដោយ ៖

១- រដ្ឋ

២- រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣- គ្រឹះស្ថានសាធារណៈ ។

៤- សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ ដែលត្រួតពិនិត្យដោយរដ្ឋ ឬ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទោសនេះអាចជាស្ថាពរ ឬ ជាបណ្ដោះអាសន្ន សម្រាប់ថេរវេលាមួយមិនលើសពី ៥ ( ប្រាំ ) ឆ្នាំ។[44]

➢ **ចំណុចទី៥. ( ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ) ៖**

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឲ្យធ្វើការដាក់ប្រាក់សន្សំ អាចជាស្ថាពរ ឬជា បណ្ដោះអាសន្នសម្រាប់រយៈពេល ៥ ( ប្រាំ ) ឆ្នាំ យ៉ាងច្រើន ។

ការហាមឃាត់នេះ នាំឲ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវដើម្បីឲ្យ ដាក់ឧបករណ៍ អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬ ក្រុមហ៊ុនមូលបទានបត្រ ។

ការហាមឃាត់នេះនាំឲ្យមានការហាមឃាត់ចំពោះការផ្សព្វផ្សាយជាសាធារណៈដែរ។[45]

➢ **ចំណុចទី៦. ( ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរ បាន ក្រៅពីឧបរណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ) ៖**

ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន អាចជាស្ថាពរ ឬ ជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ ( ប្រាំ ) ឆ្នាំ យ៉ាងច្រើន។[46]

➢ **ចំណុចទី៧. ( ការហាមឃាត់ចំពោះការប្រើប្រាស់ប័ណ្ណទូទាត់ )៖**

ផ្អែកតាមមាត្រា១៧៥ នៃក្រមព្រហ្មទណ្ឌកថាខ័ណ្ឌទី ២ ចំពោះការហាមឃាត់ប្រើប្រាស់ប័ណ្ណទូទាត់ ក៏ ដូចគ្នាដែរ ។

➢ **ចំណុចទី៨. ( ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស ) ៖**

[44] មាត្រា១៧៣នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[45] មាត្រា១៧៤នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[46] មាត្រា១៧៥នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ទោសបិទគ្រឹះស្ថាននាំឱ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ។[47]

ទោសនេះអាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

- **ចំណុចទី៩. ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សារធារណៈជន ឬ ដែលបានប្រើប្រាស់ដោយសារធារណៈជន ៖**

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយ ដែលបើកចំហដល់សាធារណៈជន ឬ ដែលប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។[48]

- **ចំណុចទី១០. ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តល្មើស ៖**

តាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការរឹបអូស និង សិទ្ធតតិយជនៈ

កថាខណ្ឌទី១ : ឧកបករណ៍សម្ភារៈ ឬ វត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តិបទល្មើស ឬ ដែលមានគោលដៅសម្រាប់ការប្រព្រឹត្តិបទល្មើស ។[49]

កថាខណ្ឌទី៤ : ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើត ក៏ប៉ុន្តែការរឹបអូសមិនអាចត្រូវបានប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធរបស់តតិយជន ។

- **ចំណុចទី១១. ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ៖**

-កថាខណ្ឌទី២ : វត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

យោងតាមប្បញ្ញត្តិមាត្រា ១៧៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការរឹបអូស និង សិទ្ធិតតិយជនៈ

- **ចំណុចទី១២. ការរឹបអូស ផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ៖**

-មាត្រា ១៧៩នៃក្រមព្រហ្មទណ្ឌ កថាខណ្ឌទី៣ : ផលទុនឬ ទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

- **ចំណុចទី១៣. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ៖**

- មាត្រា ១៧៩ នៃក្រមព្រហ្មទណ្ឌដដែលកថាខណ្ឌទី៤ : ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើត ក៏ប៉ុន្តែការរឹបអូសមិនអាចត្រូវបានប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

[47] មាត្រា១៧៦នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[48] មាត្រា១៧៧នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[49] មាត្រា១៧៩នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

➢ **ចំណុចទី១៤. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមសមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ៖**

ការបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រាប់រយៈពេលមួយដែលកំណត់ឡើងដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ ( ខែ ) ។ ការបិទផ្សាយអាចទាំងស្រុងតាមសម្រង់ ឬ តាមនិទ្ទេសធម្មតា ។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ក្នុងករណីដែលដកបំបាត់ចេញ លាក់កំបាំង ឬហែកចោលសេចក្តីប្រកាសបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្តងទៀត ។ សោហ៊ុយនៃការបិទផ្សាយនេះ ត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោល លាក់កំបាំង ឬ ហែកចោល ។[50]

តាមក្រមព្រហ្មទណ្ឌបានចែងថា ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយ ទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍ :

ទោសផ្សាយសេចក្តីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ ។ ការផ្សាយនេះ មិនអាចលើសពីរ ៨ ( ប្រាំបី ) ថ្ងៃ ។ ការផ្សាយនេះ អាចផ្សាយទាំងស្រុងតាមសម្រង់ ឬ តាមនិទ្ទេស ។ សោហ៊ុយការផ្សាយនេះជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារពត៌មាន មិនអាចបដិសេធការចុះផ្សាយនេះបានទេ ។

ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារពត៌មានសរសេរតាមបែបបទនិងចិរវេលាដែលកំណោត់ដោយតុលារ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់នីតិបុគ្គល ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារពត៌មានមិនអាចបដិសេធការចុះផ្សាយនេះបានទេ ។[51]

## ២.៣ . ការប្រកាសទោសព្រហ្មទណ្ឌ ចំពោះទោសនីមួយៗទៅលើនីតិបុគ្គល

យើងដឹងហើយថានីតិបុគ្គលគឺជាក្រុមមនុស្ស ឬ មូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ដែលបង្កើតឡើងដោយច្បាប់ និងជាប្រធាននៃសិទ្ធ និងកាតព្វកិច្ច ។ ហើយនីតិបុគ្គលនេះទៀតសោតត្រូវបានបែងចែកជាពីរ គឺ នីតិបុគ្គលនៃនីតិសាធារណៈ ( នីតិបុគ្គលដែលជារដ្ឋ ) និង នីតិបុគ្គលដែលជានីតិឯកជន ( នីតិបុគ្គលមិនមែនជារដ្ឋ )ដែលយើងនឹងធ្វើការបកស្រាយដូចខាងក្រោម ៖

[50] មាត្រា១៨០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[51] មាត្រា១៨១នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

### ២.៣ .១. នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិបុគ្គលដែលជារដ្ឋ

នីតិបុគ្គលនៃនីតិសាធារណៈ ( នីតិបុគ្គលដែលជារដ្ឋ ) គឺជាក្រុមមនុស្សដែលច្បាប់បានអនុញ្ញាតឲ្យធ្វើសកម្មភាពដូចជាបុគ្គល ដើម្បីជាផលប្រយោជន៍សាធារណៈនិងគ្មានគោលបំណងដើម្បីទទួលបានប្រាក់ចំណេញដែលវាមានលក្ខណៈខុសគ្នាអំពីនីតិបុគ្គលដែលជានីតិបុគ្គលឯកជន ។ នីតិបុគ្គលសាធារណៈគឺជាស្ថាប័នដែលត្រូវបានបង្កើតឡើងដោយច្បាប់ និងត្រូវគ្រប់គ្រងដោយច្បាប់សាធារណៈ ហើយមានសិទ្ធអំណាចក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាល ។[52]

នីតិបុគ្គលនៃនីតិសាធារណៈនៅទីនេះគឺ សំដៅដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ( រាជធានី ខេត្តក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ) និងគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាល និងឧស្សាហកម្ម ពាណិជ្ជកម្ម ។

ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលវិញយើងឃើញថា ដោយយោងទៅតាមបញ្ញត្តិមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលបញ្ញត្តិអំពី ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល បានចែងថា នៅក្នុងករណីដែលមានចែងជាក់លាក់នៅក្នុងច្បាប់ និងបទដ្ឋានគតិយុត្តិផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកដំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។

ដោយយោងទៅតាមបញ្ញត្តិមាត្រានេះយើឃើញថា រដ្ឋដែលជានីតិបុគ្គលនៃនីតិសាធារណៈគឺមិនតម្រូវឲ្យមាននូវការទទួលខុសត្រូវព្រហ្មទណ្ឌណាមួយទេ ហើយក៏មិនត្រូវទទួលនូវទោសព្រហ្មទណ្ឌដែរ ។

**តើមានមូលហេតុអ្វីខ្លះបានជារដ្ឋមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ទោសព្រហ្មទណ្ឌ** ?

ដើម្បីដឹងថាហេតុអ្វីបានជារដ្ឋមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ទោសព្រហ្មទណ្ឌនោះ ដំបូងយើងត្រូវស្វែងយល់នូវពាក្យថារដ្ឋជាមុនសិន ។ រដ្ឋ គឺជា នគរ ឬ បុរី ឬ ប្រទេសមួយ ហេតុនេះហើយក្រមព្រហ្មទណ្ឌគឺមិនអាចចែងដើម្បីរំលាយ រដ្ឋ ឬ នគរ ឬ បុរី ឬ ប្រទេសមួយបានឡើយ ដោយសារតែរដ្ឋជាអ្នកគ្រប់គ្រងសង្គម ដូច្នេះរដ្ឋត្រូវតែបង្កើតច្បាប់ដើម្បីដាក់ទោសទៅលើសមាជិកសង្គមណាដែលបានប្រព្រឹត្តបទល្មើស ។ អាស្រ័យហេតុនេះប្រសិនបើរដ្ឋត្រូវមានទោស ឬ ទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថារដ្ឋបង្កើតច្បាប់ព្រហ្មទណ្ឌដើម្បីដាក់ទោស រដ្ឋខ្លួនឯងហើយ ដែលវាគឺជារឿងមួយដែលមិនអាចធ្វើទៅបាន ហើយវានិងបណ្តាលឲ្យប៉ះពាល់ដល់អធិប្បតេយ្យរបស់ជាតិ។[53]

---

[52] យោងតាមសន្ទានុក្រមនៃច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ។

[53] មាត្រា១ ដល់មាត្រា៦នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ដូចនេះនីតិបុគ្គលដែលជារដ្ឋមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌណាមួយឡើយ លើកលែងតែបទល្មើសចំនួន ៤ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ( ICC ) ដែលជាបទល្មើសធ្ងន់ធ្ងរនិងមិនអាចលើកលែងបាន រវាងរដ្ឋ និង ប្រជាពលរដ្ឋ ដែលកើតមាននៅក្នុងប្រទេសមួយប៉ុណ្ណោះ ។

បទល្មើសទាំង ៤ នោះមានដូចជាៈ

១. បទឧក្រិដ្ឋប្រល័យពូជសាសន៍

២.បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

៣.បទឧក្រិដ្ឋសង្គ្រាម និង

៤. បទឧក្រិដ្ឋកម្មឈ្លានពាន ។

ដែលបទល្មើសទាំង ៤ នេះគឺជាប្រភេទនៃបទល្មើសដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនិងមិនអាចលើកលែងឲ្យបាន ។

មួយវិញទៀតដោយយោងទៅតាមបញ្ញត្តិ ( មាត្រា ១៧០ )នៃក្រមព្រហ្មទណ្ឌដដែលនេះ ចំពោះទោសបន្ថែមដែលអនុវត្តទៅលើនីតិបុគ្គល គឺចែងអំពីការរំលាយនីតិបុគ្គលនោះចោល ដែលនីតិបុគ្គលនៅទីនេះគឺសំដៅដល់នីតិបុគ្គលដែលមិនមែនជារដ្ឋតែប៉ុណ្ណោះ ពីព្រោះថាប្រសិនបើមានការអនុញ្ញាតឲ្យរំលាយនីតិបុគ្គលដែលជារដ្ឋ ឧទាហរណ៍ដូចជាប្រទេសកម្ពុជាយើង ប្រសិនបើមានការអនុញ្ញាតឲ្យរំលាយប្រទេសចោលបាននោះគឺវានិងមានផលប៉ះពាល់ទៅដល់អធិប្បតេយ្យជាតិរបស់ព្រះរាជាណាចក្រកម្ពុជាហើយ ដូច្នេះក្រមព្រហ្មទណ្ឌថ្មីនេះនិងអធម្មនុញ្ញភាព ។ ចំពោះនីតិបុគ្គលដែលមិនមែនជារដ្ឋវិញចំពោះទោសបន្ថែមនៅក្នុងការរំលាយនីតិបុគ្គលនេះអាចធ្វើទៅបានតាមសេចក្តីសម្រេចរបស់តុលាការ តាមរយៈការបញ្ជូននីតិបុគ្គលនោះទៅតុលាការមានសមត្ថកិច្ចដើម្បីធ្វើការជម្រះបញ្ជី ក្នុងន័យនីតិបុគ្គលមិនមែនជារដ្ឋ ( ជាអង្គការ ឬ សមាគមន៍ ) ។

## ២.៣.២. នីតិបុគ្គលដែលជានីតិឯកជន ឬ នីតិបុគ្គលដែលមិនមែនជារដ្ឋ

នីតិបុគ្គលឯកជនគឺជាក្រុមមនុស្ស ឬ មូលនិធិ ដែលមានបុគ្គលភាពគតិយុត្តិ ហើយជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ច និងស្ថិតក្រោមវិធានទាំងឡាយណាដែលគ្រប់គ្រងទំនាក់ទំនងគតិយុត្តរវាង បុគ្គលឯកជន និងបុគ្គលឯកជន និងមិនស្ថិតនៅក្រោមនីតិសាធារណៈទេ ។ នីតិបុគ្គលឯកជនមានដូចជា អង្គការ ក្រុមហ៊ុនសមាគមន៍ សហជីព រោងចក្រ .ល . ។ ដែលជាប្រធាននៃបទល្មើសនៅក្នុងសង្គមបច្ចុប្បន្ន និងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ទទួលទោសព្រហ្មទណ្ឌចំពោះទង្វើដែលបានប្រព្រឹត្ត ។

ហើយចំពោះការប្រកាសទោសព្រហ្មទណ្ឌទៅលើនីតិបុគ្គលនេះវិញជាគោលការណ៍ គឺធ្វើឡើងតាមរយៈចៅក្រមដែលជាអ្នកមានសិទ្ធិនៅក្នុងការប្រកាសទោស ដែលជាកាតព្វកិច្ចនិងកំណត់ដោយតុលាការ ។

**តើនីតិបុគ្គលដែលជានីតិឯកជន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌបែបណា** ?

ដើម្បីដឹងថា នីតិបុគ្គលដែលជានីតិបុគ្គលឯកជនទទួលខុសត្រូវព្រហ្មទណ្ឌបែបណានោះគឺយើងនិងធ្វើការបកស្រាយដូខាងក្រោម៖

ចំពោះទោសដែលត្រូវបានយកទៅអនុវត្តចំពោះនីតិបុគ្គលគែមានតែពីរប្រភេទប៉ុណ្ណោះគឺ ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស និង ទោសបន្ថែមទាំង ១៤ ចំណុច។ហើយចំពោះទោសជំនួសវិញគឺមិនត្រូវបានយកមកអនុវត្តចំពោះនីតិបុគ្គលនោះទេ ព្រោះថានីតិបុគ្គលគឺជាមនុស្សអរូបិយ៍ ( គ្មានរូបរាងពិតប្រាកដ ) ដូច្នេះហើយមិនអាចយកទោសជំនួសដែលជាប្រភេទនៃទោសបែបជាទោសកាងារសហគមន៍ ឬ ទោសស្តីបន្ទោសយកទៅអនុវត្តចំពោះ នីតិបុគ្គលដែលអរូបិយ៍បានឡើយ ព្រោះថានីតិបុគ្គលគឺអរូបិយ៍គ្មានរូបរាង ដូច្នេះហើយយើងមិនអាចយកទោសប្រភេទនេះទៅអនុវត្តចំពោះនីតិបុគ្គលបានទេ ។

### ២.៣.៣. ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស

ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស គឺជាទោសមួយប្រភេទដែលត្រូវបានយកទៅអនុវត្តចំពោះនីតិបុគ្គល ដែលជាទោសពិន័យជាប្រាក់ និងកំណត់ជាមូលទោសដោយគ្មានទោសដាក់ពន្ធនាគារទៀតនោះទេ ព្រោះថានីតិបុគ្គលគឺមានលក្ខណៈខុសពីរូបវន្តបុគ្គលដែលជាបុគ្គលមានសាច់ មានឈាម មានជីវិត ។

ហេតុនេះហើយការដែលចាប់នីតិបុគ្គលដែលជាក្រុមហ៊ុន គ្រឹះស្ថាន សហគ្រាស រោងចក្រដែលមានលក្ខណៈជា ( អរូបិយ៍ ) ដាក់ពន្ធនាគារគឺមិនអាចធ្វើបាននោះទេ ។

ហើយចំពោះទោសដែលអាចយកទៅអនុវត្តចំពោះនីតិបុគ្គលបានទៀតនោះគឺមានទោសមួយប្រភេទទៀតគឺទោសបន្ថែមទាំង ១៤ ចំណុច ។

### ២.៣.៤. ទោសបន្ថែមទាំង ១៤ ចំណុច

ចំពោះទោសបន្ថែមនៅទីនេះ គឺជាប្រភេទនៃទោសមួយប្រភេទទៀតដែលបន្ថែមទៅលើមូលទោស ដែលមានន័យថាក្រៅពីមូលទោសក្នុងប្រភេទជាទោសពិន័យជាប្រាក់ហើយតុលាការអាចប្រកាសទោសបន្ថែមទៅលើនីតិបុគ្គលបានផងដែរ ហើយការប្រកាសទោសបន្ថែមនេះត្រូវបានក្រមព្រហ្មទណ្ឌចងជាកាតព្វកិច្ចចំពោះចៅក្រម ឬ ចាប់បង្ខំឲ្យចៅក្រមត្រូវតែប្រកាសទោសបន្ថែមទៅលើនីតិបុគ្គល មានន័យថាទោសបន្ថែមនៅទីនេះវាមិនមែនជាជម្រើសរបស់ចៅក្រមនៅក្នុងការសម្រេចថាប្រកាស ឬ មិនប្រកាសឡើយ ដែលវាមានលក្ខណៈខុសពីទោសបន្ថែមសម្រាប់រូបវន្តបុគ្គល ។ ដូចនេះនៅពេលដែលតុលាការសម្រេចផ្តន្ទាទោសជាប្រាក់ក្នុងឋានៈជាមូលទោសចំពោះនីតិបុគ្គលណាមួយហើយ តុលាការមានកាតព្វកិច្ចត្រូវតែប្រកាសនូវទោសបន្ថែមជាដាច់ខាតទៅលើនីតិបុគ្គលណាមួយនោះ ។

ឧទាហរណ៍៖ មាត្រា ៣៣៦ នៃក្រមព្រហ្មទណ្ឌដដែលនេះដែលនិយាយអំពី ការអនុវត្តទោសចំពោះនីតិបុគ្គល ដែលមានខ្លឹមសាថា នីតិបុគ្គលអាចនិងត្រូវបានប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមលក្ខណ្ឌ

ដែលមានចែងនៅក្នុងមាត្រា ៤២នៃក្រមព្រហ្មទណ្ឌ ( ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងនៅក្នុងមាត្រា ៣៣០ ( បទញុះញង់អោយបោះបង់ទារក ) មាត្រា ៣៣១ ( បទអន្តរកាលរវាងអ្នកសុំកូននិងអ្នកបោះបង់កូន ) មាត្រា ៣៣២នៃក្រមព្រហ្មទណ្ឌ ( បទអន្តរកាលរវាងអ្នកសុំកូននិងស្រ្តីពរពោះ ) នៃក្រមនេះ ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.000.000 ( មួយលាន ) រៀលទៅ ៥.000.000 ( ប្រាំលាន ) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ។ ចំពោះទោសបន្ថែមដែលត្រូវយកទៅអនុវត្តចំពោះនីតិបុគ្គល ជាកាតព្វកិច្ចដែលបានចងចៅក្រមឲ្យត្រូវតែប្រកាសជាមួយមូលទោសក្នុងប្រភេទជាទោសពិន័យតែម្តង ។

ជារួមមកចំពោះទោសដែលអនុវត្តទាក់ទងទៅនិងនីតិបុគ្គលគឺមានចែងយ៉ាងពិសេសចាប់ពីមាត្រា ១៦៧ ទៅដល់មាត្រា ១៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩នេះ ។ ប៉ុន្តែអ្វីដែលមិនបានចែងចាប់ពីមាត្រ ១៦៧ ដល់មាត្រា ១៨១ នៃក្រមព្រហ្មទណ្ឌនេះ គឺត្រូវបានបកស្រាយជូនហើយអំពីបទបញ្ញត្តទូទៅដែលអនុវត្តសម្រាប់រូបវន្តបុគ្គល ។

# ជំពូកទី៣

# ស្ថានទម្ងន់ទោស

# និង

# ស្ថានសម្រាលទោស

# ជំពូកទី៣

# ស្ថានសម្រាលទោស និង ស្ថានទម្ងន់ទោស

ជាទូទៅទាក់ទងទៅនិងទោសព្រហ្មទណ្ឌ គឺឃើញថាមានកំណត់អំពីប្រភេទនៃទោសព្រហ្មទណ្ឌ ស្ថានទម្ងន់ទោសព្រហ្មទណ្ឌ និង ស្ថានសម្រាលទោសព្រហ្មទណ្ឌ ។ ដោយឈរលើគោលការណ៍នីត្យានុកូលភាព ឃើញថា ចំពោះស្ថានទម្ងន់ និង ស្ថានសម្រាលទោសព្រហ្មទណ្ឌ គឺមានកំណត់នៅក្រមព្រហ្មទណ្ឌ។ មួយវិញទៀតពាក់ព័ន្ធទៅនិង អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ព្រមទាំងទោសពិន័យជាប្រាក់ គឺអាចមានការបន្ថែម ឬ បន្ថយ ។[54]

ស្ថានទម្ងន់ទោសគឺជា ការដំឡើងទោសឲ្យដល់ កម្រិតអតិប្បរមាដាក់ទៅលើជនណាម្នាក់ ដែលជាការកំណត់ដោយច្បាប់។[55]

ការសម្រាលទោសវិញ គឺជាការបញ្ចុះទោសដល់កម្រិតក្រោមអប្បបរមាដែលដាក់ទៅលើជនណាម្នាក់ ដែលកំណត់ដោយច្បាប់ដូចគ្នា ។[56]

ចំពោះស្ថានទម្ងន់ទោសគឺជាទូទៅគេមើលទៅលើចរិតគ្រោះថ្នាក់នៃអំពើរបស់ជនល្មើស ទំហំនៃការខូចខាតជាដើម និង ដោយការដែលចារីស្ថិតក្នុងលក្ខខណ្ឌនៃការមិនរាងចាលណាមួយ ទោះបីជាបានប្រព្រឹត្តបទល្មើសណាមួយក៏ដោយ ។ ចំណែកឯស្ថានសម្រាលទោសវិញគឺមើលទៅខ្នាតនៃទោសដែលត្រូវអនុវត្ត និង ស្ថានភាពបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលជាលក្ខខណ្ឌនៅក្នុងការអនុវត្ត ។

## ៣.១. ស្ថានទម្ងន់ទោស

ដោយយោងទៅតាមមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ កថាខ័ណ្ឌទី២ នៃក្រមដដែលនេះបានចែងថា ៖ មានតែទោសដែលមានចែងនៅក្នុងបទប្បញ្ញត្តិជាធរមាននៅពេលដែលអំពើនោះបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។ ហើយចំពោះការប្រកាសទោសនៅទីនេះ គឺតុលាការតែងតែគិតទៅលើស្ថានទម្ងន់ទោស និង ស្ថានសម្រាលទោស ដោយធ្វើការពិនិត្យមើលទៅលើ ចរិតគ្រោះថ្នាក់នៃអំពើនោះ ដែលជនល្មើសបានប្រព្រឹត្ត ពិនិត្យទៅលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ព្រមទាំងសភាពផ្លូវចិត្តរបស់ជនជាប់ចោទ និង កាលៈទេសៈតម្រូវ ដែលជាមូលហេតុក្នុងការប្រព្រឹត្តបទល្មើស ហើយក៏ជាចំណុចដែលតុលាការត្រូវពិចារណាផងដែរ ។ បែបនេះហើយទើបតុលាការអាចធ្វើការកំណត់ថា តើជននោះត្រូវទទួលលបាននូវស្ថានទម្ងន់ទោស ឬ ទទួលបាននូវស្ថានសម្រាលទោសសម្រាប់អំពើដែលខ្លួនបានប្រព្រឹត្ត ។

---

[54] មាត្រា៤៥នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[55] សទ្ទានុក្រមពាក្យច្បាប់នៃក្រមព្រហ្មទណ្ឌទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី៩។

[56] សទ្ទានុក្រមពាក្យច្បាប់នៃក្រមព្រហ្មទណ្ឌទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី២៤។

ជាទូទៅទាក់ទងទៅនិងស្ថានទម្ងន់ទោសនៅទីនេះគឺ អ្នកដែលបានរៀបចំតាក់តែងច្បាប់បានចង្អុលបង្ហាញយ៉ាងជាក់លាក់ណាស់អំពីស្ថានទម្ងន់ទោសដោយកំណត់ជាសញ្ញាណដាច់ខាតដោយកំណត់ថាបើមិនមានច្បាប់ចែងទេ នោះចៅក្រមមិនអាចជ្រើសរើសយកស្ថានទម្ងន់ទោសផ្សេងទៀតមកបន្ថែមបានឡើយ ។ ដែលមានន័យថាទោះបីជាស្របជាមួយនិងទស្សនៈសង្គមក៏ដោយ អោយតែច្បាប់មិនបានចែងគឺចៅក្រមមិនអាចយកស្ថានទម្ងន់ទោសផ្សេងទៀត យកមកបន្ថែមបាននោះទេ ។

នៅក្នុងការកំណត់អំពីស្ថានទម្ងន់ទោសនេះគឺឈរទៅលើគោលការណ៍តែពីរប៉ុណ្ណោះគឺ ៖

១- ចរិតគ្រោះថ្នាក់នៃអំពើល្មើស និង

២- ការមិនរាងចាល

### ៣.១.១. ស្ថានទម្ងន់ទោសទូទៅ ឬ ចរិតគ្រោះថ្នាក់នៃអំពើរបស់ជនល្មើស

ស្ថានទម្ងន់ទោសទូទៅ ឬ ចរិតគ្រោះថ្នាក់នៃអំពើរបស់ជនល្មើស គឺជាស្ថានភាពមួយដែលមានកំណត់យ៉ាងជាក់លាក់នៅក្នុងបទប្បញ្ញត្តិជាធរមាន ចំពោះបទល្មើសនីមួយៗដោយហេតុថាអំពើនោះគឺជាអំពើមួយដែលបង្កនូវបញ្ហាយ៉ាងធ្ងន់ធ្ងរដល់សង្គម ។

ហើយទម្រង់នៃអំពើទាំងនោះគឺមានចែងចាប់ពីមាត្រា ៧៧ ដល់មាត្រា ៨២ នៃក្រមព្រហ្មទណ្ឌ និងមានខ្លឹមសារដូចតទៅ ៖

១- ក្រុមមានការចាត់តាំង

២- ការគិតទុកជាមុន

៣- ការកាប់គាស់ទម្លុះទម្លាយ

៤- ការផ្លោះរបងចូល

៥- ការប្រើប្រាស់អាវុធ និង វត្ថុដែលត្រូវបានចាត់ទុកដូចជាអាវុធ

៦- ការពួនស្ទាក់ ។

#### ៣.១.១.១. ក្រុមមានការចាត់តាំង

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬ សន្និដ្ឋិភាពដែលបានធ្វើឡើងដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។[57]

#### ៣.១.១.២. ការគិតទុកជាមុន

[57] មាត្រា៧៧នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ការគិតទុកជាមុនគឺជាគម្រោង ដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស ។ ដែលវាគឺជាស្ថានភាពមួយដែលចារីមានគម្រោងការណាមួយក្នុងការប្រព្រឹត្តបទល្មើស និង ដោយមានរៀបចំទុកជាមុន ។[58]

**៣.១.១.៣. ការកាប់គាស់ទម្លុះទម្លាយ**

ការកាប់គាស់ទម្លុះទម្លាយគឺជាអំពើបង្ខំធ្វើឲ្យខូចខាត ឬ បំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬ របងទោះបីមានប្រភេទយ៉ាងណាក៏ដោយ ។

ត្រូវចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយៈ

១- ការប្រើប្រាសកូនសោក្លែង

២- ការប្រើប្រាស់កូនសោដែលបានមកពីឧបាយកលទុច្ចរិត ។

៣- ការប្រើប្រាសឧបករណ៍ ដើម្បីធ្វើឱ្យគ្រឿងបិទមានដំណើរការដោយគ្មានការបង្ខិតបង្ខំ ការខូចខាត ឬ ការបំផ្លិចបំផ្លាញទេ។[59]

**៣.១.១.៤. ការផ្លោះរបងចូល**

ការផ្លោះរបងចូល គឺជាអំពើចូលទៅក្នុងទីកន្លែងណាមួយដោយឆ្លងរបង ឬ ដោយចូលតាមទ្វារ ឬ បង្អួចដែលមិនមែនប្រើសម្រាប់ធ្វើជាផ្លូវចូលទេ។[60]

**៣.១.១.៥. ការប្រើប្រាស់អាវុធ និង វត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ**

អាវុធគឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬ ធ្វើឲ្យមានរបួស ។

ត្រូវចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចតទៅៈ

១- វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឲ្យរបួស ឬ គំរាមកំហែង ។

២- វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឲ្យមានរបួស ឬ គំរាមកំហែង ។ ការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឲ្យមានរបួស ឬ គំរាមកំហែង ត្រូវចាត់ទុកដូចជាបានប្រើប្រាស់អាវុធដែរ។[61]

**៣.១.១.៦. ការពួនស្ទាក់**

ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំមើលជនរងគ្រោះនៅទីកន្លែងណាមួយ ក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្តបទល្មើស ។[62]

**៣.១.២. ការមិនរាងចាល**

[58] មាត្រា៧៨នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[59] មាត្រា៧៩នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[60] មាត្រា៨០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[61] មាត្រា៨១នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[62] មាត្រា៨២នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ការមិនរាងចាលគឺជាស្ថានភាពមួយដែលបុគ្គលម្នាក់បានប្រព្រឹត្តបទល្មើសមួយ និងត្រូវបានតុលាការផ្តន្ទាទោស ប៉ុន្តែក្រោយពីត្រូវបានផ្តន្ទាទោសនិងសាលក្រមបានចូលជាស្ថាពររួចហើយនោះ បុគ្គលនោះបានទៅប្រព្រឹត្តបទល្មើសមួយផ្សេងទៀត ដែលការប្រព្រឹត្តបទល្មើសថ្មីក្រោយនេះគឺជាស្ថានភាពនៃការមិនរាងចាល ដោយយោងទៅតាមលក្ខខណ្ឌដែលបានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌដែលនិយាយអំពីលក្ខខណ្ឌនៃការមិនរាងចាល ។ ករណីមិនរាងចាលនេះគឺជាទណ្ឌកម្មមួយដែលមានបន្ថែមនៅអតិបរមានៃទោស ប្រសិនអំពើដែលបានប្រព្រឹត្តនោះស្ថិននៅក្នុងលក្ខខណ្ឌនៃការមិនរាងចាល។[63]

### ៣.១.២.១. អានុភាពនៃការមិនរាងចាល

ការមិនរាងចាលមានអានុភាព នាំឲ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើស ឧក្រិដ្ឋ ឬ មជ្ឈិម នៅក្នុងលក្ខខណ្ឌដែលមានចែងដោយកថាភាគនេះ ។[64]

ដែលមានន័យថាវាគឺជាស្ថានភាពមួយដែលនាំឲ្យមាននូវការបន្ថែមនូវទម្ងន់អតិបរមានៃទោសចំពោះបទល្មើសនីមួយៗដែលច្បាប់បានកំណត់ ហើយដែលបទល្មើសទាំងនោះចូលនៅក្នុងលក្ខខណ្ឌនៃការមិនរាងចាល ដែលវាត្រូវបានកំណត់ដោយកថាភាគនេះ ។

### ៣.១.២.២. លក្ខខណ្ឌនៃការមិនរាងចាល

ការមិនរាងចាលត្រូវបានកើតឡើងក្នុងករណីដូចតទៅ ៖

១- កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទ ឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីមួយទៀតនៅក្នុងរយៈពេល ១០ ( ដប់ ) ឆ្នាំ។[65]

យោងតាមក្រមព្រហ្មទណ្ឌ បានចែងអំពីការមិនរាងចាលក្នុងបទឧក្រិដ្ឋដែលមានន័យថា ៖

កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទ ឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយថ្មីទៀតនៅក្នុងរយៈពេល ១០ ( ដប់ ) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មី ត្រូវបន្ថែមទម្ងន់តាមខ្នាតដូចតទៅ :

- ប្រសិនបើអតិប្បរមានៃទោសដាក់ពន្ធនាគាចំពោះបទឧក្រិដ្ឋមិនលើសពី ២០ឆ្នាំទេ អតិបរមានេះត្រូវទ្វេឡើង។[66]

[63] មាត្រា៨៤នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[64] មាត្រា៨៣នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[65] មាត្រា៨៤នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[66] មាត្រា៨៥នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ឧទាហរណ៍៖ បុគ្គល ( **ក** ) បានប្រព្រឹត្តបទល្មើសមួយដែលជាបទ លួចដែលមានស្ថានទម្ងន់ទោស ដោយយោងតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌនេះ ដែលជាបទឧក្រិដ្ឋ និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ ( បី ) ឆ្នាំ ទៅ ១០ ( ដប់ ) ឆ្នាំ ហើយនៅពេលដែលតុលាការចេញសាលក្រមចូលជាស្ថាពរ នៅថ្ងៃទី ០១ ខែ ០១ ឆ្នាំ ២០០៥ ហើយមិនទាន់ផុតរយៈពេល ១០ ( ដប់ ) ឆ្នាំ ផងបុគ្គល ( **ក** ) បានទៅ ប្រព្រឹត្តបទល្មើសថ្មីមួយទៀតដែលជាបទឧក្រិដ្ឋ ដែលការប្រព្រឹត្តបទឧក្រិដ្ឋថ្មីនេះគឺចូលជាករណីមិនរាងចាល ។ និងប្រសិនបើបទឧក្រិដ្ឋថ្មីដែលបានប្រព្រឹត្តនោះគឺជាបទឧក្រិដ្ឋដែលជាបទឃាតកម្ម ដោយយោងតាម( មាត្រា ១៩៩ ) នៃក្រមព្រហ្មទណ្ឌនេះ និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ( ដប់ ) ឆ្នាំ ទៅ ១៥ ( ដប់ប្រាំ ) ឆ្នាំ ប្រសិនបើបែបនេះគឺតុលាការត្រូវពិចារណាអំពីការផ្តន្ទាទោស ដោយត្រូវផ្តន្ទាទោសចន្លោះពី ១៥ ( ដប់ប្រាំ ) ឆ្នាំ ទៅ ៣០ ( សាបសិប ) ឆ្នាំ ដោយយក ១៥ ( ដប់ប្រាំ ) ឆ្នាំ ទៅគុណនិង២ ដោយហេតុវាគឺជាករណីនៃការមិនរាងចាល ។

មួយវិញទៀតប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មីនេះមានរយៈពេល ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។

**២**- កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទ ឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈឹមក្នុងរយៈពេល ៥ ( ប្រាំ ) ឆ្នាំ ។ ករណីបែបនេះគឺជាករណីមួយនៃការប្រព្រឹត្តបទមជ្ឈឹមដោយមិនរាងចាល ។ ហើយកាលណាចូលករណីមិនរាងចាលបែបនេះគឺអតិបរមានៃទោសចំពោះបទមជ្ឈឹមដែលប្រព្រឹត្តលើកក្រោយនោះ គឺត្រូវទ្វេដង ( គុណនិងពីរ ) នេះបើយោងទៅតាមមាត្រា ៨៦ នៃក្រមព្រហ្មទណ្ឌនេះ ។

ឧទាហរណ៍ ៖ បុគ្គល ( ក ) បានប្រព្រឹត្តបទឧក្រិដ្ឋមួយដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៥ (ប្រាំ) ឆ្នាំ ។ ប៉ុន្តែមិនទាន់បានផុត ៥ ( ប្រាំ ) ឆ្នាំផងបន្ទាប់ពីសាលក្រមចូលជាស្ថាពរ គាត់ក៏បានទៅប្រព្រឹត្តបទល្មើសថ្មីមួយទៀតដែលជាបទមជ្ឈឹម ។ ដូចនេះការប្រព្រឹត្តបទមជ្ឈឹមលើកក្រោយនេះគឺចូលទៅក្នុងលក្ខខណ្ឌនៃការមិនរាងចាលចំពោះបទមជ្ឈឹមបន្ទាប់ពីប្រព្រឹត្តបទឧក្រិដ្ឋ ។ ហើយចំពោះអតិបរមានៃទោសគឺតុលាការនិងពិចារណាទោសទ្វេដង ។

ឧទាហរណ៍ ៖ ( ក ) បានប្រព្រឹត្តបទល្មើសមួយដែលជាបទ ទារុណកម្ម និងអំពើឃោរឃៅ ( មាត្រា ២១០ នៃក្រមព្រហ្មទណ្ឌ ) ។ និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ( ប្រាំពី ) ឆ្នាំ ទៅ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។ហើយតុលាការសម្រេចដាក់ពន្ធនាគារ ១០ (ដប់ ) ឆ្នាំ ដោយគិតពីចន្លោះ ៧ ( ប្រាំពីរ ) ឆ្នាំ ទៅ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។ ហើយសាលក្រមចូលជាស្ថាពរនៅថ្ងៃទី ០១ ខែ ០១ ឆ្នាំ ២០១១ ។ ប៉ុន្តែមកដល់ឆ្នាំ ២០១៥ គាត់ក៏បានទៅប្រព្រឹត្តបទមជ្ឈឹមមួយទៀតដែលជាបទ ( បទក្លែងពត៌មាន ) ដែលជាអំពើមួយដែលគាស់កកាយ ក្លែងពត៌មានក្លែង ដើម្បីធ្វើឲ្យជឿថា និងមានអ្វីកើតឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម ឬ ការធ្វើឲ្យខូចខាត

ប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស ។ដោយយោងតាមមាត្រា ៤២៥នៃក្រមព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ ) ឆ្នាំ ទៅ ២ ( ពីរ ) ឆ្នាំ ។ ចំពោះអតិបរមានៃទោសនៃបទមជ្ឈិមដែលប្រព្រឹត្តលើកក្រោយនេះគឺត្រូវទ្វេដង ដែលមានន័យថាត្រូវយកគុណនិងពីរ ដោយយក ២ ( ពីរ ) ឆ្នាំ ទៅគុណនិងពីរដែលស្មើនិង ៤ ឆ្នាំ ។ ដូច្នេះតុលាការអាចសម្រេចដាក់ពន្ធនាគារគាត់ចំពោះបទមជ្ឈិមដែលប្រព្រឹត្តលើកក្រោយនេះចន្លោះពី ១ ឆ្នាំ ទៅ ៤ ឆ្នាំ ។

**៣**- កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទ មជ្ឈិម ដោយត្រូវជាប់ពន្ធនាគារស្មើ ឬ លើសពី ៣ ( បី ) ឆ្នាំ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋក្នុងរយៈពេល ៥ ( ប្រាំ ) ឆ្នាំ ។ មានន័យថាវាគឺជាស្ថានភាពមួយដែលចារីបានប្រព្រឹត្តបទល្មើសមួយដែលជាបទមជ្ឈិម និងត្រូវដាក់ពន្ធនាគាររយៈពេលស្មើរ ឬ លើសពី ៣ ( បី ) ឆ្នាំ ។បន្ទាប់ពីសាលក្រម សាដីការបានចូលជាស្ថាពររួចហើយ ប៉ុន្តែមិនទាន់ផុតរយៈពេល ៥ ឆ្នាំផងស្រាប់តែគាត់បានប្រព្រឹត្តបទល្មើសថ្មីមួយទៀតដែលជាបទ ឧក្រិដ្ឋ ដែលការប្រព្រឹត្តបទល្មើសលើកក្រោយនេះគឺវាចូលទៅក្នុងករណីមិនរាងចាល ហើយកាលណាចូលទៅក្នុងករណីមិនរាងចាលបែបនេះ គឺអតិបរមានៃទោសគឺត្រូវទ្វេដង ។

**៤**- កាលបើបុគ្គលណាម្នាក់ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈឹម បុគ្គលនោះបានប្រព្រឹត្តបទ មជ្ឈឹមដដែលក្នុងរយៈពេល ៥ ( ប្រាំ ) ឆ្នាំ ។រយៈពេល ១០ ( ដប់ ) ឆ្នាំ និង ៥ ( ប្រាំ ) ឆ្នាំ ចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសចំពោះបទល្មើសទី ១ ចូលជាស្ថាពរ ។

ឧទាហរណ៍៖ ( ក ) បានប្រព្រឹត្តបទល្មើសមួយដែលជាបទ មនុស្សឃាតដោយអចេតនា ( មាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ ) និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ ) ឆ្នាំ ទៅ ៣ ( បី ) ឆ្នាំ ។ តុលាការបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ៣ ឆ្នាំនៅថ្ងៃ ០១.០១. ២០១៤ ហើយសាលក្រមលើកទីមួយចូលជាស្ថាពរនៅថ្ងៃ ០១.០១.២០១៦ ។ក្រោយពីសាលក្រមជាស្ថាពរនៅ០១.០១.២០១៦ មក ឃើញថាមិនទាន់ហួសរយៈពេល ៥ ឆ្នាំផងគាត់ក៏បានទៅប្រព្រឹត្តបទល្មើសថ្មីមួយទៀតដែលជាបទ មនុស្សឃាតដោយអចេតនាដដែល យើងឃើញថាមិនទាន់ផុតរយៈពេល ៥ ឆ្នាំ ទេ ។ ករណីបែបនេះគឺជាករណីប្រព្រឹត្តបទមជ្ឈឹមដោយមិនរាងចាល ។ មួយវិញទៀតប្រសិនបើគាត់បានទៅប្រព្រឹត្តបទប្រទូសកេរខ្មាស ( មត្រា ២៤៦នៃក្រមព្រហ្មទណ្ឌ ) ។ លុះក្រោយមកគាត់បានទៅប្រព្រឹត្តបទប្រទូសកេរខ្មាសម្តងទៀតតាមមាត្រា ២៤៦នៃក្រមព្រហ្មទណ្ឌ ដដែល ។ ប៉ុន្តែមិនទាន់ហួសរយៈពេល ៥ ឆ្នាំទេ ។ បើដូចករណីនេះ គេក៏ហៅថាគាត់ប្រព្រឹត្តបទមជ្ឈឹមដោយមិនរាងចាលផងដែរ ។

ជារួមមកឲ្យតែមានកម្មវត្ថុ ឬ ប្រភេទនៃបទល្មើសដែលជាបទមជ្ឈឹម ដូចគ្នាដដែលៗដូចជាការប្រព្រឹត្តបទមនុស្សឃាតដោយអចេតនា បន្ទាប់មកប្រព្រឹត្តបទមនុស្សឃាតដោយអចេតនាម្តងទៀត ។ ប្រសិនបើមាន

ករណីបែបនេះកើតឡើង នោះគឺជាករណីនៃការប្រព្រឹត្តបទមជ្ឈិមដោយមិនរាងចាល និងមានចែងនៅក្នុងមាត្រា ២០៧នៃក្រមព្រហ្មទណ្ឌឆ្នាំ៣០០៩ ។ ប៉ុន្តែប្រសិនបើមានការប្រព្រឹត្តបទមនុស្សឃាតដោយអចេតនាម្តងហើយ លើកក្រោយបានប្រព្រឹត្តបទ លួច ( មាត្រា ៣៥៣នៃក្រមព្រហ្មទណ្ឌ ) វិញម្តង។ ចំពោះករណីបែបនេះឃើញថា ទោះបីជាប្រភេទបទល្មើស មជ្ឈិមដូចគ្នាក៏ដោយ ក៏វាមិនចូលទៅក្នុងករណីនៃការមិនរាងចាលនោះដែរ ដោយ ហេតុការមិនរាងចាលចំពោះបទមជ្ឈិមនៅទីនេះគឺសំដៅតែចំពោះប្រភេទនៃបទមឈ្ឃឹមដែលមានប្រភេទដូចគ្នា ដដែលតែប៉ុណ្ណោះ ។

មួយវិញទៀតចំពោះករណីនៃការគិតគូរអំពីរយៈពេល ១០ឆ្នាំ ឬ ៥ឆ្នាំ តើគេគិតចាប់ពីពេលណាមក ? គឺ គិតចាប់ពីពេលដែលសាលក្រមលើកទីមួយបានចូលជាស្ថាពរ ។ ប្រសិនបើសាលក្រមលើកទីមួយ ឬ ក៏សេចក្តី សម្រេចរបស់តុលាការពីមុនមិនទាន់បានចូលជាស្ថាពរនោះទេ នោះការប្រព្រឹត្តបទល្មើសបន្តទៅមុខទៀត មិន មែនជាការប្រព្រឹត្តបទល្មើសដែលចូលទៅក្នុងលក្ខខណ្ឌនៃការមិនរាងចាលនោះទេ ។

ឧទាហរណ៍ ៖ បុគ្គលម្នាក់គាត់បានទៅប្រព្រឹត្តបទល្មើសលួចបន្ទាប់មកគាត់ក៏ទៅប្រព្រឹត្ត បទល្មើស រំលោភលើទំនុកចិត្ត រួចហើយក៏ទៅប្រព្រឹត្តបទល្មើសមនុស្សឃាតដោយអចេតនាមួយទៀត ។ ហើយចំពោះបទ ល្មើសទាំងអស់នេះមិនទាន់មានសាលក្រមចូលជាស្ថាពរនៅឡើយទេ ដូច្នេះវាមិនមែនជាប្រភេទបទល្មើសដែល មិនរាងចាលនោះទេ ប៉ុន្តែវាគឺជាស្ថានភាពមួយដែលចូលទៅក្នុងលក្ខខណ្ឌបទល្មើសត្រួតគ្នាទៅវិញ។

មួយវិញទៀតសូមបញ្ជាក់ផងដែលថាការមិនរាងចាលនេះ មិនមែនឲ្យចៅក្រមពិចារណាទោស ហើយ គុណនិងពីរ ឬ ទ្វេដងនោះទេ គឺតុលាការអាចពិចារណាថាត្រូវផ្តន្ទាទោសប៉ុន្មាន បើលើសពីទោសធម្មតានោះ ហើយចៅក្រមអាចផ្តន្ទាទោសរហូតទៅដល់ទ្វេដងនៃទោសនោះ ប៉ុន្តែគាត់អាចផ្តន្ទាទោសនោះពីចន្លោះទោស ណាមួយចំពោះបទល្មើសដែលបានប្រព្រឹត្តនោះបាន ។

ជាក់ស្តែងដូចជាបទលួចដែលបានប្រព្រឹត្តនិងចូលទៅក្នុងករណីមិនរាងចាល ដែលត្រូវកំណត់ផ្តន្ទា ទោសដាក់ពន្ធនាគារពី ៦ ( ប្រាំមួយ ) ខែ ដល់ ៣ ( បី ) ឆ្នាំ ។ ចំពោះករណីបែបនេះគឺតុលាការពិចារណាកម្រិត ទោសដែលគាត់អាចប្រកាសបានចន្លោះពី ៦ ខែ ( ប្រាំមួយ ) ខែ ទៅ ៦ ( ប្រាំមួយ ) ឆ្នាំ ដោយយក ៣ ( បី ) ឆ្នាំ ទៅគុណនិង ២ ( ពីរ ) ។ ដូច្នេះចន្លោះនៃទោសដែលបានលើកឡើងខាងលើនេះគឺតុលាការអាចដាក់ទោស ប៉ុន្មានក៏បានដែរ គឺក្នុងចន្លោះនៃទោសដែលបានលើកឡើងខាងលើនេះ ប៉ុន្តែមិនអាចផ្តន្ទាទោសលើសពី ៦ ( ប្រាំមួយ ) ឆ្នាំ បានទេ ។ គាត់អាចផ្តន្ទាទោស ៣ ( បី ) ឆ្នាំ ក៏បាន ៤ ( បួន ) ឆ្នាំក៏បាន ប៉ុន្តែមិនអាចលើសពី ៦ ( ប្រាំមួយ ) ឆ្នាំ បានទេទោះបីវាជាករណីមិនរាងចាលក៏ដោយ ។

ហើយចំពោះករណីមិនរាងចាលបែបនេះ គឺតុលាការអាចផ្តន្ទាទោសបានលុះត្រាតែមានចែងយ៉ាងជាក់ លាក់នៅក្នុងលិខិតចោទប្រកាន់ដែលមានចែងនៅក្នុងមាត្រា ( មាត្រា ២៩១នៃ ) នៃក្រមនីតិវិធីព្រហ្មទណ្ឌតែ

ប៉ុណ្ណោះ ទើបតុលាការអាចប្រកាសទោសបាន ។ ហើយប្រសិនបើគ្មានចែងជាក់លាក់នៅក្នុងលិខិតចោទប្រកាន់ទេ នោះតុលាការមិនអាចនឹកឃើញ ឬ ផ្តន្ទាទោសដោយខ្លួនឯងបាននោះឡើយ ។

នៅក្នុងដំណាក់កាលនៃការចោទប្រកាន់ចំពោះកណីណាមួយដែលកំណត់ថាជាករណីមិនរាងចាល គឺនៅពេលដែរព្រះរាជអាជ្ញា ធ្វើដីការសន្និដ្ឋានស្ថាពរមក ហើយចៅក្រមសើបសួរគាត់បញ្ជូនរឿងមកជំនុំជម្រះ គឺមិនមានចែងជាក់លាក់អំពីស្ថានមិនរាងចាលនោះទេ ។ ដូចនេះនៅមុខសវនាការស្រាប់តែលេចហេតុភេទថ្មីមកឃើញថា ជននេះធ្លាប់បានប្រព្រឹត្តបទល្មើសពីមុនមកដែលចូលទៅក្នុងលក្ខខណ្ឌដែរមានចែងនៅក្នុងមាត្រា ៨៤ នៃក្រមព្រហ្មទណ្ឌ ដោយកំណត់ថាចំពោះករណីបែបនេះគឺជាករណីមិនរាងចាល ហើយគាត់ក៏ប្រកាសថាជាករណីមិនរាងចាល ការធ្វើបែបនេះគឺមិនត្រឹមត្រូវទេ ។ ការកំណត់ថាជាករណីមិនរាងចាលគឺលុះណាតែមានចែងយ៉ាងជាក់ច្បាស់នៅក្នុងលិខិតចោទប្រកាន់ដែលធ្វើតាមរយៈដីការបញ្ជូនមកជំនុំជម្រះរបស់ចៅក្រមសើបសួរ ឬក៏សាលដីការបញ្ជូនមកជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា ឬ តាមកំណត់ហេតុបង្ហាញខ្លួនភ្លាម ។ ទាំងអស់នេះទើបតុលាការអាចពិចារណាអំពីស្ថានមិនរាងចាលបាន ។

## ៣.២ .ស្ថានសម្រាលទោស

ជាគោលការណ៍ទោសត្រូវទទួលបាននូវស្ថានសម្រាល គឺអាស្រ័យទៅលើកាលៈទេសនៃបទល្មើស ឬ បុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ដែលនេះគឺជាគោលការណ៍មួយដែលនាំឲ្យមាននូវស្ថានសម្រាលទោស ។ ហើយមូលដ្ឋានគ្រឹះនៃស្ថានសម្រាលទោសនេះគឺមាននិយមន័យ នៃស្ថានសម្រាលទោស ទោសដាក់ពន្ធនាគារអស់មួយជីវិត និង ស្ថានសម្រាលទោស រួមទាំងមាននូវការបែងចែកខ្នាតនៃស្ថានសម្រាលទោសដែលអនុវត្តសម្រាប់រូបវន្តបុគ្គលជានីតិជន និង អនីតិជនផងដែរ ។

### ៣.២.១. មូលដ្ឋានគ្រឹះស្ថានសម្រាលទោស

យោងទៅតាមមាត្រា ៩៣ ដល់មាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបញ្ញត្តិអំពីស្ថានសម្រាលទោស និងបានកំណត់អំពីនិយមន័យនៃស្ថានសម្រាលទោស ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោសដែលជាមូលដ្ឋានគ្រឹះនៃស្ថានសម្រាលទោស ដែលនិងមានការបកស្រាយនៅផ្នែកខាងក្រោម ។

#### ៣.២.១.១. និយមន័យនៃស្ថានសម្រាលទោស

ដោយយោងទៅតាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ដែលបញ្ញត្តិអំពីស្ថានសម្រាលទោស មានន័យថា ៖

កាលណាកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឲ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស ។

ស្ថានសម្រាលទោសអាចត្រូវផ្តល់ឲ្យដល់ជនជាប់ចោទបានដែរទោះបីជាជននោះត្រូវបានប្រកាសថាស្ថិតក្នុងស្ថានភាពមិនរាងចាលក៏ដោយ ។ ដែលនេះគឺជាគោលការណ៍មួយដែលត្រូវបានផ្តល់អោយដោយការការពិចារណារបស់តុលាការ ដោយផ្អែកទៅលើស្ថានភាពមួយចំនួន ដូចជាបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ឬ ក៏ការលៈទេសៈនៃបទល្មើសតម្រូវ ដែលនាំឲ្យជនជាប់ចោទអាចទទួលបាននូវស្ថានសម្រាលទោស ។

### ៣.២.១.២. ទោសដាក់ពន្ធនាគារអស់មួយជីវិត និង ស្ថានសម្រាលទោស

ដោយយោងទៅតាមមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩នេះ ដែលបានបញ្ញត្តិអំពី ទោសដាក់ពន្ធនាគារអស់មួយជីវិត និង ស្ថានសម្រាលទោសបានចែងថា ៖

កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសដាក់ទោសដាក់ពន្ធនាគារក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ ) ឆ្នាំ និង ៣០ ( សាមសិប ) ឆ្នាំ ។

ដោយផ្អែកតាមមាត្រាខាងលើយើងអាចធ្វើការបកស្រាយបានថាវាគឺជាករណីមួយដែលបទល្មើសមួយត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតហើយ ប៉ុន្តែដោយមាននូវស្ថានភាពមួយចំនួនដែលតុលាការពិនិត្យឃើញថា បុគ្គលនោះត្រូវទទួលបាននូវស្ថានសម្រាលទោសដែលជាស្ថានភាពមួយជួយឲ្យគាត់ទទួលបាននូវទោសមួយដែលមានភាពធូរស្រាលជាងមុន ហើយកាលណាគាត់ទទួលបាននូវស្ថានសម្រាលទោសដែលមានភាពធូរស្រាលជាងមុនបែបនេះ នោះចៅក្រមគាត់អាចប្រកាសទោសចំពោះគាត់បានចន្លោះពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ ។

មួយវិញទៀតចំពោះទោសដែលដាក់ពន្ធនាគារអស់មួយជីវិត ដោយយោងតាមក្រមព្រហ្មទណ្ឌដដែលនេះចំពោះទោសដាក់ពន្ធនាគារអស់មួយជីវិតនេះគឺមានដូចខាងក្រោម ៖

- បទឧក្រិដ្ឋប្រល័យពូជសាសន៍ ( មាត្រា ១៨៣ និង មាត្រា ១៨៤នៃក្រមព្រហ្មទណ្ឌ )
- បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ( មាត្រា ១៨៨ និង មាត្រា ១៨៩ នៃក្រមព្រហ្មទណ្ឌ )
- បទឧក្រិដ្ឋសង្គ្រាម ( មាត្រា ១៩៣ ដល់ មាត្រា ១៩៥ នៃក្រមព្រហ្មទណ្ឌ )
- បទឃាតកម្មគិតទុកជាមុន ( មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ )
- បទឃាតកម្មដោយមានទារុនកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ ( មាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ )
- បទរាជឃាតកម្ម ( មាត្រា ៤៣៣ នៃក្រមព្រហ្មទណ្ឌ )
- បទប្រគល់ឲ្យរដ្ឋបរទេសនូវដែនដីជាតិ ទាំងស្រុង ឬ មួយផ្នែក ( មាត្រា ៤៤០ នៃក្រមព្រហ្មទណ្ឌ )
- បទប្រគល់ឲ្យរដ្ឋបរទេសនូវកងយុទ្ធពលខេមរៈភូមិន្ទ ( មាត្រា ៤៤១ នៃក្រមព្រហ្មទណ្ឌ )

- បទឃុបឃាតដោយមានស្ថានទម្ងន់ទោសដែលទាក់ទងទៅនិងជនល្មើស ( មាត្រា ៤៥២ នៃក្រមព្រហ្មទណ្ឌ )

ដែលបទល្មើសទាំងអស់ខាងលើនេះ គឺជាប្រភេទនៃបទល្មើសឧក្រិដ្ឋដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ និងជាប្រភេទនៃបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

### ៣.២.២. ខ្លាតនៃស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលជានីតិជន និងអនីតិជន

ដោយយោងទៅតាមមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដដែលនេះដែលចែងអំពីអានុភាពនៃស្ថានសម្រាលទោសសម្រាប់អនីតិជន និង ដោយដោយផ្អែកទៅតាមមាត្រា ១៦៤ ដែលស្តីអំពីការទទួលផលប្រយោជន៍នៃស្ថានទោសសម្រាប់អនីតិជន។

ជាងនេះទៅទៀតនៅក្នុងមាត្រា ៩៤ និង មាត្រា ១៦៤នៃក្រមព្រហ្មទណ្ឌ ទោសដែលអនុវត្តសម្រាប់រូបវន្តបុគ្គលដែលជានីតិជន និង អនីតិជនច្បាប់ក៏បានកំណត់អំពីស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលទាំងពីខាងលើផងដែរ ដែលយើងនិងធ្វើការបែងចែកជាពីផ្នែក និង ធ្វើការបកស្រាយដូចខាងក្រោម ។

#### ៣.២.២.១. ខ្លាតនៃស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលជានីតិជន

ចំពោះរូបវន្តបុគ្គលដែលជានីតិជនជននេះជាគោលការណ៍ តុលាការតែងតែគិតគូរទៅលើស្ថានសម្រាលទោស នៅក្នុងកម្រិតអប្បបរមានៃទោសដែលច្បាប់បានកំណត់ចំពោះបទល្មើសដែលបានប្រព្រឹត្ត ។ បន្ថែមលើសពីនេះទៅទៀតនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ យើងនេះក៏បានចែងឲ្យតុលាការអាចគិតគូរបន្ធូរបន្ថយទោសក្រោមអប្បបរមានៃទោសដែលត្រូវបានកំណត់នៅក្នុងច្បាប់ដែលពាក់ព័ន្ធនិងបទល្មើសដែលបានប្រព្រឹត្ត ដែលទាក់ទងទៅនិងបុគ្គលិកលក្ខណៈនៃជនល្មើសល្មើស ការលៈទេសៈនៃបទល្មើសជាដើម ដែលនេះជាគោលការណ៍មួយដែលនាំឲ្យមាននូវស្ថានសម្រាលទោស ។

ឧទាហរណ៍ ៖ ស្ថានសម្រាលទោសដែលទាក់ទងទៅនិងបុគ្គលិកលក្ខណៈរបស់ជនចារីះ

គឺជារូបភាពមួយដែលបទល្មើសត្រូវបានប្រព្រឹត្តិឡើងដោយ កូនក្មេងដែលជាអនីតិជនដែលទើបនិងប្រព្រឹត្តបទល្មើសជាលើកដំបូងជាដើម ។ ចំពោះកាលៈទេសៈនៃបទល្មើស គឺជាស្ថានភាពមួយដែលតម្រូវនៅក្នុងការប្រព្រឹត្តបើទោះបីជាចារីមិនចង់ក្នុងការប្រព្រឹត្តក៏ដោយ ប៉ុន្តែដោយហេតុវាគឺជាស្ថានភាពមួយដែកាលៈទសៈតម្រូវនៅក្នុងការប្រព្រឹត្តបទល្មើស ដែលកាលៈទេសៈនេះបង្ហាញឡើងក្នុងគោលបំណងការពារពារខ្លួន ការពារទ្រព្យសម្បត្តិរបស់ខ្លួន របស់អ្នកដ៏ទៃ ចំពោះការលបលួចចូលនៅពេលយប់ជាអាទិ៍ ។ទាំងអស់នេះសុទ្ធតែជាស្ថានភាពមួយដែលជួយឲ្យមាននូវស្ថានសម្រាលទោសទោះបីជាចារីបានប្រព្រឹត្តបទល្មើសក៏ដោយ ។

ហើយជាគោលការណ៍ ការដែលត្រូវទទួលបាននូវស្ថានសម្រាលទោសនេះគឺត្រូវបានកំណត់នៅក្នុងខ្នាតមួយដែលច្បាប់បានកំណត់ជាដាក់លាក់ ដោយចៅក្រមមិនអាចធ្វើការប្រកាសទោសដោយដែលត្រូវបានទទួលនូវស្ថានសម្រាលនេះ ក្រោមអប្បបរមាដែលច្បាប់បានកំណត់នោះទេ ។

ខ្នាតនៅក្នុងការប្រកាសទោសដែលត្រូវបានទទួលនូវស្ថានសម្រាលនោះគឺត្រូវបានកំណត់ដូចខាងក្រោម ៖

យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ដែលបញ្ញត្តិអំពីអានុភាពនៃស្ថានសម្រាលទោសដែលបានបញ្ញត្តិដូចខាងក្រោម ៖[67]

កាលណាតុលាការផ្ដល់ឲ្យជនជាប់ចោទនូវស្ថានសម្រាលទោស អប្បបរមានៃស្ថានសម្រាលទោសចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈឹម ត្រូវបន្ថយតាមខ្នាតដូចខាងក្រោម ៖

១- ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១០ ( ដប់ ) ឆ្នាំ អប្បបរមានេះត្រូបបន្ថយមកត្រឹម ២ ( ពីរ ) ឆ្នាំ ។

ឧទាហរណ៍ ៖ ប្រសិនបើជនម្នាក់គាត់បានប្រព្រឹត្តបទល្មើសមួយ ហើយច្បាប់បានកំណត់ថាត្រូវផ្ដន្ទាទោសពី ១០ ( ដប់ ) ឆ្នាំ ទៅ ១៥ ( ដប់ប្រាំ ) ឆ្នាំ ។ ដែលនេះឃើញថាអប្បបរមានៃទោសនោះគឺ ១០ ឆ្នាំ ។ ប្រសិនបើមានករណីបែបនេះ ហើយតុលាការរកឃើញថាមាននូវស្ថានសម្រាលទោសដែលច្បាប់បានកំណត់ជាធម្មតា និង តិចជាង ១០ ( ដប់ ) ឆ្នាំ នោះ តុលាការអាចកំណត់ដាក់ទោសគាត់ដែលអាចបន្ធូរបន្ថយបានចាប់ពី ៩ . ៨ . ៧ . ៦ . ៥ . ៤ . ៣ .២ ឆ្នាំបាន តុលាការអាចដាក់ទោសគាត់បានក្នុងចំណោមទោសដែលត្រូវទទួលរងខាងលើនេះបាន ប៉ុន្តែមិនអាចក្រោម ២ ឆ្នាំនោះទេ ។

២- ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៥ ( ប្រាំ ) ឆ្នាំ ហើយតិចជាង ១០ ( ដប់ ) ឆ្នាំ អប្បបរមានៃទោសនេះត្រូវបន្ថយមកត្រឹម ១ ( មួយ ) ឆ្នាំ ។

ឧទាហរណ៍ ៖ ប្រសិនបើជានម្នាក់គាត់បានប្រព្រឹត្តបទល្មើស និង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ពី ៧ ឆ្នាំ ទៅ ១៥ ឆ្នាំ ដែលជាប្រភេទបទល្មើសតាម ( មាត្រា ២១០នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ) បទទារុនកម្មនិងអំពើឃោរឃៅ ។ ហើយប្រសិនបើចៅក្រមរកឃើញថាមានស្ថានសម្រាលទោសនោះ ចៅក្រមអាចបន្ធូបន្ថយទោសគាត់បានមកសល់ត្រឹម ១ ឆ្នាំ ដែលមួយឆ្នាំនេះមិនមែនមានន័យថាត្រូវបន្ថយមកសល់មួយឆ្នាំនោះទេ ប៉ុន្តែគឺជាឆន្ទានុសិទ្ធរបស់ចៅក្រមនៅក្នុងការផ្ដន្ទាទោសគាត់ដែលបន្ថយពី ៦. ៥ . ៤ .៣ . ២ . ១. ដែលមួយឆ្នាំនេះគឺជាស្ថានសម្រាលទោសដែលត្រូវបន្ថយ ហើយបន្ថយនេះមិនអាចតិចជាងមួយឆ្នាំនោះទេ ហើយតុលាការក៏អាច

[67] មាត្រា៩៤នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ជ្រើសរើសដាក់ទោសគាត់បានក្នុងចំណោមទោសដែលបានបន្ថយខាងលើ មិនមែនត្រូវតែផ្តន្ទាទោសគាត់មួយឆ្នាំនោះទេ ។

៣- ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ ( ពីរ ) ឆ្នាំ ហើយតិចជាង ៥ ( ប្រាំ ) ឆ្នាំ អប្បបរមានៃទោសត្រូវបន្ថយមកត្រឹម ៦ ( ប្រាំមួយ ) ខែ ។

ឧទាហរណ៍ ៖ យោងតាមមាត្រា ២៨៤នៃក្រមព្រហ្មទណ្ឌ បទសញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ ។ ហើយប្រសិនបើចៅក្រមរកឃើញថាមាននូវស្ថានសម្រាលទោសគឺគាត់អាចបន្ថយមកត្រឹម ៦ ( ប្រាំមួយ ) ខែ ដែល ៦ ខែ នេះមិនមែនមានន័យថាត្រូវយកមមកផ្តន្ទាទោសដាក់ពន្ធនាគារគាត់ ៦ ខែតែម្តងនោះទេ គឺចៅក្រមអាចផ្តន្ទាទោសគាត់បានក្នុងចន្លោះ ពី ១ ឆ្នាំ និង ៦ ខែ ឬ មួយឆ្នាំគត់ ឬ អាចផ្តន្ទាទោស ៦ ខែតែម្តង និងមិនអាចតិចជាង ៦ ខែ នោះទេ ។

៤- ប្រសិនបើអប្បបរមានៃទោសស្មើ ឬ លើសពី ៦ ( ប្រាំមួយ ) ថ្ងៃ ហើយតិចជាង ២ ( ពីរ ) ឆ្នាំ អប្បបរមានៃទោសនេះត្រូវបន្ថយមកត្រឹម ១ ( មួយ ) ថ្ងៃ ។

ឧទាហរណ៍ ៖ ជនម្នាក់បានប្រព្រឹត្តបទល្មើសតាមមាត្រា ៥៤១នៃក្រមព្រហ្មទណ្ឌ ( បទបដិសេធមិនស្តាប់បង្គាប់បញ្ជា ) និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ( ប្រាំមួយ ) ថ្ងៃទៅ ៣ ( បី ) ខែ ។ យើងឃើញថាអប្បបរមានៃទោសដាក់ពន្ធនាគារដែលច្បាប់បានកំណត់ចំពោះបទល្មើសនេះគឺ ៦ ( ប្រាំមួយ ) ថ្ងៃ ។ ហើយចំពោះបទល្មើសខាងលើនេះប្រសិនបើតុលាការរកឃើញថាមាននូវស្ថានសម្រាលទោសសម្រាប់ចារីដែលត្រូវទទួលនោះ មានភាពធូរស្រាលនៅក្រោមអប្បបរមានៃទោសដែលច្បាប់បានកំណត់ជាធម្មតានោះគឺ ៦ ( ប្រាំមួយ ) ថ្ងៃ នោះចៅក្រមអាចបន្ធូរបន្ថយរហូតមកដល់ទាបជាងគេគឺ ១ ថ្ងៃ ។ មានន័យថាគាត់អាចផ្តន្ទាទោសគាត់បានចាប់ពី ៥ ថ្ងៃ, ៤ថ្ងៃ , ៣ថ្ងៃ ,២ថ្ងៃ , ១ថ្ងៃ , ដែលទាបជាងគេគឺ ១ ថ្ងៃ ហើយមិនអាចផ្តន្ទាទោសគាត់ក្រោម ១ ថ្ងៃ បាននោះទេ ។ ដែលទាំងអស់នេះគឺជាទោសដែលអនុវត្តសម្រាប់ទោសដាក់ពន្ធនាគារ ។

ដោយឡែកចំពោះទោសពិន័យជាប្រាក់វិញគឺមានកំណត់នៅក្នុងមាត្រា ៩៤នៃក្រមព្រហ្មទណ្ឌ ចំណុចទី ៥ ដែលយើងនិងបង្ហាញដូចខាងក្រោម ៖

៥-អប្បបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយមកត្រឹមពាក់កណ្តាលៈ

ជាឧទាហរណ៍ ៖ យោងទៅតាមមាត្រា ២៩៨ នៃក្រមព្រហ្មទណ្ឌដដែលនេះដែលបញ្ញត្តិអំពីបទ ហៅអ្នកដទៃនៅទីសាធារណៈ ។ ហើយចំពោះបទល្មើសនេះគឺមានត្រឹមតែទោសពិន័យជាប្រាក់តែប៉ុណ្ណោះ ដែលច្បាប់បានកំណត់ថាត្រូវផ្តន្ទាទោសពីន័យជាប្រាក់ពី ៥.០០០ ( ប្រាំពាន់ ) រៀល ទៅ ៥.០០០០ ( ប្រាំម៉ឺន ) រៀល ។ ឃើញថាអប្បបរមានៃទោសពិន័យជាប្រាក់នេះត្រឹមតែ ៥.០០០ ( ប្រាំពាន់ ) រៀលប៉ុណ្ណោះ ។ ដូច្នេះប្រសិនបើ

ចៅក្រមរកឃើញថាត្រូវមានស្ថានសម្រាល គាត់អាចបន្ថយមកត្រឹមពាក់កណ្ដាលអប្បបរមានៃ ៥.០០០ ( ប្រាំពាន់ ) រៀល មកត្រឹមតែ ២.៥០០ ( ពីរពាន់ប្រាំរយ ) រៀលប៉ុណ្ណោះ ។

មួយវិញទៀតចំពោះទោសដាក់ពន្ធនាគារអស់មួយជីវិត គឺមានបញ្ញត្តិនៅក្នុងមាត្រា ៩៥ នៃក្រមដែលនេះដែលបានបញ្ញត្តិអំពីទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស ដែលមានន័យថា ៖

កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់

ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារក្នុងចន្លោះរវាង ១៥ ( ដប់ប្រាំ ) ឆ្នាំ និង ៣០ ( សាមសិប ) ឆ្នាំ ។

ដែលទាំងអស់នេះគឺជាការទទួលបាននូវស្ថានសម្រាល សម្រាប់ការអនុវត្តចំពោះនីតិជនដែលបានប្រព្រឹត្តបទល្មើស ។

**៣.២.២.២.ខ្នាតនៃស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលជាអនីតិជន**

ដោយយោងទៅតាមមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌនេះយើងឃើញថាគឺមានបង្ហាញយ៉ាងជាក់លាក់អំពីស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលដែលជាអនីតិជន និងមានខ្លឹមសារដូចខាងក្រោម ៖

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ៖

កាលបើតុលាការសម្រេចឲ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោសលើអនីតិជនពីបទឧក្រិដ្ឋ ឬ បទមជ្ឈឹមត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១- ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១០ (ដប់ ) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកនៅត្រឹម ១ ( មួយ ) ឆ្នាំ ។

២- ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៥ ( ប្រាំ ) ឆ្នាំ និងតិចជាង ១០ ( ដប់ ) ឆ្នាំ នោះអប្បបរមានត្រូវបន្ថយមកត្រឹម ៦ ( ប្រាំមួយ ) ខែ ។

៣-ប្រសិនបើអប្បបរមាននៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ២ ( ពីរ ) ឆ្នាំ និងតិចជាង ៥ ( ប្រាំ ) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកត្រឹម ៣ ( បី ) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៦ ( ប្រាំមួយ ) ថ្ងៃ និងតិចជាង ២ ( ពីរ ) ឆ្នាំ នោះអប្បបរមានត្រូវបន្ថយមកត្រឹម ១ ( មួយ ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្ដាល ។

ដែលទាំងអស់នេះគឺជាខ្នាតនៃទោសដែលចៅក្រមត្រូវយកទៅអនុវត្តសម្រាប់ អនីតិជន ហើយខ្នាតសម្រាលទោសសម្រាប់អនីតិជននេះគឺមានស្ថានសម្រាលខុសពី នីតិជន ។ ស្ថានសម្រាលទោសសម្រាប់អនីតិជនគឺស្មើរនិងពាក់កណ្ដាលនៃស្ថានសម្រាលសម្រាប់នីតិជន ។

ឧទាហរណ៍ ៖ បទល្មើសមួយត្រូវបានប្រព្រឹត្តដោយនីតិជន និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ ។ ប៉ុន្តែដោយរកឃើញថាមាននូវស្ថានសម្រាលទោសនោះ នោះទោសដែលត្រូវយកមកអនុវត្តសម្រាប់នីតិជននោះគឺត្រឹមតែ ២ ឆ្នាំប៉ុណ្ណោះ ។ ដោយឡែកប្រសិនបើបទល្មើសនេះត្រូវបានប្រព្រឹត្តដោយ អនីតិជនវិញ ឃើញថាទោសដែលត្រូវយកមកអនុវត្តសម្រាប់អនីតិជននៅទីនេះគឺត្រឹមតែ ១ ( មួយ ) ឆ្នាំប៉ុណ្ណោះ ( ស្មើនិងពាក់កណ្តាលនៃទោសដែលអនុវត្តសម្រាប់នីតិជន ) ។

មួយវិញទៀតចំពោះបទបញ្ញត្តិដែលស្តីអំពីការមិនរាងចាលគឺមិនត្រូវយកមកអនុវត្តចំពោះអនីតិជននោះទេទោះបីជាចូលក្នុងមាត្រា ៨៤ នៃក្រមព្រហ្មទណ្ឌដដែលនេះក៏ដោយ ។ ហើយដោយយោងទៅតាមមាត្រា ១៦៣ នៃក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិយ៉ាងច្បាស់ថា ស្ថានមិនរាងចាលមិនត្រូវបានយកទៅអនុវត្តចំពោះអនីតិជននោះទេ ។

ដែលនេះគឺមានចែងយ៉ាងជាក់ច្បាស់ អំពីទោសដែលត្រូវអនុវត្តសម្រាប់អនីតិជន និង លក្ខខណ្ឌមួយចំនួនដែលមិនត្រូវយកមកអនុវត្តសម្រាប់អនីតិជន ដូចមានចែងក្នុងមាត្រា ៨៤នៃក្រមព្រហ្មទណ្ឌ ( លក្ខខណ្ឌនៃការមិនរាងចាល ) និង មាត្រា ១៦៣នៃក្រមព្រហ្មទណ្ឌ ( ការមិនអនុវត្តបទបញ្ញត្តិស្តីពីការមិនរាងចាល ) នៃក្រមនេះជាអាទិ៍ ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជារួមមកយើងឃើញថា ប្រភេទនៃទោសព្រហ្មទណ្ឌដែលកំណត់ដោយ ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នៃព្រះរាជាណាចក្រកម្ពុជាយើង គឺមានការបែងចែកប្រភេទនៃទោសព្រហ្មទណ្ឌជាបីខុសៗគ្នា ដែលមានដូចជា មូលទោស ទោសជំនួស ទោសបន្ថែម ដែលទោសទាំងបីប្រភេទនេះ គឺជាប្រភេទនៃទោសដែលតុលាការយកទៅអនុវត្តចំពោះរូបវន្តបុគ្គលដែលបានប្រព្រឹត្តបទល្មើសណាមួយ ។ មួយវិញទៀតដោយយោងទៅតាមមាត្រា ៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាយើងឆ្នាំ ២០០៩ គឺបានបង្ហាញយ៉ាងច្បាស់អំពីការអនុវត្តទោសដោយបញ្ញត្តិថា មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងយ៉ាងជាក់ច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌជាធរមាននៅពេលដែលអំពើនោះបានប្រព្រឹត្តប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចត្រូវប្រកាសបាន ។ ដែលនេះសរបញ្ជាក់ឲ្យឃើញថាដោយយោងទៅតាមមាត្រានេះក្រមព្រហ្មទណ្ឌយើងមានចែងយាងជាក់ច្បាស់អំពីគោលការណ៍នៃការអនុវត្តន៍ ទោសក៏ដូចជាគោលការណ៍នៅក្នុងការប្រកាសទោសជាដើម ដោយកំណត់អំពីប្រភេទនៃទោសដែលអាចត្រូវផ្តន្ទាទោស និង កំណត់អំពីប្រភេទនៃទោសដែលត្រូវប្រកាស ។ ចំណែកឯទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គលវិញ គឺមានភាពខុសគ្នាអំពីទោសដែលអនុវត្តសម្រាប់រូបវន្តបុគ្គល ដែលក្នុងនោះឃើញថាទោសដែលអនុវត្តសម្រាប់នីតិបុគ្គលគឺមានតែទោសមួយចំនួនប៉ុណ្ណោះដូចជា ទោសពិន័យក្នុងឋានៈជាមូលទោស ( មាត្រា ១៩៦ ) នៃក្រមព្រហ្មទណ្ឌ និង ទោសបន្ថែមទាំង ១៤ ចំណុចដូចមានចែងនៅក្នុង ( មាត្រា ១៦៨ ) នៃក្រមព្រហ្មទណ្ឌ។ ហើយចំពោះនីតិបុគ្គនេះផងដែរ គឺមានការបែងចែកជាពីរគឺ នីតិបុគ្គលដែលជារដ្ឋ និង នីតិបុគ្គលឯកជន ។ ចំពោះមូលទោសវិញគឺត្រូវបានកំណត់យ៉ាងជាក់ច្បាស់នៅក្នុងមាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ ដែលបានកំណត់អំពីមូលទោសក្នុងប្រភេទជាដាក់ពន្ធនាគារ និងមូលទោសក្នុងប្រភេទទោសពិន័យជាប្រាក់ ។ ចំណែកឯទោសបន្ថែមវិញគឺត្រូវបានបញ្ញត្តិនៅក្នុងមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌដដែលនេះដូចគ្នា ដោយទោសបន្ថែមនៅទីនេះមានចំនួន ១៩ ចំណុចដែលសម្រាប់បន្ថែមទោលើមូលទោស ។ ចំពោះទោសជំនួសវិញគឺចែងសម្រាប់ជំនួសឲ្យមូលទោស ដែលមានទោសការងារសហគមន៍ ដែលកំណត់ក្នុង ( មាត្រា ៧២ ) និង ទោសស្តីបន្ទោស ដែលកំណត់ក្នុង ( មាត្រា ៧៦ ) នៃក្រមព្រហ្មទណ្ឌ។ ហើយជាទូទៅមូលទោសត្រូវបានកំណត់ពីអប្បបរមា និង អតិបរមា ដែលជាការកំណត់ចំពោះទោសដាក់ពន្ធនាគារ និង ទោសពិន័យជាប្រាក់ ដោយក្នុងនោះក៏មាននូវការកំណត់អំពីស្ថានទម្ងន់ទោស និង ស្ថានសម្រាលទោសផងដែរ ។ ចំពោះអំពើដែលត្រូវបានទទួលនូវស្ថានទម្ងន់ទោសគឺអាស្រ័យលើការកំណត់ដោយច្បាប់ជាអ្នកកំណត់ ដោយកំណត់ទៅលើ ( ចរិតគ្រោះថ្នាក់នៃអំពើល្មើស និងការមិនរាងចាលជាដើម ) ។ ចំណែកឯស្ថានសម្រាលទោសវិញគឺច្បាប់បានកំណត់អំពីខ្នាតនៃស្ថានសម្រាលទោស ដោយកំណត់អំពីស្ថាន

សម្រាលទោសសម្រាប់រូបវន្តបុគ្គលដែលជានីតិជន និង ស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលដែលជាអនីតិជន ។ ទោសព្រហ្មទណ្ឌច្បាប់ក៏បានកំណត់អំពីការប្រកាសទោសផងដែរ ដោយជាទូទៅការប្រកាសទោសគឺគេធ្វើការប្រកាសចំពោះមូលទោស ទោសបន្ថែម និងទោសជំនួស ។ ហើយចំពោះការប្រកាសមូលទោស គឺមានទោសដាក់ពន្ធនាគារ និង ទោសពិន័យជាប្រាក់ និងមានទាំងទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង ។ ចំណែកឯការប្រកាសទោសបន្ថែមគឺគេប្រកាសទោសនេះដើម្បីបន្ថែមទៅលើមូលទោស និងជាការប្រកាសទោសបន្ថែមដើម្បីជំនួសមូលទោស ។ ចំពោះការប្រកាសទោសជំនួស គឺប្រកាសចំពោះការងារសហគមន៍ និងទោសស្តីបន្ទោស ។

ការប្រកាសទោសទាំងអស់ខាងលើនេះគឺត្រូវគោរពទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើរួចមក ដើម្បីឲ្យយើងយល់ដឹងកាន់តែច្បាស់នោះ គឺយើងចាំបាច់ត្រូវតែសិក្សាទៅលើគន្ថីទី១ ដែលនិយាយអំពីបទប្បញ្ញត្តិទូទៅ និងត្រង់មាតិកាទី៣ ដែលនិយាយអំពី “ ទោស “ ហើយចំពោះជំពូកទី១វិញនោះ គឺ និយាយអំពី “ ប្រភេទនៃទោស “ ព្រហ្មទណ្ឌឆ្នាំ ២០០៩។

## ស្ថានភាពទូទៅនៃទោសព្រហ្មទណ្ឌ

១. អត្ថន័យនៃទោសព្រហ្មទណ្ឌ គឺសិក្សាទៅលើអត្ថន័យ តាមបែបទស្សនៈវិជ្ជា ឬសង្គមវិជ្ជា។ ហើយន័យម្យ៉ាងទៀតនោះ គឺសិក្សាតាមបែបគតិយុត្ត និងតាមបែបនីតិសាស្ត្រ។

២. ចរិកលក្ខណៈនៃទោសព្រហ្មទណ្ឌ គឺសំដៅដល់ភាពច្បាស់លាស់ បានសេចក្តីថា “ ទោស” បានកំណត់ដោយច្បាប់ ហើយត្រូវបានប្រកាសដោយ តុលាការ។

៣. មុខងារនៃទោសព្រហ្មទណ្ឌ រួមមាន៖ មុខងារបង្ក្រាប សំដៅដល់ការដាក់ទណ្ឌកម្ម មុខងារ បង្ការ គឺភាពបន្លាចតាមរយៈបំភិតបំភ័យ មុខងារ អប់រំ ឬកែប្រែ។

៤. ផលវិបាកនៃទោសព្រហ្មទណ្ឌ គឺជាផលប៉ះពាល់ដែលធ្លាក់ទៅលើ ចំពោះទណ្ឌិតខ្លួនផ្ទាល់ ចំពោះក្រុមគ្រួសារ និងចំពោះសង្គមជាតិ។

## ប្រភេទនៃទោសព្រហ្មទណ្ឌ

១. ទោសសម្រាប់អនុវត្តទៅលើរូបវន្តបុគ្គល រួមមាន មូលទោស ទោសជំនួស និងទោសបន្ថែម។

២. ទោសសម្រាប់អនុវត្តទៅលើនីតិបុគ្គល៖ ទោសពិន័យក្នុងឋានជាមូលទោស រួមទាំងទោសបន្ថែមទាំង១៤ចំណុច។

៣. ស្ថានទម្ងន់ទោស៖ ចរិកគ្រោះថ្នាក់នៃអំពើរបស់ជនល្មើស និងការមិនរាងចាល។

៤. ស្ថានសម្រាលទោស៖ មូលដ្ឋានគ្រឹះនៃស្ថានសម្រាលទោស និងខ្នាតនៃស្ថានសម្រាលទោសសម្រាប់រូបវន្តបុគ្គលជា នីតិជន និងអនីតិជន។

# ឯកសារយោង

## ឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣។

២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ ចុះថ្ងៃទី ៣០ វិច្ឆិការ ឆ្នាំ ២០០៩ ។

៣. ច្បាប់ស្តីអំពីវិសោធនកម្ម និង ច្បាប់ស្តីអំពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ។

៤. ច្បាប់ស្តីអំពីការប្រឆាំងអំពើពុករលួយចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ ។

៥. សន្ទានុក្រមពាក្យច្បាប់ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១ ។

៦. សន្ទានុក្រមផ្នែកច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី ០៨ ឧសភា ឆ្នាំ ២០០៨ ។

៧. តាមប្រសាសន៍របស់ឯកឧត្តម កើនរិទ្ធ “ ស្តីអំពីទោសស្តីបន្ទោស ” ឆ្នាំ ២០១០ ។

៨. តាមប្រសាសន៍របស់ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ “ ស្តីអំពីទោសជំនួស ” ។

៩. តាមប្រសាសន៍ ឯកឧត្តម ហ៊ី សោភា “ ស្តីពីប្រភេទនៃទោសជំនួស ” ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១០ ។

១០. រៀបរៀងដោយសាស្ត្រាចារ្យ កៅសីហា ។

១១. រៀបរៀងដោយ លោក សែនសារ៉េង ។

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

**នស/រកម/១១០៩/០២២**

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ក្រមព្រហ្មទណ្ឌ

# គន្ថីទី ១
# បទប្បញ្ញត្តិទូទៅ
## មាតិកាទី ១
## ច្បាប់ព្រហ្មទណ្ឌ
### ជំពូកទី ១
### គោលការណ៍ទូទៅ

**មាត្រា ១.-** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថា ជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្ដន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ២.-** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់បញ្ញត្តថា អំពើខ្វះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ ។

**មាត្រា ៣.-** គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្ដន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.-** ចេតនាប្រព្រឹត្តបទល្មើស

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

ប៉ុន្តែ ក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។

**មាត្រា ៥.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ ។

**មាត្រា ៦.-** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ ។

**មាត្រា ៧.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៨.-** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ៩.-** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ចប់ ។

ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត ។

**មាត្រា ១០.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬធ្ងន់ជាង

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែ ការផ្តន្ទាទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។

**មាត្រា ១១.-** សុពលភាពនៃកិច្ចនីតិវិធី

ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ ។

## ជំពូកទី ៣
## ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ
### ផ្នែកទី ១
### បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១២.-** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៣.-** ទីកន្លែងប្រព្រឹត្តបទល្មើស

បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅ

ពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៥.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ ។

**មាត្រា ១៦.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៧.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះត្រូវបានបំពេញ :

-បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង

-អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស ។

**មាត្រា ១៨.-** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល ។

## ផ្នែកទី ២
## បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩.-** បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ នៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។

បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ ។

**មាត្រា ២០.-** ជនរងគ្រោះជាជនជាតិខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេស ទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

**មាត្រា ២១.-** ការធ្វើបណ្តឹងចោទប្រកាន់

នៅក្នុងករណីដែលមានចែងនៅក្នុងមាត្រា ១៩ (បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ) និងមាត្រា ២០ (ជនរងគ្រោះជាជនជាតិខ្មែរ) នៃក្រមនេះ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ ។ ការ

ចោទប្រកាន់ត្រូវតែមានបណ្តឹងពីជនរងគ្រោះ ឬពីសិទ្ធិវន្ត ឬបណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត ។

**មាត្រា ២២.-** សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា :

១-បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ។

២-បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។

៣-បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

៤-បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

៥-បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣.-** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២
## ការទទួលខុសត្រូវព្រហ្មទណ្ឌ
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

## មាត្រា ២៥.- និយមន័យនៃចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

## មាត្រា ២៦.- និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

## មាត្រា ២៧.- និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង

-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ ។

## មាត្រា ២៨.- និយមន័យនៃអ្នកផ្តើមគំនិត

ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែល :

១-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា។

២-បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន ។

អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។

## មាត្រា ២៩.- និយមន័យនៃអ្នកសមគំនិត

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួល ដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន ។

អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។

## មាត្រា ៣០.- និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត

១-អ្នករាជការសាធារណៈ មានន័យថា ៖

ក/ បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្តីដោយមិនគិតពី ឋានៈ អាយុរបស់បុគ្គលនោះឡើយ ។

ខ/ បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថា ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២
## មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.-** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ ។

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចធារណ៍នៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណ៍នេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.–** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។

**មាត្រា ៤០.–** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្ដិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.–** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្ដីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

## ជំពូកទី ៤
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍ របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុស ត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣
## ទោស
## ជំពូកទី ១
## ប្រភេទនៃទោស
## ផ្នែកទី ១
## មូលទោស

**មាត្រា ៤៣.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និង អតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

**មាត្រា ៤៥.-** ការទម្ងន់ទោស និងការសម្រាលទោស

អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចបន្ថែម ឬបន្ថយនៅក្នុងលក្ខខណ្ឌដែលចែងដោយក្រមនេះ ។

**មាត្រា ៤៦.-** និយមន័យនៃបទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ :

១-ជាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៧.-** និយមន័យនៃបទមជ្ឈិម

បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៨.-** និយមន័យនៃបទលហុ

បទល្មើសជាបទលហុ នៅក្នុងករណីដែល :

១-អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

២-បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

**មាត្រា ៤៩.-** ការគណនាអំពីថិរវេលានៃទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្ដែងដែលមាននៅក្នុងខែនោះ ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ ។

**មាត្រា ៥០.-** លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស

ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ ។

**មាត្រា ៥១.-** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥២.-** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិកាជាតិ ។

## ផ្នែកទី ២

## ទោសបន្ថែម

**មាត្រា ៥៣.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការព្យួរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត ។

**មាត្រា ៥៤.-** លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម

ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់ ។

ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។

**មាត្រា ៥៥.-** សិទ្ធិពលរដ្ឋដែលអាចដកបាន

សិទ្ធិពលរដ្ឋដែលអាចដកបានដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ រួមមាន ៖

១-សិទ្ធិបោះឆ្នោត ។

២-សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។

៣-សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ។

៤-សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្ដាល ឬជាអាណត្តិគាហករបស់តុលាការ ។

៥-សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ ។

៦-សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ ។

ទោសនេះអាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

**មាត្រា ៥៦.-** ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ

ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ មិនអនុវត្តទៅលើការបំពេញអាណត្តិដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ឬការទទួលខុសត្រូវខាងសហជីពទេ ។ ការហាមឃាត់នេះ មិនអាចអនុវត្តចំពោះបទល្មើសរំលោភលើច្បាប់ស្ដីពីរបបសារព័ត៌មានទេ ។

ទោសនេះអាចជាស្ថាពរ ឬក៏ជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

តុលាការត្រូវបញ្ជាក់មុខរបរដែលត្រូវហាមឃាត់ ។

**មាត្រា ៥៧.-** ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការបើកបរយានយន្ត មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ទេ។

**មាត្រា ៥៨.-** ការព្យួរលិខិតបើកបរ

ទោសព្យួរលិខិតបើកបរ មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនទៅក្រឡាបញ្ជីតុលាការ ។ លិខិតបើកបរត្រូវរក្សាទុកតាម

លក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៥៩.-** ការហាមឃាត់ចំពោះការស្នាក់នៅទីកន្លែងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា

ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិត ចំពោះការមានមុខនៅទីកន្លែងខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ទោសនេះមិនអាចលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម ។

តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់ និងកំណត់ថិរវេលានៃការហាមឃាត់ ។

ការហាមឃាត់ការស្នាក់នៅ រួមមានវិធានការតាមដាន ។

ទណ្ឌិតត្រូវតែ :

១-ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលដែលតុលាការបានចាត់តាំង ។

២-ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ ។

តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន ។

សេចក្ដីសម្រេចរបស់តុលាការ ត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ៦០.-** ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវលើសពី ៥ (ប្រាំ) ឆ្នាំ ។

ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ ។ លិខិតឆ្លងដែននេះ ត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេ ក្នុងរយៈពេលដែលកំពុងទទួលទោសនោះ ។

**មាត្រា ៦១.-** ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដល់ទណ្ឌិតដែលជាជនបរទេស

ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចជាស្ថាពរ ឬជាបណ្ដោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះ នាំឱ្យមានការបណ្ដេញទណ្ឌិតឱ្យចេញដោយពេញច្បាប់នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ ។

**មាត្រា ៦២.-** ការរឹបអូស

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចតទៅ :

១-ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

ប៉ុន្តែ ការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

**មាត្រា ៦៣.-** ការចាត់ចែងទ្រព្យសម្បត្តិរឹបអូស

កាលបើការរឹបអូសបានក្លាយទៅជាស្ថាពរ ទ្រព្យសម្បត្តិរឹបអូសក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងអំពីការប្រគល់ផ្សេងពីនេះ ។

រដ្ឋអាចលក់ ឬបំផ្លាញទ្រព្យរឹបអូស តាមនីតិវិធីស្ដីពីការលក់ទ្រព្យសម្បត្តិរដ្ឋ ។

**មាត្រា ៦៤.-** ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ

ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង

គ្រាប់រំសេវ អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៥.-** ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ

ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយ :

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទោសបណ្ដេញចេញនេះអាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៦៦.-** ការបិទគ្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង ។

ទោសបិទគ្រឹះស្ថាននេះអាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៦៧.-** ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលត្រូវប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ៦៨.-** ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស

ទោសបិទផ្សាយសេចក្ដីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ទេ ។ ការបិទផ្សាយអាចធ្វើទាំងស្រុង ឬតាមសម្រង់ ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

ក្នុងករណីមានការបំបាត់ចោល ការលាក់បំបាំង ឬការហែកចោលសេចក្ដីប្រកាសនេះ ត្រូវតែធ្វើការបិទផ្សាយជាថ្មី ។ ការបិទផ្សាយនេះ ត្រូវចេញសោហ៊ុយដោយអ្នកបំបាត់ចោល លាក់បំបាំង ឬអ្នកហែកចោលសេចក្ដីប្រកាសនេះ ។

**មាត្រា ៦៩.-** ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ

ទោសផ្សាយសេចក្ដីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងថិរវេលាដែលកំណត់ដោយតុលាការ ។

សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត ។ ក្នុងករណីមិនគោរពតាម ទណ្ឌិតអាចត្រូវបង្ខិដល់រូបកាយ ។

បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្ដីសម្រេច សារព័ត៌មានមិនអាចបដិសេធការផ្សព្វផ្សាយនេះបានទេ ។

**មាត្រា ៧០.-** ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍

ទោសផ្សាយជាសាធារណៈនូវសេចក្ដីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ ។ ការផ្សាយនេះមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ទេ ។ ការផ្សាយអាចផ្សាយទាំងស្រុង តាមសម្រង់ ឬតាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

**មាត្រា ៧១.-** ពេលនៃការអនុវត្តទោសបន្ថែម

ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង ៧ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ ត្រូវអនុវត្តនៅពេល

ផុតទោសពន្ធនាគារ លើកលែងតែមានសេចក្ដីសម្រេចផ្ទុយរបស់តុលាការ។

# ផ្នែកទី ៣
# ទោសជំនួស
## កថាភាគទី ១
## ការងារសហគមន៍

**មាត្រា ៧២.–** និយមន័យនៃការងារសហគមន៍

កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍ ។

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃ ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល ។

**មាត្រា ៧៣.–** អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ ។

**មាត្រា ៧៤.–** របបគតិយុត្តនៃការងារសហគមន៍

ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី ។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ ។

**មាត្រា ៧៥.–** គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ

រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិត នៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍ ។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ ទៅក្នុងសិទ្ធិជនរងគ្រោះ ។

## កថាភាគទី ២
## ការស្ដីបន្ទោស

**មាត្រា ៧៦.–** របបគតិយុត្តនៃការស្ដីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្ដីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ :

-ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើសបានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

## ជំពូកទី ២
## ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស
## ផ្នែកទី ១
## ស្ថានទម្ងន់ទោស
## កថាភាគទី ១
## និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ

**មាត្រា ៧៧.–** ក្រុមមានការចាត់តាំង

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្ដុំដែលបានបង្កើតឡើង ឬជាសន្និដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន ។

**មាត្រា ៧៨.–** ការគិតទុកជាមុន

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស ។

**មាត្រា ៧៩.-** ការកាប់គាស់ទម្លុះទម្លាយ

ការកាប់គាស់ទម្លុះទម្លាយគឺជាអំពើបង្ខំធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬរបង ទោះបីមានប្រភេទយ៉ាងណាក៏ដោយ ។

ត្រូវចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយ :

១-ការប្រើប្រាស់កូនសោក្លែង ។

២-ការប្រើប្រាស់កូនសោដែលបានមកដោយឧបាយកលទុច្ចរិត ។

៣-ការប្រើប្រាស់គ្រប់ឧបករណ៍ ដើម្បីធ្វើឱ្យគ្រឿងបិទមានដំណើរការដោយគ្មានការបង្ខំ ការខូចខាត ឬការបំផ្លិចបំផ្លាញទេ ។

**មាត្រា ៨០.-** ការផ្លោះរបងចូល

ការផ្លោះរបងចូល គឺជាអំពើចូលទៅក្នុងទីកន្លែងណាមួយដោយឆ្លងរបង ឬដោយចូលតាមទ្វារ ឬបង្អួច ដែលមិនមែនសម្រាប់ធ្វើជាផ្លូវចូលទេ ។

**មាត្រា ៨១.-** អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ

អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើឱ្យមានរបួស ។

ត្រូវបានចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចតទៅ :

១-វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឱ្យរបួស ឬគំរាមកំហែង ។

២-វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង ។

ការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង ត្រូវចាត់ទុកដូចបានប្រើប្រាស់អាវុធដែរ ។

**មាត្រា ៨២.-** ការពួនស្ទាក់

ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំជនរងគ្រោះនៅទីកន្លែងណាមួយ ក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្តបទល្មើស ។

# កថាភាគទី ២
# ការមិនរាងចាល

## មាត្រា ៨៣.- អានុភាពនៃការមិនរាងចាល

ការមិនរាងចាលមានអានុភាព នាំឱ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម នៅក្នុងលក្ខខណ្ឌដែលមានចែងដោយកថាភាគនេះ ។

## មាត្រា ៨៤.- លក្ខខណ្ឌនៃការមិនរាងចាល

ការមិនរាងចាលត្រូវបានកើតក្នុងករណីណាមួយដូចតទៅ :

១-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីទៀតនៅក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ។

២-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

៣-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ដោយត្រូវជាប់ពន្ធនាគារស្មើ ឬលើសពី ៣ (បី) ឆ្នាំ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

៤-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមដដែលនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

រយៈពេល ១០ (ដប់) ឆ្នាំ និង ៥ (ប្រាំ) ឆ្នាំ ចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសចំពោះបទល្មើសទី ១ ចូលជាស្ថាពរ ។

## មាត្រា ៨៥.- ការមិនរាងចាលក្នុងបទឧក្រិដ្ឋ

កាលបើបុគ្គលណាមួយត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនេះបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយថ្មីទៀតនៅក្នុងរយៈពេល ១០ (ដប់) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មី ត្រូវបន្ថែមទម្ងន់តាមខ្នាតដូចតទៅ :

១-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មីមិនលើសពី ២០ (ម្ភៃ) ឆ្នាំ ទេ អតិបរមានេះ ត្រូវទ្វេឡើង ។

២-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មីនេះមានរយៈពេល ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។

## មាត្រា ៨៦.- ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទឧក្រិដ្ឋ

កាលបើបុគ្គលណាមួយ ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋណាមួយ បុគ្គលនេះបានប្រព្រឹត្តបទមជ្ឈិមនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិម ត្រូវទ្វេឡើង ។

តាមអានុភាពនៃការមិនរាងចាល ក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ បទល្មើសនៅតែជាបទមជ្ឈិមដដែល ទោះបីជាមានការបន្ថែមទម្ងន់ទោសយ៉ាងណាក៏ដោយ ។

## មាត្រា ៨៧.- ការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម

កាលបើបុគ្គលណាមួយ ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមដាក់ពន្ធនាគារស្មើ ឬលើសពី ៣ (បី) ឆ្នាំ បុគ្គលនេះបានប្រព្រឹត្តបទឧក្រិដ្ឋ នៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ទោសដែលត្រូវផ្តន្ទាទោសលើបទឧក្រិដ្ឋនេះ ត្រូវបន្ថែមទម្ងន់ទៅតាមខ្នាតដូចតទៅ :

១-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមិនលើសពី ២០ (ម្ភៃ) ឆ្នាំ ទេ អតិបរមានេះ ត្រូវទ្វេឡើង ។

២-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមានរយៈពេល ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។

## មាត្រា ៨៨.- ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម

កាលបើបុគ្គលណាមួយ ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមណាមួយ បុគ្គលនេះបានប្រព្រឹត្តបទមជ្ឈិមដដែលនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមថ្មី ត្រូវទ្វេឡើង ។

តាមអានុភាពនៃការមិនរាងចាល ក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ បទល្មើសនៅតែជាបទមជ្ឈិមដដែល ទោះបីជាមានការបន្ថែមទម្ងន់ទោសយ៉ាងណាក៏ដោយ ។

**មាត្រា ៨៩.-** ការប្រដូចបទល្មើស ដើម្បីបង្កើតឱ្យមានការមិនរាងចាល

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល បទលួច បទរំលោភលើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នាដដែល ។

បទល្មើសទទួលផលចោរកម្ម ត្រូវប្រដូចជាបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិដែលទទួលលាក់បំបាំង ។

បទល្មើសសំអាតប្រាក់ ត្រូវប្រដូចជាបទល្មើសដែលការសំអាតប្រាក់នេះបានសម្រេច ។

**មាត្រា ៩០.-** ការមិនរាងចាល និងកិច្ចនៃការចោទប្រកាន់

ការមិនរាងចាលអាចត្រូវតុលាការជំនុំជម្រះកត់ត្រាទុក និងអាចជាមូលហេតុនៃការបន្ថែមទម្ងន់ទោសដាក់ពន្ធនាគារបាន ប្រសិនបើមានចែងយ៉ាងជាក់លាក់នៅក្នុងលិខិតចោទប្រកាន់ ។

**មាត្រា ៩១.-** ការមិនរាងចាល និងសេចក្តីសម្រេចស្ថាពរ

សេចក្តីសម្រេចត្រូវបានចាត់ទុកថាជាស្ថាពរ កាលណាសេចក្តីសម្រេចនេះមិនអាចមានផ្លូវតវ៉ាបានទៀតឡើយ ។

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល ត្រូវគិតគូរតែលើការផ្តន្ទាទោសស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ ។

**មាត្រា ៩២.-** បទប្បញ្ញត្តិដោយឡែក

ការមិនរាងចាលអាចត្រូវកត់ត្រាទុក ទោះបីទោសដែលកើតចេញពីការផ្តន្ទាទោសនោះត្រូវផុតអាជ្ញាយុកាលក៏ដោយ ។

ការមិនរាងចាល មិនអាចត្រូវកត់ត្រាទុកទេ បើទោសដែលកើតចេញពីការផ្តន្ទាទោសស្ថាពរនោះ ត្រូវបានលើកលែងដោយអនុលោមតាមមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ២
## ស្ថានសម្រាលទោស

**មាត្រា ៩៣.-** និយមន័យនៃស្ថានសម្រាលទោស

កាលណាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស ។

ស្ថានសម្រាលទោសអាចត្រូវផ្តល់ឱ្យជនជាប់ចោទបានដែរ ទោះបីជាជននោះត្រូវបានប្រកាសថា ស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ ។

**មាត្រា ៩៤.-** អានុភាពនៃស្ថានសម្រាលទោស

កាលណាតុលាការផ្តល់ឱ្យជនជាប់ចោទនូវស្ថានសម្រាលទោស អប្បបរមានៃមូលទោសចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដូចខាងក្រោម :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ២ (ពីរ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ ហើយតិចជាង ១០ (ដប់) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ (មួយ) ឆ្នាំ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ ហើយតិចជាង ៥ (ប្រាំ) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ ហើយតិចជាង ២ (ពីរ) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យ ត្រូវបន្ថយមកត្រឹមពាក់កណ្តាល ។

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស

កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។

## ជំពូកទី ៣

## របបនៃការប្រកាសទោស

### ផ្នែកទី ១

### របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

ការស្ដីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្ដីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្ដន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះ ចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម :

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា ។

**មាត្រា ១០២.-** ថិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីថិរវេលានៃ

ការងារ និងរយៈពេលដែលត្រូវបំពេញ ។ រយៈពេលនេះមិនអាចលើសពី ១ (មួយ) ឆ្នាំ ទេ ។

**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា ។

ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គល ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ។

ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។

## ផ្នែកទី ២
## ការព្យួរទោសធម្មតា
### កថាភាគទី ១
### បទប្បញ្ញត្តិរួម

**មាត្រា ១០៤.-** ការប្រកាសការព្យួរទោស

នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកនេះ តុលាការអាចបង្គាប់ថា ត្រូវព្យួរការអនុវត្តនូវមូលទោស ។

**មាត្រា ១០៥.-** របបនៃការព្យួរទោស

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការព្យួរទោស ត្រូវគិតតែអំពីការផ្ដន្ទាទោសជាស្ថាពរខាងបណ្ដឹងអាជ្ញាប៉ុណ្ណោះ ។

### កថាភាគទី ២
### ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

**មាត្រា ១០៦.-** លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសពីមុន

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ការព្យួរទោសធម្មតាអាចត្រូវផ្ដល់ឱ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្ដន្ទាទោស

ជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនអំពើល្មើស ។

**មាត្រា ១០៧.-** ទោសអាចនាំឱ្យមានការព្យួរទោស

ការព្យួរទោសធម្មតា ត្រូវអនុវត្តទៅលើទោសដូចតទៅ :

១-ទោសដាក់ពន្ធនាគារ កាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១០៨.-** ការព្យួរទោសមួយផ្នែក

តុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ចិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ។

**មាត្រា ១០៩.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់ ។

ទោសទី ១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី ២ បានឡើយ ។

**មាត្រា ១១០.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៩ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិននាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុននោះទេ។ សេចក្តីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស ។

**មាត្រា ១១១.-** ការទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ

ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀត ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកថាជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

កាលណាបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោសនោះ ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុង ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## កថាភាគទី ៣
## ការចោទប្រកាន់ចំពោះបទលហុ

**មាត្រា ១១២.-** លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាអាចត្រូវបានប្រកាស ប្រសិនបើជនជាប់ចោទ មិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយ នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ មុនបទល្មើសនេះ ។

**មាត្រា ១១៣.-** ទោសអាចនាំឱ្យមានការព្យួរទោស

ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោសដូចតទៅនេះ :

១-ទោសដាក់ពន្ធនាគារ ។

២-ទោសពិន័យជាប្រាក់ ។

**មាត្រា ១១៤.-** ការដកហូតការព្យួរទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះ ត្រូវដកហូតចេញដោយពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រួបជាមួយទោសទី ២ ឡើយ ។

**មាត្រា ១១៥.-** ការមិនដកហូតការព្យួរទោស

ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតការព្យួរទោស) នៃក្រមនេះ តុលាការអាចសម្រេចថា ការផ្តន្ទាទោសថ្មីមិនអាចនាំឱ្យមានការដកហូតនូវការព្យួរទោសធម្មតានេះដែលសម្រេចពីមុននោះទេ។ សេចក្តីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស។

**មាត្រា ១១៦.-** ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុដែលមានការព្យួរទោសធម្មតា គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអសារបង់ ។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ ។

## ផ្នែកទី ៣
## ការព្យួរទោសសាកល្បង

**មាត្រា ១១៧.-** និយមន័យ និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង

តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ការព្យួរទោសសាកល្បង មានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង ។

**មាត្រា ១១៨.-** រយៈពេលនៃការសាកល្បង

តុលាការកំណត់រយៈពេលនៃការសាកល្បង។ រយៈពេលនេះមិនអាចតិចជាង ១ (មួយ) ឆ្នាំ និងមិនលើសពី ៣ (បី) ឆ្នាំ ទេ ។

**មាត្រា ១១៩.-** វិធានការត្រួតពិនិត្យ

វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ :

១-ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែល

ព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

២-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ ។

៣-ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ ។

៤-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន ។

៥-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន ។

៦-ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស ។

**មាត្រា ១២០.-** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត

កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅ :

១-បំពេញសកម្មភាពខាងវិជ្ជាជីវៈ ។

២-ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

៣-រស់នៅក្នុងទីកន្លែងណាមួយជាកំណត់ ។

៤-ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល ។

៥-បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ ។

៦-ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន ។

៧-បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន ។

៨-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់ ។

៩-មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់ ។

១០-មិនត្រូវសេពគប់បនល្បែង ។

១១-មិនត្រូវសេពគប់គៀមភេសជ្ជៈស្រវឹង ។

១២-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ ។

១៣-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត ។

**មាត្រា ១២១.-** ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

នៅគ្រប់ពេលវេលា តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២២.-** ការដកហូតការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បងអាចត្រូវដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ :

១-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ ។

២-ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត ។

តុលាការអាចបង្គាប់ឱ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក ។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក ។

តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២៣.-** ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់

ការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បង ការផ្តន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូតដែលមានសេចក្តីសម្រេចដកហូតទេ ។

## ផ្នែកទី ៤

## ការផ្អាកការប្រកាសទោស

**មាត្រា ១២៤.-** លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

ក្នុងករណីចោទប្រកាន់ពីបទមជ្ឈិម តុលាការក្រោយពីបានប្រកាសថា ជនជាប់ចោទមានពិរុទ្ធ អាចផ្អាកការប្រកាសទោស ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ និង

-ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ។

**មាត្រា ១២៥.-** សេចក្តីសម្រេចនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោសអាចត្រូវបង្គាប់បាន លុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ ។

តុលាការកំណត់នៅក្នុងសាលក្រម ឬសាលដីកានូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស ។

សេចក្តីសម្រេចអំពីទោសត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយសេចក្តីសម្រេចផ្អាក ។

**មាត្រា ១២៦.-** សវនាការពិនិត្យរឿងដែលបង្អង់

នៅពេលសវនាការពិនិត្យរឿងដែលបង្អង់នេះ តុលាការសម្រេចអំពីទោស ។

## ផ្នែកទី ៥
## របបពាក់កណ្តាលសេរីភាព

**មាត្រា ១២៧.-** លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ តុលាការអាចសម្រេចថា ទោសត្រូវអនុវត្តក្រោមរបបពាក់កណ្តាលសេរីភាព ដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្តុះបណ្តាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្តីត្រូវការរបស់គ្រួសារ ។

**មាត្រា ១២៨.-** បែបបទនៃរបបពាក់កណ្តាលសេរីភាព

ទណ្ឌិតដែលស្ថិតនៅក្រោមរបបពាក់កណ្តាលសេរីភាព ត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារ ក្នុងរយៈពេលជាកំណត់ ។

តុលាការកំណត់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបានអនុញ្ញាតឱ្យមានអវត្តមាននៅក្នុងពន្ធនាគារ ។

**មាត្រា ១២៩.-** ការគិតបញ្ចូលរយៈពេលនៃពាក់កណ្តាលសេរីភាពទៅក្នុងទោស

រយៈពេលនៃពាក់កណ្តាលសេរីភាព ត្រូវគិតបញ្ចូលទៅក្នុងថិរវេលានៃទោសដែលកំពុងអនុវត្ត ។

**មាត្រា ១៣០.-** ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្តាលសេរីភាព

នៅគ្រប់ពេល តុលាការអាចរៀបចំរយៈពេលនៃពាក់កណ្តាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្តាលសេរីភាព តាមបណ្តឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣១.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃពាក់កណ្ដាលសេរីភាព ។

## ផ្នែកទី ៦
## ការបែងចែកទោសជាប្រភាគ

**មាត្រា ១៣២.-** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ តុលាការអាចសម្រេចថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម។

**មាត្រា ១៣៣.-** បែបបទនៃការបែងចែកទោសជាប្រភាគ

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ (មួយ) ខែ ទេ ។ ចិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី ២ (ពីរ) ឆ្នាំ ទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស ។

តុលាការកំណត់ក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ ។

**មាត្រា ១៣៤.-** ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ

នៅគ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣៥.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មក

ពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស ។

# ជំពូកទី ៤
# វិធានអនុវត្តនៅក្នុងករណីបទល្មើសត្រួតគ្នា
## ផ្នែកទី ១
## វិធានទូទៅ

**មាត្រា ១៣៦.–** បទល្មើសត្រួតគ្នា

មានបទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ មុនពេលដែលបុគ្គលនេះត្រូវបានផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត ។

**មាត្រា ១៣៧.–** ការចោទប្រកាន់តែមួយ

កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវប្រកាសឡើង ។ ប៉ុន្តែ កាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។

ទោសនីមួយៗ ដែលប្រកាសត្រូវចាត់ទុកថាជាទោសរួម ចំពោះបទល្មើសដែលត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ អនុវត្តទៅលើបទល្មើសនីមួយៗ ។

**មាត្រា ១៣៨.–** ការចោទប្រកាន់ដាច់ពីគ្នា

នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។ ប៉ុន្តែ តុលាការចុងក្រោយដែលត្រូវសម្រេច អាចប្រកាសឱ្យអនុវត្តទោសស្រួបបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា ។

ដើម្បីអនុវត្តមាត្រានេះ នៅក្នុងករណីទោសដែលច្បាប់កំណត់ ជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ (សាមសិប) ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ ។

ការព្យួរទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែលត្រួតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោសនៃប្រភេទដូចគ្នាដែលគ្មានការព្យួរទោសទេ ។

## ផ្នែកទី ២
## វិធានដោយឡែក

**មាត្រា ១៣៩.-** អានុភាពនៃការលើកលែងទោស និងការបន្ធូរបន្ថយទោសលើការស្រូបទោស

កាលបើទោសជាកម្មវត្ថុនៃវិធានការលើកលែងទោស និងបន្ធូរបន្ថយទោសដូចមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែគិតគូរអំពីទោសដែលជាលទ្ធផលនៃការលើកលែងទោស និងបន្ធូរបន្ថយទោស ដើម្បីអនុវត្តវិធានស្តីពីការស្រូបបញ្ចូលគ្នានៃទោស ។

ចិរវេលានៃការបន្ធូរបន្ថយទោស ត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃទោសទៅថ្ងៃមុខ ក្រោយការស្រូបទោស ។

**មាត្រា ១៤០.-** ការបូកបញ្ចូលគ្នានៃទោសពិន័យ

ជាបដិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះ ត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យដែលប្រកាសឡើងចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

**មាត្រា ១៤១.-** ការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាសចំពោះករណីរត់ចេញពីពន្ធនាគារ

ក្នុងករណីផ្តន្ទាទោសពីបទរត់ចេញពីពន្ធនាគារ ទោសដែលប្រកាសពីបទនេះ

ត្រូវបូកជាមួយនឹងទោសដែលប្រកាសឡើង ចំពោះបទល្មើសដែលនាំឱ្យមានការឃុំខ្លួនជននោះ ដោយមិនអាចមានការស្រូបចូលគ្នា ។

## ជំពូកទី ៥
## មូលហេតុទូទៅដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស
### ផ្នែកទី ១
### អាជ្ញាយុកាលនៃទោស

**មាត្រា ១៤២.-** អានុភាពនៃអាជ្ញាយុកាល

នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។

**មាត្រា ១៤៣.-** ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន

ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ ។

ក្រៅពីបទល្មើសខាងលើ ច្បាប់ពិសេសអាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបាន ។

**មាត្រា ១៤៤.-** អាជ្ញាយុកាលនៃទោស

ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ ។

ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ ។

ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ ។

**មាត្រា ១៤៥.-** ចំណុចចាប់ផ្ដើមនៃថិរវេលា

ថិរវេលា ២០ (ម្ភៃ) ឆ្នាំ ៥ (ប្រាំ) ឆ្នាំ និង ១ (មួយ) ឆ្នាំ ខាងលើ ដែលមានចែងនៅក្នុងមាត្រា ១៤៤ (អាជ្ញាយុកាលនៃទោស) នៃក្រមនេះ ចាប់គិតពីថ្ងៃដែលសេចក្ដីសម្រេចផ្ដន្ទាទោស បានក្លាយទៅជាស្ថាពរ ។

**មាត្រា ១៤៦.-** អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើតចេញពីសេចក្តីសម្រេចព្រហ្មទណ្ឌ

កាតព្វកិច្ចដែលមានប្រភេទជារដ្ឋប្បវេណី និងដែលមានប្រភពចេញមកពីសេចក្តីសម្រេចព្រហ្មទណ្ឌដែលក្លាយជាស្ថាពរ ផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។

## ផ្នែកទី ២
## ការអនុគ្រោះទោស

**មាត្រា ១៤៧.-** អានុភាពនៃការអនុគ្រោះទោស

ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬការលើកលែងទោស ដោយអនុលោមតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកលែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះនោះ ។

**មាត្រា ១៤៨.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការអនុគ្រោះទោស

ការអនុគ្រោះទោសមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៃព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការអនុគ្រោះទោសនោះ។

## ផ្នែកទី ៣
## ការលើកលែងទោសជាទូទៅ

**មាត្រា ១៤៩.-** អានុភាពនៃការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

ទោសមិនអាចយកមកអនុវត្តទេ ។

ទោសដែលកំពុងអនុវត្ត ត្រូវបានបញ្ចប់ ។

ប៉ុន្តែ ចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តី ដែលបានបង់រួចហើយ មិនអាចទារសំណងពីរដ្ឋវិញបានទេ ។

**មាត្រា ១៥០.-** ការលើកលែងទោសជាទូទៅ និងការដកការព្យួរទោស

កាលបើការព្យួរទោសពីមុន ត្រូវបានដកហូតដោយអានុភាពនៃការផ្តន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅចំពោះទោសខាងក្រោយនេះ បង្កើតឡើងវិញនូវផលប្រយោជន៍នៃការព្យួរទោសដែលមានពីមុន ។

**មាត្រា ១៥១.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការលើកលែងទោសជាទូទៅ

លើកលែងតែបទប្បញ្ញត្តិផ្ទុយនៃច្បាប់ ការលើកលែងទោសជាទូទៅ មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងការជួសជុលនៃការខូចខាតឡើយ ។

## ផ្នែកទី ៤
## ការរៀបចំទោស និងការលុបចោលទោសបន្ថែមខ្លះៗ

**មាត្រា ១៥២.-** លក្ខខណ្ឌនៃការកែប្រែទោសបន្ថែមខ្លះៗ

ក្នុងករណីផ្តន្ទាទោសបន្ថែមដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦, ៧, ១៤, ១៥ និង ១៦ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ តុលាការអាចបង្គាប់ឱ្យរៀបចំកែប្រែ ឬលុបចោលទោសមួយ ឬច្រើន ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ឈប់

-ព្យសនកម្ម ត្រូវបានជួសជុល និង

-សេចក្តីសម្រេចរៀបចំកែប្រែ ឬលុបចោល មានលក្ខណៈអនុគ្រោះឱ្យធ្វើការបញ្ចូលជនល្មើសទៅរស់នៅក្នុងសង្គមវិញ ។

តុលាការទទួលពាក្យប្ដឹងពីអយ្យការតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនផ្ទាល់ ឬតាមពាក្យប្ដឹងរបស់ទណ្ឌិត ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់យោបល់របស់តំណាងអយ្យការ ទណ្ឌិត និងជាយថាហេតុ មេធាវីរបស់ជននេះ ។

**មាត្រា ១៥៣.-** ការធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ ឬខ្លះៗ

ក្នុងករណីដកសិទ្ធិពលរដ្ឋ តុលាការអាចធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ដែលរៀបរាប់នៅមាត្រា ៥៥ (សិទ្ធិពលរដ្ឋដែលអាចដកបាន) នៃក្រមនេះ ឬក៏សិទ្ធិខ្លះក្នុងចំណោមសិទ្ធិទាំងនេះ ។

**មាត្រា ១៥៤.-** ការរៀបចំកែប្រែ ឬការលុបចោលនូវការហាមឃាត់

តុលាការអាចរៀបចំកែប្រែ ឬលុបចោលនូវ :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ឬសកម្មភាពសង្គម ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ។

**មាត្រា ១៥៥.-** ការប្រគល់ឱ្យវិញនូវលិខិតបើកបរ

ក្នុងករណីព្យួរលិខិតបើកបរ តុលាការអាចបង្គាប់ឱ្យប្រគល់លិខិតបើកបរនេះទៅម្ចាស់វិញ ។

**មាត្រា ១៥៦.-** ការកែប្រែវិធានការនៃការហាមឃាត់ចំពោះការស្នាក់នៅ

ក្នុងករណីផ្ដន្ទាទោសហាមឃាត់ចំពោះការស្នាក់នៅ តុលាការអាចកែប្រែបែបបទនៃវិធានការតាមដាន ។

ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យស្នាក់នៅជាបណ្ដោះអាសន្នសម្រាប់រយៈពេលដែលមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ នៅក្នុងទីកន្លែងដែលហាមឃាត់ ។ ព្រះរាជអាជ្ញាជូនព័ត៌មានអំពីកិច្ចនេះដល់តុលាការ ។

សេចក្ដីសម្រេចរបស់តុលាការ និងព្រះរាជអាជ្ញា ត្រូវបានជូនដំណឹងដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ១៥៧.-** ការកែប្រែការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការអាចលុបចោលការហាមឃាត់ ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ តុលាការអាចគ្រោងទុកនូវលក្ខខណ្ឌខ្លះៗ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ។

**មាត្រា ១៥៨.-** ការកែប្រែការហាមឃាត់ការចូលមកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការអាចលុបចោលការហាមឃាត់ចំពោះការស្នាក់នៅ និងការចូលក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដល់ទណ្ឌិតបរទេស ។

ប៉ុន្តែ ជាបឋម ព្រះរាជអាជ្ញាត្រូវតែទទួលយោបល់ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជូនដំណឹងអំពីយោបល់នេះទៅតុលាការ ។

យោបល់នេះមិនបង្ខំឱ្យតុលាការត្រូវតែអនុវត្តតាមទេ ។

**មាត្រា ១៥៩.-** ការកែប្រែការបណ្ដេញចេញ ការបិទ ការហាមឃាត់ការធ្វើអាជីវកម្ម

តុលាការអាចរៀបចំកែប្រែទោស ឬបញ្ចប់នូវទោសដូចខាងក្រោមនេះ :

១-ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ ។

២-ការបិទគ្រឹះស្ថាន ។

៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

# ជំពូកទី ៦
# ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបាន បន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្ដុះបណ្ដាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល

បទប្បញ្ញត្តិស្ដីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤-ជួសជុលព្យសនកម្មដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយតាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្ដន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។ល

## ផ្នែកទី ២
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែង

សម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ។

## ជំពូកទី ៧
## ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល
### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦៧.-** ទោសដែលត្រូវរងដោយនីតិបុគ្គល

ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលមានដូចតទៅ :

១-ទោសពិន័យក្នុងឋានៈជាមូលទោស ។

២-ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមនេះ ។

### ផ្នែកទី ២
### ទោសបន្ថែម

**មាត្រា ១៦៨.-** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ :

១-ការរំលាយចោល ។

២-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។

៧-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

១១-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន ។

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ ។

**មាត្រា ១៧០.-** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

សេចក្តីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំ ទេ ។ សេចក្តីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។

ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិច អាណត្តិគាហកតុលាការធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្ដឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់យោបល់របស់តំណាងអយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ ។

**មាត្រា ១៧២.–** ការហាមឃាត់ចំពោះការធ្វើសកម្មភាព

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់ថិរវេលា ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់ ។

**មាត្រា ១៧៣.–** ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ

ទោសបណ្ដេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួម ដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំ ដោយ :

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសនេះ អាចជាស្ថាពរ ឬជាបណ្ដោះអាសន្ន សម្រាប់ថិរវេលាមួយមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ១៧៤.–** ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ឱ្យធ្វើការដាក់ប្រាក់សន្សំ

អាចជាស្លាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ការហាមឃាត់នេះ នាំឱ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវដើម្បីឱ្យដាក់ឧបករណ៍អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុនមូលបត្រ ។

ការហាមឃាត់នេះនាំឱ្យមានការហាមឃាត់ចំពោះការផ្សព្វផ្សាយជាសាធារណៈដែរ ។

**មាត្រា ១៧៥.–** ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន

ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន អាចជាស្លាពរ ឬជាបណ្ដោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ចំពោះការហាមឃាត់ប្រើប្រាស់បណ្ណទូទាត់ ក៏ដូចគ្នាដែរ ។

**មាត្រា ១៧៦.–** ការបិទគ្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ។

ទោសនេះអាចជាស្លាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ១៧៧.–** ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយ ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន អាចជាស្លាពរ ឬជាបណ្ដោះអាសន្នក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ១៧៨.–** ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស

កាលបើការរឹបអូសក្លាយជាស្លាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែបទប្បញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត ។

រដ្ឋអាចលក់ ឬបំផ្លាញចោលវត្ថុរឹបអូសនៅក្នុងទម្រង់ដែលមានចែងសម្រាប់ការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ ។ ច្បាប់អាចចែងអំពីការបំផ្លាញចោលនូវវត្ថុខ្លះផងដែរ ។

កាលបើវត្ថុរឹបអូសមិនត្រូវបានចាប់យកទេ ហើយនិងមិនអាចប្រគល់ឱ្យបានទេនោះ ទណ្ឌិតត្រូវចេញសងតម្លៃនៃវត្ថុរឹបអូសនេះ ។ តម្លៃនេះត្រូវបានកំណត់ដោយតុលាការ ។ វិធានការដើម្បីប្រមូលប្រាក់នេះ ត្រូវធ្វើឡើងដូចក្នុងរឿងបង្ខំដល់រូបកាយដែរ ។

**មាត្រា ១៧៩.-** ការរឹបអូស និងសិទ្ធិតតិយជន

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចខាងក្រោមនេះ :

១-ឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើតឡើង ។

ក៏ប៉ុន្តែ ការរឹបអូសមិនអាចត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

**មាត្រា ១៨០.-** ការបិទផ្សាយសេចក្តីសម្រេច

ការបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រាប់រយៈពេលមួយដែលកំណត់ឡើងដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ។ ការបិទផ្សាយ អាចទាំងស្រុងតាមសម្រង់ ឬតាមនិទ្ទេសធម្មតា ។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ក្នុងករណីដែលដកបំបាត់ចេញ លាក់បំបាំង ឬហែកចោលសេចក្តីប្រកាសបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្តងទៀត ។ សោហ៊ុយនៃការបិទផ្សាយនេះត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោល លាក់បំបាំង ឬហែកចោល ។

**មាត្រា ១៨១.–** ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍

ទោសផ្សាយសេចក្តីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ ។ ការផ្សាយនេះ មិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ។ ការផ្សាយនេះ អាចផ្សាយទាំងស្រុង តាមសម្រង់ ឬតាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់នីតិបុគ្គល ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មានមិនអាចបដិសេធការចុះផ្សាយនេះបានទេ ។

**មាត្រា ១៨២.–** ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងរូបវន្តបុគ្គល និងនីតិបុគ្គល

បទប្បញ្ញត្តិនៃមាតិកាទី ១ មាតិកាទី ២ និងមាតិកាទី ៣ នៃគន្ថីទី ១ នៃក្រមនេះដែលទាក់ទងនឹងរូបវន្តបុគ្គល ត្រូវអនុវត្តទៅលើនីតិបុគ្គលក្នុងកម្រិតដែលបទប្បញ្ញត្តិនេះ មិនផ្ទុយជាមួយនឹងបទប្បញ្ញត្តិនៃជំពូកនេះ ។